អធិប្បាយ
ប្រជុំកឋធម៌ពិស្ដារ

ភាគ ២

បណ្ឌិត ឈឹម-ទូច

រៀបរៀង

ជំនួយសាលាធម្មវិន័យថ្នាក់ត្រី

ចិរំ តិដ្ឋតុ ពុទ្ធសាសនំ

សូមឲ្យព្រះពុទ្ធសាសនាប្រតិស្ឋាននៅអស់កាលដ៏យូរ

ផ្សាយពី បណ្ណាគារ

លេខ ១៨៦ វិថីខេមរភូមិន្ទ ភ្នំពេញ

ព.ស. ២៥១៦ គ.ស. ១៩៧២

ផ្សាយចេញពី

www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

អធិប្បាយ ប្រជុំកខធម៌ពិស្ដារ

ភាគទី ២

បណ្ឌិត ឈឹម ទូច

រៀបរៀង

ជំនួយសាលាធម្មវិន័យថ្នាក់ត្រី

ផ្សាយចេញលើកទី ៥

ចិរំ តិដ្ឋតុ ពុទ្ធសាសនំ

“ សូមឲ្យព្រះពុទ្ធសាសនាប្រតិស្ឋាននៅអស់កាលដ៏យូរ ! ”

ការផ្សាយរបស់

បណ្ណាគារ **គិម អេង** លេខ ១៤៦

វិថីខេមរ ភូមិន្ទ ភ្នំពេញ

ព. ស. ២៥១៦ គ. ស. ១៩៧២

ចតុក្កៈ ពួក ៤

វគ្គ “ ធម៌ជាគ្រឿងចំរើន ” ៤ យ៉ាង

១– សប្បុរិសូបសំសេវៈ សេពគប់សប្បុរស គឺលោកអ្នកប្រព្រឹត្តល្អដោយ កាយ វាចា ចិត្ត ,

២– សទ្ធម្មស្សវនៈ ស្ដាប់ពាក្យប្រដៅរបស់លោកដោយគោរព

៣– យោនិសោមនសិការៈ ត្រិះរិះឲ្យស្គាល់របស់ល្អឬអាក្រក់ដោយឧបាយដែលត្រូវ ,

៤– ធម្មានុធម្មប្បដិបត្តិៈ ប្រតិបត្តិធម៌សមគួរដល់ធម៌ដែលបានត្រិះរិះឃើញហើយ ។

អធិប្បាយថា

ពាក្យថា “ សប្បុរស ” សំដៅយកបុគ្គលដែលប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត គឺបុគ្គលដែលប្រកបដោយធម៌ ៧ គឺ:

១– ធម្មញ្ញុតា ភាពជាអ្នកស្គាល់ហេតុ, ដូចស្គាល់ថា សមុទយៈជាហេតុឲ្យកើតសេចក្ដីទុក្ខមាន ១២ ករ, មគ្គសច្ច ជាហេតុឲ្យកើតសេចក្ដីសុខ គឺព្រះនិព្វាន ;

២– អត្ថញ្ញុតា ភាពជាអ្នកស្គាល់ផល , ដូចស្គាល់ថាទុក្ខសច្ច

ជាផលរបស់សមុទយសច្ច, និរោធសច្ច ជាផលរបស់មគ្គសច្ចជាដើម ;

៣- អត្តញ្ញុតា ភាពជាអ្នកស្គាល់ខ្លួនថា អាត្មាអញនេះមានជាតិ ត្រកូល យស ស័ក្តិ សម្បត្តិ បរិវារ សេចក្តីចេះដឹង គុណធម៌ដែលមានក្នុងសន្តានតែប៉ុណ្ណេះ ហើយប្រព្រឹត្តខ្លួនឲ្យគួរដល់ឋានៈរបស់ខ្លួន មិនមានការផ្តើងផ្តៃច្រលើសបើសហួសហេតុ :

៤- មត្តញ្ញុតា ភាពជាអ្នកស្គាល់ប្រមាណក្នុងការស្វែងរកគ្រឿងចិញ្ចឹមជីវិតដោយផ្លូវប្រពៃ និងស្គាល់ប្រមាណក្នុងការបរិភោគជាដើម ;

៥- កាលញ្ញុតា ភាពជាអ្នកស្គាល់កាលវេលា ដែលគួរនឹងប្រកបការងារនោះ ៗ ឲ្យទាន់ពេលវេលា ,

៦- បរិសញ្ញុតា ភាពជាអ្នកស្គាល់បរិស័ទក្នុងទីប្រជុំជននិងកិរិយាដែលត្រូវប្រព្រឹត្តក្នុងទីប្រជុំជននោះថា ពួកជននេះ កាលអាត្មាអញចូលទៅរកត្រូវធ្វើកិរិយាយ៉ាងនេះ ៗ ត្រូវធ្វើកិរិយាយ៉ាងនោះ ៗ ជាដើម ,

៧- បុគ្គលបរោបរញ្ញុតា ភាពជាអ្នកស្គាល់បុគ្គល , ដូចស្គាល់ថា អ្នកនេះជាមនុស្សល្អគួរសេពគប់, អ្នកនេះជាមនុស្សមិនល្អ មិនគួរសេពគប់ជាដើម ។

សប្បុរសធម៌ ៧ ផ្សេងទៀត

១- សប្បុរសប្រកបដោយធម៌ ៧ គឺមានសទ្ធា មានសេចក្តីខ្មាស់បាប, មានសេចក្តីខ្លាចបាប, ជាអ្នកបានឮបានស្តាប់ច្រើន, ជាអ្នកមានព្យាយាម, ជាអ្នកមានសេចក្តីខ្ជាប់ខ្លួន, ជាអ្នកមានបញ្ញា ;

២- សប្បុរសបើប្រឹក្សារឿងអ្វីនឹងអ្នកណា ក៏មិនប្រឹក្សាដើម្បីបៀតបៀនខ្លួននិងអ្នកដទៃ

៣- សប្បុរសបើគិតអ្វី ក៏មិនគិតដើម្បីបៀតបៀនខ្លួននិងអ្នកដទៃ ,

៤- សប្បុរសបើពោលអ្វីក៏មិនពោលដើម្បីបៀតបៀនខ្លួននិងអ្នកដទៃ ,

៥- សប្បុរសបើធ្វើអ្វី ក៏មិនធ្វើដើម្បីបៀតបៀនខ្លួននិងអ្នកដទៃ,

៦- សប្បុរសតែងមានសេចក្តីឃើញប្រពៃ មានឃើញថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ជាដើម,

៧- សប្បុរសតែងឲ្យទានដោយគោរព គឺអើពើនិងរបស់ដែលខ្លួនឲ្យ អើពើនឹងអ្នកទទួលទាន មិនធ្វើអាការដូចជាអ្នកបោះចោល ៗ

ការពោលមកប៉ុណ្ណេះជាដើម ឈ្មោះថា សប្បុរសធម៌ ៧ ព្រោះហេតុនោះ សាធុសប្បុរសទាំងឡាយ កាលបើឃើញលោកអ្នកសប្បុរសប្រព្រឹត្តដោយ កាយ វាចា ចិត្ត ដូច្នេះ, គួរតែចូលទៅសមាគមជាមួយនឹងសប្បុរសកុំខាន, សមដូចរឿងពណ៌នាតទៅនេះ,

បានឮថា មានពួកឈ្មួញច្រើននាក់ នាំគ្នាចុះស្លុះទៅកាន់សមុទ្រ

ដោយនាវាដ៏ធំ ។ ពួកឈ្មួញទាំងនោះបានបើកសំពៅទៅ លុះទៅដល់ពាក់កណ្តាលសមុទ្រ ក៏កើតឧបទ្រពចង្រៃយ៉ាងមហោឡារិក គឺមានរលកធំ ៗ តាំងឡើងដោយអំណាចខ្យល់ព្យុះទឹកចូលពេញលិចទៅ ។ កាលដែលសំពៅទៀបនឹងលិចទៅឡើយ ពួកឈ្មួញទាំងនោះបានរឭកនឹកដល់ឈ្មោះទេវតារៀងរាល់ខ្លួន និងធ្វើកិច្ចបន់ស្រន់ជាដើមហើយនាំគ្នាស្រែកទ្រហោយំ ។ ក្នុងកាលនោះមានបុរសម្នាក់គិតពិចារណាថា អាត្មាមានទីពឹងក្នុងមហាភ័យនេះដែរឬ ? ស្រាប់តែនឹកឃើញដល់សរណគមន៍និងសីលដ៏បរិសុទ្ធរបស់ខ្លួន ហើយក៏អង្គុយពែនភ្នែនកណ្តាលជនទាំងនោះ ហាក់ដូចជាព្រះយោគីធ្វើកម្មដ្ឋាន ។ ពួកមហាជនកាលបើឃើញហេតុអស្ចារ្យរបស់បុរស ដែលមិនតក់ស្លុតនិងឧទកភ័យដូច្នោះហើយក៏សួរ, បុរសនោះប្រាប់ថា ម្នាលអ្នកទាំងឡាយ, មុនថ្ងៃដែលយើងឡើងជិះនាវាមក, យើងបានឲ្យទានដល់ភិក្ខុសង្ឃ និងបានសមាទានសរណគមន៍សីលរួចស្រេចហើយ ទើបយើងចេញមក, អាស្រ័យដោយហេតុនេះហើយ បានជាមិនភ័យ ។ បពិត្រអ្នកជាម្ចាស់ ? សរណគមន៍និងសីលនោះគួរដល់អ្នកដទៃដែរឬ ? គួរដល់អ្នកដទៃដែរ ។ បើដូច្នោះអ្នកចូលឲ្យដល់យើងរាល់គ្នាផង ។ បុរសនោះធ្វើជនទាំងនោះឲ្យទៅជា ៧ ចំណែក ក្នុងមួយចំណែក ៗ ១០០ នាក់ ៗ ។ ទើបបុរសនោះឲ្យសីល ៥ ដល់ជនទាំងអស់ ។ បណ្តាជនទាំងនោះ ជន

១០០ នាក់ទី ១ សមាទានសីលក្នុងវេលាទឹកត្រឹមករជើង, ពួកជន ១០០ ទី ២ សមាទានសីលក្នុងវេលាទឹកត្រឹមជង្គង់. ទី ៣ ត្រឹមចង្កេះ, ទី ៤ ត្រឹមផ្ចិត, ទី ៥ ត្រឹមដោះ, ទី ៦ ត្រឹមក, ទី ៧ សមាទានសីលក្នុងវេលាទឹកប្រៃចូលមាត់ ។ បុរសនោះបានឲ្យសីលដល់មនុស្សទាំងអស់រួចហើយ ស្រែកប្រកាសឃោសនាឡើងថា អ្នកទាំងឡាយ គ្មានទីពឹងអ្វីដទៃក្រៅពីសីលនេះទេ, ចូរពិចារណាសីលតែម្យ៉ាងចុះ ។ ពួកជនទាំង ៧០០ នាក់ក៏ធ្វើមរណកាលក្នុងសមុទ្រទាំងអស់ ក៏បានទៅកើតក្នុងពិភពតាវតឹងទេវលោក ព្រោះអាស្រ័យសីលដែលខ្លួនបានសមាទានក្នុងសម័យជិតស្លាប់ ។ វិមានទាំងឡាយ ក៏កើតមានដល់ទេវតាទាំងនោះដោយពួកដោយដុំ ។ វិមានមានប្រមាណ ១០០ យោជន៍កើតឡើងដល់ទេវតាជាអាចារ្យ នាកណ្តាលវិមានទាំងអស់ ។ វិមានក្រៅអំពីនោះ ជាបរិវារនៃវិមាននោះ, វិមានយ៉ាងទាបជាងគេបង្អស់ត្រឹម ១២ យោជន៍ ។ ទេវតាទាំងឡាយ, ក៏រំពឹងបុញ្ញកម្មគុណៈដែលខ្លួនបានទៅកើតរួចហើយបានដឹងច្បាស់ថា សម្បត្តិដែលខ្លួនបាននោះព្រោះអាស្រ័យទេវតាជាអាចារ្យ ហើយនាំគ្នាទៅនិយាយសរសើរគុណអាចារ្យក្នុងសំណាក់ព្រះឱសពល ។ រឿងនេះ មានក្នុងអដ្ឋកថាទេវតាសំយុត្ត ។

មានរឿងក្នុងបាលី សត្តិសូត្រ ទេវតាសំយុត្ត ក្នុងគម្ពីរសំយុត្តនិ-

កាយថា ទេវតាទាំងអស់នោះឈ្មោះថា "សតុល្លបកាយិកាទេវតា" មានរស្មីភ្លឺព្រោងព្រាយ ញុំាងវិហារជេតពនឲ្យភ្លឺស្វាងទាំងអស់ ក្នុងវេលាពាក់កណ្ដាលរាត្រី ហើយចូលទៅគាល់ព្រះមានព្រះភាគ, លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីក៏សមគួរ ។ ទេវតាមួយអង្គលុះឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ពោលគាថា ក្នុងសំណាក់ព្រះមានព្រះភាគថា:

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សេយ្យោ ហោតិ ន បាបិយោ ។

បុគ្គលគប្បីអង្គុយជាមួយនឹងសប្បុរស គប្បីធ្វើសេចក្ដីរីករាយជាមួយនឹងសប្បុរស, សេចក្ដីល្អនិងចំរើនមានដល់បុគ្គលនោះ, សេចក្ដីអាក្រក់មិនមានដល់បុគ្គលនោះឡើយ ព្រោះបុគ្គលនោះបានដឹងច្បាស់នូវព្រះសទ្ធម្មរបស់សប្បុរសទាំងឡាយ ។

លំដាប់នោះ មានទេវតាដទៃទៀត បានពោលគាថានេះក្នុងសំណាក់ព្រះមានព្រះភាគថា :

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ បញ្ញំ លភតិ នាញ្ញតោ ។

បុគ្គលគប្បីអង្គុយជាមួយនឹងសប្បុរស, គប្បីធ្វើសេចក្ដីរីករាយ

ជាមួយនឹងសប្បុរស, បុគ្គលនោះរមែងបានបញ្ញា ព្រោះដឹងច្បាស់នូវព្រះសទ្ធម្មរបស់សប្បុរសទាំងឡាយ មិនមែនបានអំពីសំណាក់បុគ្គលដទៃឡើយ ។

លំដាប់នោះ មានទេវតាដទៃទៀត បានពោលថានេះ ក្នុងសំណាក់ព្រះសាស្ដាថា :

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សោកមជ្ឈេ ន សោចតិ ។

បុគ្គលគប្បីអង្គុយជាមួយនឹងបុរស គប្បីធ្វើសេចក្ដីរីករាយជាមួយនឹងសប្បុរស, បុគ្គលនោះរមែងមិនសោយសោកក្នុងកណ្ដាលនៃពួកជនដែលប្រកបដោយសេចក្ដីសោយសោកព្រោះដឹងច្បាស់នូវព្រះសទ្ធម្មរបស់សប្បុរសទាំងឡាយ ។

លំដាប់នោះ ទេវតាដទៃទៀត បានពោលគាថានេះ ក្នុងសំណាក់ព្រះមានជោគថា :

សព្ភិរេវ សមាសេថ សព្ភិ កុព្វេ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ ញាតិមជ្ឈេ វិរោចតិ ។

បុគ្គលគប្បីអង្គុយជាមួយនឹងសប្បុរស គប្បីធ្វើសេចក្ដីរីករាយជាមួយនឹងសប្បុរស, បុគ្គលនោះរមែងរុងរឿងក្នុងកណ្ដាលនៃ

ញាតិ ព្រោះដឹងច្បាស់នូវសទ្ធម្ម របស់សប្បុរសទាំងឡាយ ៗ

លំដាប់នោះ ទេវតាដទៃទៀត បានពោលគាថានេះក្នុងសំណាក់ព្រះគគវន្តមុនីថា :

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ

សតំ សទ្ធម្មមញ្ញាយ សត្តា គច្ឆន្តិ សុគតី ។

បុគ្គលគប្បីអង្គុយជាមួយនឹងសប្បុរស គប្បីធ្វើសេចក្ដីរីករាយជាមួយនឹងសប្បុរស , សត្វទាំងឡាយបានដឹងច្បាស់នូវព្រះសទ្ធម្មរបស់សប្បុរសទាំងឡាយហើយ រមែងទៅកាន់សុគតិភព ៗ

លំដាប់នោះ ទេវតាដទៃទៀត បានពោលគាថានេះ ក្នុងសំណាក់ព្រះមានព្រះភាគថា :

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ

សតំ សទ្ធម្មមញ្ញាយ សត្តា តិដ្ឋន្តិ សាតតំ ។

បុគ្គលគប្បីអង្គុយជាមួយនឹងសប្បុរស គប្បីធ្វើសេចក្ដីរីករាយជាមួយនឹងសប្បុរស, សត្វទាំងឡាយបានដឹងច្បាស់នូវព្រះសទ្ធម្មរបស់សប្បុរសទាំងឡាយហើយ រមែងឋិតនៅជាសុខ អស់កាលដ៏យូរ ៗ

លំដាប់នោះ ទេវតាដទៃទៀត ក្រាបបង្គំទូលសួរព្រះមានព្រះភាគ

ជាម្ចាស់ថា បពិត្រព្រះអង្គដ៏ចំរើន , សូមទ្រង់ព្រះមេត្តាប្រោស ! បណ្ដាពាក្យយើងខ្ញុំទាំងអស់គ្នាបើពាក្យនរណាល្អពីរោះជាងគេ ? ព្រះមានព្រះភាគទ្រង់ត្រាស់ថា ពាក្យអ្នកទាំងអស់គ្នា សុទ្ធតែជាពាក្យល្អពីរោះដោយបែបដោយយ៉ាង តែថាអ្នកទាំងឡាយចាំស្ដាប់ពាក្យតថាគតម្ដងវិញមើល ! ព្រះអង្គទ្រង់ត្រាស់ថា :

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ

សតំ សទ្ធម្មមញ្ញា សព្វទុក្ខា បមុច្ចតិ ។

បុគ្គលគប្បីអង្គុយជាមួយនឹងសប្បុរស គប្បីធ្វើសេចក្ដីរីករាយជាមួយនឹងសប្បុរស បុគ្គលបានដឹងច្បាស់នូវព្រះសទ្ធម្មរបស់សប្បុរសទាំងឡាយហើយ **រមែងរួចចាកទុក្ខទាំងពួង** ៗ

ជនជាសប្បុរសទាំងឡាយ កាលបើឃើញអានិសង្សនៃការសេពគប់សមាគមជាមួយនឹងសប្បុរសដូច្នេះហើយ គួរតែចូលទៅធ្វើសមាគមជាមួយសប្បុរសនោះកុំខាន ; ព្រោះថាការសេពគប់សមាគមជាមួយសប្បុរស គឺលោកអ្នកប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត នោះជាហេតុឲ្យបានស្ដាប់ពាក្យប្រដៅរបស់លោក , ការបានស្ដាប់បានព្រមជាហេតុឲ្យប្រើសេចក្ដីគិត ឬ ជាហេតុឲ្យមានគំនិត កាលបើដឹងខុសត្រូវហើយ ជាហេតុប្រព្រឹត្តធម៌ដ៏សមគួរដល់ធម៌ គេចវេះចៀសវាងអំពីផ្លូវអាក្រក់ខិលខូច

ជាឧបាយបណ្តុះបណ្តាលសេចក្តីចំរើនដល់ខ្លួនទាំងអស់ , ដូច្នេះធម៌ទាំង ៤ ប្រការនេះ ទាក់ទងអាស្រ័យគ្នាដោយហេតុនិងផល , គួរសាធុជនប្រកបឲ្យមានបរិបូណ៌ឡើង រមែងបានសេចក្តីចំរើន តាមសមគួរដល់ការប្រតិបត្តិ , ការសេពគប់សមាគម ចាត់ជាការសំខាន់មួយ ជាហេតុខាងដើម គួរជ្រើសរើសគប់នឹងសប្បុរសដូចបានពោលមកហើយ, ព្រោះការសេពគប់សម្ពគ្នាអាចជ្រួតជ្រាបនិស្ស័យ ចិត្តថ្លើមហូតដល់សេចក្តីប្រព្រឹត្តឲ្យដូចបាន ។

ចក្កធម៌ ៤ យ៉ាង

១ - បដិរូបទេសវាសៈ នៅក្នុងប្រទេសដ៏សមគួរ ,

២ - សប្បុរិសូបសំសេវៈ សេពគប់សប្បុរស ,

៣ - អត្តសម្មាបណិធិៈ តាំងខ្លួនដោយប្រពៃ ,

៤ - បុព្វេកតបុញ្ញតា: ជាអ្នកបានធ្វើបុណ្យទុកមកពីក្នុងកាលមុនៗ

ធម៌ ៤ យ៉ាងនេះប្រៀបដូចកង់រថ នាំទៅកាន់សេចក្តីចំរើន ។

អធិប្បាយថា :

ទីឋានដ៏សមគួរដល់ការ ប្រកបកិច្ចធុរៈរបស់ខ្លួនក្តី, ស្រួលសប្បាយដល់ការនៅក្តី , ឈ្មោះថាប្រទេសដ៏សមគួរ , តែក្នុងទីនេះបំណងយកប្រទេសដែលមានសប្បុរស ។

ការនៅក្នុងប្រទេសដ៏សមគួរនោះ ជាបច្ច័យឲ្យបាននូវអនុត្តរិយៈទាំង ៦ គឺៈ ទស្សនានុត្តរិយៈ ១ , សវនានុត្តរិយៈ ១ , លាភានុត្តរិយៈ ១ . សិក្ខានុត្តរិយៈ ១ , បារិចរិយានុត្តរិយៈ ១ , អនុស្សតានុត្តរិយ ១ , ។

ទស្សនានុត្តរិយៈ ការឃើញមានឃើញដំរីរត្ន, សេះរត្ន, កែវមណី, រូបខ្ពស់ ទាប, សមណៈនិងព្រាហ្មណ៍ដែលជាមច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុស, ការឃើញទាំងនេះ មិនឈ្មោះថា ទស្សនានុត្តរិយៈទេ ឈ្មោះថាហីនធម៌ តាមធម៌; លុះតែបុគ្គលណាមួយឃើញ, តថាគតក្តី សាវ័កតថាគតក្តី នោះទើបឈ្មោះជា ទស្សនានុត្តរិយៈ , បុគ្គលពួកខ្លះស្តាប់ចម្រៀងមានពិណ, ស្គរ, សម្ភោរ, ស្រឡៃ, ប៉ីអ ជាដើម ការស្តាប់ទាំងនេះមិនឈ្មោះថា សវនានុត្តរិយៈទេ, ហៅថា ហីនធម៌តាមធម៌វិញ , លុះតែបុគ្គលណាមួយ ស្តាប់ធម្មទេសនារបស់តថាគតក្តី ធម្មទេសនាដែលសាវ័កតថាគតសំដែងក្តី ដើម្បីប្រាសចាកទុក្ខទាំងពួង , ការស្តាប់ទាំងនេះ ទើបឈ្មោះថា សវនានុត្តរិយ; បុគ្គលបានកូនក្តី, ប្រពន្ធក្តី ទ្រព្យសម្បត្តិក្តី ការបានរូបខ្ពស់ ទាបក្តី ការបានទាំងនេះមិនឈ្មោះថា លាភានុត្តរិយៈទេ , ហៅថាហីនធម៌ តាមធម៌ វិញ ; លុះតែបុគ្គលណាមួយ បានជឿតាមឱវាទតថាគតក្តី ឱវាទសាវ័កតថាគតក្តី នោះទើបឈ្មោះថា លាភានុត្តរិយៈ , សិក្សានូវការបរសេះក្តី ហាត់ដំរីក្តី សិក្សាតាមពាក្យប្រៀនប្រដៅរបស់សមណៈ នឹងព្រាហ្មណ៍

ដែលជាមិច្ឆាទិដ្ឋិក្តី ការសិក្សាទាំងនេះមិនឈ្មោះថា សិក្ខានុត្តរិយៈទេ, ហៅថា ហីនធម៌ គាមធម៌វិញ, លុះតែបុគ្គលណាមួយសិក្សានូវសិក្ខាទាំង ៣ គឺ អធិសីលសិក្ខា ១, អធិចិត្តសិក្ខា ១, អធិប្បញ្ញាសិក្ខា ១ ក្នុងធម្មវិន័យដែលតថាគតសំដែងហើយ នោះទើបឈ្មោះថា សិក្ខានុត្តរិយៈ, ការបំរើក្សត្រក្តី ព្រាហ្មណ៍ក្តី គហបតីក្តី សមណៈដែលជាមិច្ឆាទិដ្ឋិក្តី ការបំរើទាំងនេះមិនឈ្មោះថា បារិចរិយានុត្តរិយៈទេ, ហៅថា ហីនធម៌ គាមធម៌វិញ; លុះតែបុគ្គលណាបំរើតថាគតក្តី សាវ័កតថាគតក្តី បំរើទាំងនេះ ទើបឈ្មោះថា បារិចរិយានុត្តរិយៈ បុគ្គលរឭកកូនក្តី ប្រពន្ធក្តី ទ្រព្យសម្បត្តិក្តី សមណៈនិងព្រាហ្មណ៍ដែលជាមច្ឆាទិដ្ឋិក្តី បុគ្គលរឭកទាំងនេះ មិនឈ្មោះថា អនុស្សតានុត្តរិយៈទេ, ហៅថាហីនធម៌, គាមធម៌វិញ, លុះតែបុគ្គលរឭកនូវតថាគតក្តី សាវ័កតថាគត នោះទើបឈ្មោះថា អនុស្សតានុត្តរិយៈ ។

ទស្សនានុត្តរិយៈ ដូចមានរឿងដំណាលថា :

មានព្រាហ្មណ៍ម្នាក់ឈ្មោះវក្កលិ នៅក្រុងពារាណសី ។

សម័យថ្ងៃមួយនោះ, ព្រះពុទ្ធជាម្ចាស់ទ្រង់ស្តេចយាងចូលទៅក្នុងក្រុងដើម្បីបិណ្ឌបាត ។ ចំណែកព្រាហ្មណ៍ស្រាប់តែក្រឡេកភ្នែកមើលទៅឃើញព្រះអង្គ ហើយចេះតែសំឡឹងមិនប៉ព្រិចភ្នែកសោះដោយនឹកក្នុងចិត្តថាឃើអើ? រូបព្រះអង្គប៉េចក៏ស្អាតដល់ម្ល៉េះហ្ន៎? អញមិនដែលមើលគាប់

ចិត្តរបស់អ្នកណាម្តងសោះ, ទើបតែឃើញម្តងនេះដូចជាចម្លែកពេកណាស់ ម៉្លោះហើយការមើលរបស់ព្រាហ្មណ៍នោះមិនចេះឆ្អែតសោះ ។ ព្រះអង្គយាងចូលទៅក្នុងក្រុងបិណ្ឌបាតត្រឡប់វិញដរាបណា, ព្រាហ្មណ៍ចេះតែមើលមិនដាក់ភ្នែកដរាបនោះ, ហើយក៏ដើរតាមក្រោយព្រះបរមសាស្តាប្រយោជន៍ដល់ការមើលព្រះរូបដរាបតែព្រះអង្គយាងដល់វត្តជេតពនវិញ ។ កាលដែលព្រះអង្គយាងចូលទៅដល់វត្តជេតពនហើយ, ព្រាហ្មណ៍នៅខាងក្រៅឧបចារវត្តអង្គុយគិតតែម្នាក់ឯងថា អាត្មាអញតាំងពីឃើញរូបព្រះអង្គកាលណា, អញមិនដែលរស់ចិត្តក្នុងការមើលសោះ បើដូច្នោះ មានតែអញទៅបួសទើបមើលព្រះរូបព្រះអង្គឆ្អែត, លុះគិតដូច្នេះហើយក៏ចូលទៅក្នុងវិហារក្រាបថ្វាយបង្គំសុំផ្នួសបួសក្នុងទីចំពោះព្រះភក្ត្រព្រះអង្គ ។ ភិក្ខុនោះចាប់តាំងពីបួសហើយកាលណា ទៅជាបុគ្គលមិនមានការសិក្សាស្វែងស្វាធ្យាយធម្មវិន័យត្រៃសិក្ខាអ្វីនឹងគេទេ, គឺចេះតែរមិលមើលព្រះរូបទោះបីព្រះអង្គគង់ក្តី និមន្តយាងទៅមកក្តី ក៏មិនមានភ្លេចក្នុងការមើលនោះឡើយ, ចំណែកព្រះសាស្តាព្រះអង្គទ្រង់ចាំឲ្យតែញាណរបស់ព្រាហ្មណ៍ចាស់ក្លាក្នុងកាលណា, នឹងសំដែងធម៌ប្រោសក្នុងកាលនោះ, តែព្រះអង្គមិនដែលមានពុទ្ធដីកាបន្តិចបន្តួចដល់ភិក្ខុនោះទេ, លុះដល់រដូវជិតចូលវស្សា ព្រះអង្គទើបមានពុទ្ធដីកាចំពោះវក្កលិភិក្ខុថា ម្នាលវក្កលិ ! ប្រយោជន៍អ្វីដោយការមើលរូបតថាគត, ម្នាលវក្កលិ បុគ្គលណាមួយ

បានឃើញតថាគត បុគ្គលនោះ ទុកដូចជាឃើញធម៌របស់តថាគត, មួយទៀត បុគ្គលណាបានឃើញធម៌របស់តថាគត បុគ្គលនោះទុកដូចជាឃើញរូបតថាគតដែរ ៖ លុះមានពុទ្ធដីកាដូច្នេះ ចំពោះវក្កលិភិក្ខុនោះហើយ ក៏ទ្រង់ត្រាស់បណ្ដេញដោយពុទ្ធដីកាថា ម្នាលវក្កលិ! ចូរអ្នកថយចេញពីទីនេះឲ្យឆាប់, ចំណែកវក្កលិភិក្ខុកាលបើឮពុទ្ធដីកាដែលព្រះអង្គត្រាស់បណ្ដេញដូច្នោះហើយ ក៏សម្រក់ទឹកភ្នែកតក់ៗ ដោយគិតថា! ឃីអើ? អាត្មាអញចំជាបុគ្គលវិនាសធំ, ណ្ហើយ! បើដូច្នោះអញនៅរស់ធ្វើអ្វីទៀត! លុះគិតដូច្នេះហើយក៏ក្រោកចេញចាកពីទីនោះទៅឡើងលើភ្នំប្រុងនឹងទម្លាក់ខ្លួនពីលើឲ្យស្លាប់តែម្ដង ។ កាលដែលព្រាហ្មណ៍ឡើងដល់កំពូលភ្នំហើយ, ព្រះអង្គទ្រង់ព្រះចិន្ដាថា ឱ! វក្កលិទៅកាន់ទីណាហ្ន៎!, ក៏ទ្រង់ជ្រាបក្នុងព្រះហឫទ័យថា វក្កលិឡើងលើកំពូលភ្នំប្រុងនឹងសម្លាប់ខ្លួនឯងតើ! កាលបើព្រះអង្គទ្រង់ជ្រាបក្នុងព្រះហឫទ័យដូច្នេះហើយ ព្រះអង្គទ្រង់មិនព្រងើយកន្តើយទេ ទ្រង់ផ្សាយឆព្វណ្ណរង្សីទៅកាន់ទីចំពោះវក្កលិមុខភិក្ខុហើយសំដែងធម៌ហាក់ដូចជាព្រះអង្គគង់នៅចំពោះមុខភិក្ខុនោះ ដោយព្រះពុទ្ធដីកាជាគាថា ថា៖

បាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។

ភិក្ខុច្រើនទៅដោយប្រាមោទ្យជ្រះថ្លា ហើយក្នុងព្រះពុទ្ធសាសនារមែងត្រាស់ដឹងនូវបទ (ព្រះនិព្វាន) ដ៏ស្ងប់-រម្ងាប់ជាសុខ ជាទីចូលទៅរម្ងាប់បង់នូវសង្ខារ ។

លុះសំដែងគាថានេះចប់ហើយ ទ្រង់លាព្រះហស្តហើយត្រាស់ហៅដោយព្រះវាចាថា ម្នាលវក្កលិ! ចូរអ្នកមក កុំភ័យអ្វីឡើយ; វក្កលិភិក្ខុបានស្ដាប់គាថានិងព្រះបន្ទូលត្រាស់ហៅដូច្នោះ ក៏មានបីតិព្រឺព្រួចក្នុងចិត្តគិតថា អាត្មាទៅវិញតាមណាហ្ន៎? កំពុងតែគិតដូច្នេះ ក៏បានឈានក្នុងខណៈនោះភ្លាម ហើយហោះឡើងទៅលើអាកាសវេហាស៍នភាល័យ និងចំរើនគាថាដែលព្រះអង្គសំដែងប្រោស ក៏បានសម្រេចអរហត្តព្រមទាំងបដិសម្ភិទា ត្រឡប់ចុះមកថ្វាយបង្គំព្រះអង្គដោយសុវត្ថិភាព ។

សំដែងរឿងនេះដើម្បីឲ្យឃើញពិតប្រាកដថា វក្កលិព្រាហ្មណ៍ដែលបានសម្រេចអរហត្តព្រមទាំងបដិសម្ភិទានេះ ក៏ចកពីទស្សនានុត្តរិយៈដែលខ្លួនបានឃើញព្រះសាស្ដា; ព្រោះហេតុនោះ, ទស្សនានុត្តរិយៈចាត់ជាការសំខាន់មួយក្នុងព្រះពុទ្ធសាសនា ។ ចំណែកអនុត្តរិយៈដទៃទៀត មិនបានលើករឿងមកសំដែងពន្យល់ឲ្យសព្វគ្រប់នោះទេ, ព្រោះរឿងក្នុងអនុត្តរិយៈដទៃនោះៗ បើលោកអ្នកសង្កេតតែរឿងទស្សនានុត្តរិយៈដែលពោលមកហើយនោះ ក៏អាចយល់ដល់អនុត្តរិយៈនោះៗដែរ, ព្រោះរឿងទាំងនោះមានលំនាំស្រដៀងនឹងរឿងនោះដែរ; ហេតុនេះបើលោកអ្នកសិក្សាចង់ដឹងរឿងទាំងនោះឲ្យច្បាស់លាស់ គប្បីមើលក្នុងគម្ពីរ

មង្គលត្ថទីបនីភាគទី ១ ត្រង់ទុតិយគាថាថា "បដិរូបទេសវាសោ ច" ដូច្នេះជាដើមនោះចុះ ។

សប្បុរិសូបសំសេវៈ សេពគប់សប្បុរស គប្បីត្រូតមើលក្នុងពួកទី ១ នៃវុឌ្ឍិធម៌ ។

អត្តសម្មាបណិធិ ដំកល់ខ្លួនទុកប្រពៃ ; ពាក្យថា " ខ្លួន " នោះ ចិត្តនិងសរីរៈ ទាំងមូលហៅថា "ខ្លួន" , មែនពិតចិត្តនិងសរីរៈ ទាំងពីរនេះតែងស្ទុះទៅកាន់ភពតូចនិងភពធំ(១) ហើយដល់នូវសង្សារទុក្ខមានជាតិនិងជរាជាដើម ក៏លោកពោលថា «ខ្លួន»; ដែរ ពុំនោះសោតធម្មជាតិដែលទំពាស៊ីនូវសុខនិងទុក្ខ គឺថាសោយនូវសុខនិងទុក្ខហៅថា « ខ្លួន »

ដែលហៅថា « ដំកល់ខ្លួនដោយប្រពៃ » នោះ ដូចជាបុគ្គលខ្លះក្នុងលោក ពីដើមជាអ្នកមិនមានសីល គ្មានសទ្ធា , មានសេចក្ដីកំណាញ់ ហើយបានដំកល់ខ្លួនក្នុងសីល , ក្នុងសទ្ធា , កាត់បង់នូវមច្ឆរិយធម៌ គឺជាបុគ្គលមានសទ្ធានិងចាគៈ ; យ៉ាងនេះ ហៅថា «អត្តសម្មាបណិធិ» ការដំកល់ខ្លួនដោយប្រពៃ ,, ។

បុព្វេកតបុញ្ញតា ជាអ្នកបានធ្វើបុណ្យទុកពីក្នុងកាលមុននោះគឺបុគ្គលដែលបានសន្សំកុសលនិងធ្វើអធិការ ប្រារព្ធក្នុងព្រះពុទ្ធ ព្រះបច្ចេក-

១ ភពតូចបានដល់រូបភពនិងអរូបភព, ភពធំ បានដល់កាមភព ។

ពុទ្ធនិងព្រះខីណាស្រព ក្នុងជាតិដែលកន្លងទៅហើយ, យ៉ាងនេះហៅថាបុព្វេកតបុញ្ញតា ។ សមដូចរឿងពណ៌នាទៅនេះ ៖

អតីតេ ពារាណសិយំ ចត្តារោ ភាតរោ ព្រាហ្មណា តសិប្បព្ពជ្ជំ បព្វជិត្វា ។ល។ សោ មហន្តេន ពលេន បរិវុតោ នគរំ បវិសិត្វា អភិសេកំ ការេត្វា ទធិវាហនោ នាម រាជា អហោសីតិ ។

កាលកន្លងទៅហើយ មានព្រាហ្មណ៍ ៤ នាក់ជាបងប្អូននឹងគ្នាបាននាំគ្នាចេញទៅបួសជាឥសី ហើយធ្វើបណ្ណសាលានៅព្រៃហេមពាន្តរៀងៗខ្លួន ។ បណ្ដាឥសីទាំងនោះ ឥសីជាបងខំប្រឹងចំរើនធម៌មិនយូរប៉ុន្មានក៏ធ្វើកាលកិរិយាទៅកើតជាសក្កទេវរាជ ។ សក្កទេវរាជនោះ បានពិចារណាមើលបុញ្ញកម្មរបស់ខ្លួន លុះដឹងហើយក៏ថ្លែងភេទចុះមករកឥសីទាំងនោះដល់ហើយទើបចូលទៅរកតាបសជាច្បងថ្វាយបង្គំសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន , លោកម្ចាស់ត្រូវការវត្ថុអ្វីដែរឬ? ។ ចំណែកតាបសលោកកើតរោគសឿង ទើបពោលថា ចំរើនពរ , អាត្មាត្រូវការភ្លើង សក្កទេវរាជ ក៏ប្រគេនកាំបិតព្រាដល់តាបស ហើយប្រាប់ថា បពិត្រលោកម្ចាស់ដ៏ចំរើន , ប្រសិនបើលោកម្ចាស់ត្រូវការភ្លើង សូមលោកម្ចាស់ប្រើកាំបិតព្រានេះថា ចូរឯងទៅរកភ្លើងមក , បើលោកម្ចាស់ប្រើ

យ៉ាងនេះ កំបិតព្រានឹងទៅកាប់ខុសហើយបង្អាក់ភ្លើងតាមពាក្យដែលលោកប្រើនោះមិនខាន ។ សក្កទេវរាជ កាលបើប្រាប់សេចក្ដីនោះដល់តាបសហើយក៏ចូលទៅរកតាបសទី ២ ទៀត ហើយក្រាបបង្គំសួរដូចមុន ៗ តាបសប្រាប់ថា អាត្មាសព្វថ្ងៃនេះ កើតទុក្ខព្រោះតែក្បែរបណ្ណសាលារបស់អាត្មានេះមានផ្លូវដំរីទាំងតែងតែដើរទៅមក ហើយឈូសដីក្រហេងក្រហូងធ្វើឲ្យអាត្មាលុបដីនោះវិញរាល់ ៗ ថ្ងៃ ។ សក្កទេវរាជប្រគេនស្គរមួយដល់តាបសហើយប្រាប់ថា បពិត្រលោកម្ចាស់ដ៏ចំរើន , ពីពេលនេះទៅ បើកាលណាសត្វទាំងនោះមកបៀតបៀន , សូមលោកវាយស្គរនេះទៅ សត្វទាំងនោះវានឹងបោលទៅដោយឮសំឡេងស្គរនោះ , វានឹងត្រឡប់មកជាបរិវាររបស់លោកម្ចាស់វិញ, លុះសក្កទេវរាជប្រាប់រឿងសព្វគ្រប់ហើយ ក៏ចូលទៅរកតាបសទីបីហើយទូលសួរដូច្នោះទៀត។ តាបសនោះប្រាប់ថា អាត្មាត្រូវការដោយទធិ ដើម្បីយកមកធ្វើជាថ្នាំរម្ងាប់រោគស្លឿង ។ សក្កទេវរាជ ក៏ប្រគេនក្អមដាក់ទធិពេញមួយហើយប្រាប់ថា បពិតលោកម្ចាស់ដ៏ចំរើន , បើសិនណាលោកម្ចាស់ប្រាថ្នានឹងផ្អៀងសិតក្អមទធិនេះ , ទធិនេះនឹងក្រពប់ហូរហៀរទៅជាស្ទឹងហើយអាចកាន់យកវាឲ្យដល់លោកបាន , លុះសក្កទេវរាជ ប្រាប់ដូច្នោះហើយក៏ថ្វាយបង្គំលាជៀសចេញទៅ ចាប់ដើមតាំងពីថ្ងៃនោះមក តាបសទី ១ ក្ដី ទី ២ ក្ដី ទី ៣ ក្ដី ក៏ប្រើរបស់ទាំងនោះបានដូចប្រាថ្នាមែន។

ក្នុងគ្រានោះ មានសត្វជ្រូកមួយ ចូលទៅរកស៊ីក្នុងបុរាណគ្រាម (១) បានឃើញកែវមួយក៏ពាំហោះឡើងទៅលើអាកាស ដោយអានុភាពនៃកែវនោះ , លុះហោះបន្តិចទៅ បានឃើញកោះមួយនៅកណ្ដាលនៃសមុទ្រក៏ចុះទៅដេកក្រោមដើមឧទុម្ពរមួយដើម ថ្ងៃមួយជាខាងក្រោយមកជ្រូកនោះបានដាក់ដុំកែវមណីទៀបគល់ឈើហើយដេកលក់ទៅ ។ កាលនោះ មានបុរសម្នាក់នៅក្នុងដែនកាសី មិនដឹងជាគាត់មានទោសពៃរ៍ពៃជន្យអ្វីស្រាប់តែមាតាបិតាបណ្ដេញចេញពីផ្ទះ ហើយគាត់ក៏ចុះសំពៅទៅជាមួយនឹងនាយសំពៅ លុះទៅដល់ពាក់កណ្ដាលសមុទ្រ សំពៅបែកធ្លាយលិចទៅ ក៏ប្រឹងប្រវេប្រវាចាប់បានក្ដារមួយបន្ទះ ប្រឹងហែលតោងដរាបតែដល់កោះដែលជ្រូកនៅ ហើយដើរស្វែងរកភោជនាហារស្បៀងជីពជន្ម ស្រាប់តែឃើញកែវមណីក្រោមដើមឧទុម្ពរដែលជ្រូកលាក់ទុកនោះ ក៏ចូលសន្សឹម ៗ លួចយកកែវមណីកាន់ហោះឡើងឰដ៍អាកាសហើយអង្គុយលើមែកឧទុម្ពរគិតថា សត្វជ្រូកនេះមកតាមអាកាសដោយអានុភាពនៃកែវហើយមកនៅត្រង់កន្លែងនេះដឹង ? បើដូច្នោះ មានតែអញសម្លាប់យកសាច់វាស៊ី រួចសឹមទៅទើបគួរ! ហើយកាច់មែកឧទុម្ពរចោលជ្រូកឲ្យភ្ញាក់ឡើង ។ ជ្រូកនោះកាលបើភ្ញាក់ឡើងមិនឃើញកែវដូច្នោះក៏បោលស្ទុះស្ទារទៅខាងនេះបន្តិចខាងនោះបន្តិច បុរសនោះក៏សើច

១ – បុរាណគ្រាម គឺភូមិចាស់ ។

ក្អកក្អាយលើដើមឧទុម្ពរដោយជ្រូកនាំផ្លូវរកកែវមិនឃើញ ។ ចំណែកជ្រូកបានឮសម្លេងមនុស្សស្រែក ក៏ងើបមើលទៅលើបានឃើញបុរសនោះដាក់ហើយ ក៏បោលបុកក្បាលនឹងគល់ឧទុម្ពរស្លាប់ទៅ ។ បុរសនោះកាលបើឃើញជ្រូកស្លាប់ហើយ ក៏ចុះចាកដើមឧទុម្ពរមកបង្កាត់ភ្លើងចំអិនសាច់ជ្រូកបរិភោគដរាបដល់ឆ្អែត ហើយកាន់កែវហោះឡើងទៅលើអាកាស បានឃើញអាស្រមរបស់ឥសីទាំងនោះដែលតាំងនៅលើភ្នំហេមពាន្ត ក៏ចុះមកក្រាបបង្គំតាបសជាច្បងសុំសំណាក់អាស្រ័យនៅទីនោះ ។ បុរសនោះនៅបានពីរបីថ្ងៃ ក៏សង្កេតឃើញកាំបិតព្រាដែលមានអានុភាពអាចប្រើការបានគ្រប់យ៉ាង ក៏ចូលទៅនិយាយសុំប្តូរនឹងតាបសថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ដូរកាំបិតព្រានិងកែវរបស់ខ្ញុំឬ ? ; ចំណែកឥសីចង់បានកែវមណីដើម្បីនឹងហោះលេងឰដ៏អាកាស ក៏ព្រមទទួលដូរ ។ បុរសនោះ បានយកកាំបិតព្រាមកពីរបីថ្ងៃ ក៏ប្រើកាំបិតព្រាថា ចូរឯងទៅកាត់ក្បាលឥសីឲ្យស្លាប់ហើយយកកែវមកឲ្យអញវិញ ។ កាំបិតព្រានោះ ក៏ទៅតាមបង្គាប់ ។ បុរសនោះកាលបើបានកែវមកវិញ ក៏លាក់កាំបិតព្រាក្នុងទីកំបាំងហើយចូលទៅរកឥសីទីពីរ សុំកន្លែងនៅបានពីរបីថ្ងៃ ស្រាប់តែឃើញអានុភាពស្គររបស់ឥសីនោះក៏សូមដូរនឹងកែវមណីរបស់ខ្លួន ទើបកាំបិតព្រាឲ្យទៅកាត់ក្បាលឥសីទីពីរនោះ សម្លាប់ចោលទៀត ហើយចូលទៅរកឥសីទីបីនិយាយសុំដូរ ក្អមទធិនឹងកែវ-

របស់ខ្លួនមានហើយ ទើបប្រើកាំបិតព្រាឲ្យទៅកាត់ក្បាលឥសីនោះសម្លាប់ចោលទៀត ; កាលបើបុរសនោះសម្លាប់ឥសីអស់ហើយក៏ប្រមូលយករបស់ទាំងនោះហើយកាន់កែវហោះឡើងឰដ៏អាកាស ទៅដល់ក្រុងពារាណសី ហើយផ្ញើសារទៅព្រះបាទពារាណសីថា អ្នកឯងចង់ច្បាំងឬមួយព្រមឲ្យរាជយើង ? ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ដំណឹងនោះក៏ប្រមូលអស់មុខមន្ត្រីឲ្យរៀបទ័ពចេញទៅដោយព្រះចិន្តាថា អញនឹងចាប់ចោរ ។ បុរសនោះកាលបើឃើញពលរបស់ព្រះបាទពារាណសីមកដល់ហើយ ក៏វាយស្គរ ; ចំណែកពួកពលសេនាយោធាទាំងនោះក៏ចោមរោមព័ទ្ធបុរសនោះ ។ គាត់ក៏បាច់ទាញក្អមទធិផ្កាប់, ទធិនោះក៏ហៀរហូរទៅជាស្ទឹង លិចពួកពលទាំងអស់នៅត្រឹម ២ ក, ហើយគាត់ប្រើកាំបិតព្រាឲ្យកាត់ក្បាលស្ដេចសម្លាប់ ។ ក្នុងកាលនោះ សូម្បីតែយោធាម្នាក់ក៏មិនអាចលើកឡើងនូវអាវុធបាន ។ បុរសនោះមានពលយ៉ាងច្រើនជាបរិវារហែហមចូលទៅនគរហើយអភិសេកជាស្ដេច បានឈ្មោះថា "ទធិវាហន" ដូច្នេះឯង ។

សំដែងរឿងនេះ ដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ថា បុគ្គលដែលគ្មានបុណ្យ បើទុកណាជាបានវត្ថុដ៏បរិបូណ៌ដោយអានុភាព ក៏គង់តែដល់នូវសេចក្ដីវិនាសហិនហោចទៅ ព្រោះតែខ្លួនគ្មានបុណ្យ , ដូចជាតាបសទាំងនោះឯង, លុះតែបុគ្គលដែលមានបុណ្យទើបទទួលយកនូវសិរី

ដែលជនដទៃឲ្យហើយមិនមានគ្រោះថ្នាក់ ដូចជាទធិវាហនរាជនោះឯង, ព្រោះហេតុនោះ បុគ្គលដែលមានបុណ្យហើយ ចាត់ជាបុគ្គលមួយក្នុងព្រះពុទ្ធសាសនា ។

ការនៅក្នុងប្រទេសដែលមានសប្បុរសដូច្នេះ ចាត់ជាមង្គលនាំឲ្យកើតសេចក្ដីសុខចំរើនគ្រប់យ៉ាង ព្រោះជាហេតុបានសមាគមសេពគប់ជាមួយនឹងសប្បុរស ការសេពគប់រាប់រកនូវបុគ្គលដូច្នេះ រមែងជឿស្ដាប់ពាក្យប្រដៅរបស់លោក ការដំកល់ខ្លួនទុកឲ្យល្អ ក្នុងផ្លូវដែលត្រូវប្រកបដោយសុចរិតធម៌ និងការគ្រប់គ្រងរក្សាចិត្តរបស់ខ្លួនរមែងបានសេចក្ដីសុខចំរើនគ្រប់យ៉ាង, ការបំពេញកុសលសុចរិតក្នុងភពដែលកន្លងទៅហើយឈ្មោះថា ភាពជាអ្នកបានធ្វើបុណ្យទុកក្នុងកាលមុន ។

ធម៌ទាំង ៤ ប្រការនេះ កាលបើមានគ្រប់គ្រាន់បរិបូណ៌ក្នុងសន្ដានបុគ្គលណាហើយ រមែងធ្វើបុគ្គលនោះ ឲ្យដល់នូវសេចក្ដីចំរើនតាមវត្ថុបំណងបីដូចជារថដែលនាំទៅកាន់ទីដែលត្រូវការបានដូច្នោះឯង ។

អគតិ ៤ យ៉ាង

១– ឆន្ទាគតិ លំអៀងព្រោះស្រឡាញ់;

២– ទោសាគតិ លំអៀងព្រោះស្អប់;

៣– មោហាគតិ លំអៀងព្រោះល្ងង់,

៤– ភយាគតិ លំអៀងព្រោះខ្លាច ។

អគតិ ៤ យ៉ាង នេះ មិនគួរប្រព្រឹត្តឡើយ ។

អធិប្បាយថា :

ការប្រព្រឹត្តឲ្យឃ្លៀងឃ្លាតចាកធម៌ គឺប្រព្រឹត្តមិនត្រង់តាមសេចក្ដីពិតហៅថា "អគតិ,, , តាមអដ្ឋកថានៃធម្មបទ លោកពណ៌នាទុកជាតួយ៉ាងដូច្នេះថា អ្នកវិនិច្ឆ័យនូវក្ដី គឺកាត់ក្ដី បើតាំងនៅក្នុងឆន្ទាគតិអាស្រ័យសេចក្ដីស្រឡាញ់ហើយ រមែងនិយាយខុសច្បាប់មិនខាន តែងវិនិច្ឆ័យឲ្យញាតិមិត្រ របស់អ្នកដែលមានសេចក្ដីខុសឆ្គង ដែលគួរឲ្យចាញ់ត្រឡប់ទៅជាឈ្នះវិញបាន ។ បើតាំងនៅក្នុងទោសាគតិអាស្រ័យសេចក្ដីស្អប់ រមែងវិនិច្ឆ័យឲ្យមនុស្សដែលមានពៀរដល់គ្នាដែលជាមនុស្សមានសេចក្ដីខុស ដែលគួរឲ្យចាញ់ឲ្យត្រឡប់ទៅជាឈ្នះវិញបាន ។ បើតាំងនៅក្នុងមោហាគតិ អាស្រ័យសេចក្ដីល្ងង់ទទួលសំណូកគេក្នុងវេលាកាត់សេចក្ដីធ្វើជាឡប់ឡុបលោយរាយ រមែងនិយាយបង្កាច់ថា មនុស្សនេះឈ្នះ មនុស្សនេះចាញ់ ។ បើតាំងនៅក្នុងភយាគតិអាស្រ័យសេចក្ដីខ្លាច រមែងវិនិច្ឆ័យឲ្យមនុស្សដែលមានយសស័ក្តិដែលមានសេចក្ដីខុសគួរឲ្យចាញ់ ត្រឡប់ទៅជាឈ្នះវិញបាន ; ការប្រព្រឹត្តិដូច្នេះហៅថាប្រព្រឹត្តលំអៀងធម៌ , សមដូចរឿងវិនិច្ឆ័យមហាមត្ត(១) មានសំដែងថា

១ វិនិច្ឆ័យមហាមត្ត គឺចាងហ្វាងអ្នកកាត់ក្ដី ។

កាលព្រះសាស្តាជាម្ចាស់ទ្រង់គង់នៅវត្តជេតពន , ក្នុងថ្ងៃមួយ មានភិក្ខុជាច្រើនរូបចូលទៅបិណ្ឌបាតក្នុងឧត្តរគ្រាមនៃក្រុងសាវត្ថី, កាលសើបិណ្ឌបាតល្មមញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅបានហើយ ក៏ត្រឡប់និមន្តមកវិញតាមផ្លូវដែលតាំងនៅពាក់កណ្តាលនគរ ។ កាលភិក្ខុទាំងនោះកំពុងនិមន្តដល់ពាក់កណ្តាលនគរ , ដួនជាមានភ្លៀងបង្អុរចុះមកក្នុងខណៈនោះឯង ។ ឯភិក្ខុទាំងនោះមិនដឹងទៅរកកន្លែងជ្រកកោនត្រង់ណាឲ្យគួរសម , ស្រាប់តែឃើញសាលាសម្រាប់វិនិច្ឆ័យក្តីមួយដែលតាំងនៅក្នុងទីចំពោះមុខ ក៏នាំគ្នាចូលជ្រកកោនក្នុងទីនោះ បានឃើញវិនិច្ឆ័យមហាមត្តទាំងឡាយ កំពុងតែអង្គុយវិនិច្ឆ័យក្តីឲ្យជនទាំងឡាយ មហាមត្តទាំងនោះតែងធ្វើនូវជនជាម្ចាស់ មិនឲ្យជាម្ចាស់ហើយវិនិច្ឆ័យក្តី, លុះឃើញដូច្នោះហើយនាំគ្នាគិតថា ឱហ្ន៎ ! វិនិច្ឆ័យមហាមត្តទាំងនេះជាអធម្មិកបុគ្គលតើ ! កាលពីដើម យើងទាំងអស់មានសញ្ញាថា វិនិច្ឆ័យមហាមត្តទាំងនេះជាធម្មិកបុគ្គល ឥឡូវបែរជាខុសសញ្ញាវិញតើ ! លុះភ្លៀងរាំងហើយ ភិក្ខុទាំងនោះនាំគ្នាយករឿងនេះទៅក្រាបបង្គំទូលព្រះសាស្តា ។ ព្រះត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកវិនិច្ឆ័យនូវក្តី បើលុះក្នុងអំណាចនៃអគតិមានឆន្ទាជាអគតិជាដើម ហើយរមែងកាត់ក្តីដោយរួសរាន់រួចធ្វើជនជាម្ចាស់មិនឲ្យជាម្ចាស់វិញ បុគ្គលនោះឯងមិនឈ្មោះថា ឋិតនៅក្នុងធម៌ទេ ;

លុះតែ បុគ្គលអ្នកវិនិច្ឆ័យក្តីណាមួយរមិលមើលទោសនៃជននោះ ៗ ហើយកាត់ក្តីដោយមិនប្រញាប់ប្រញាល់ គឺកាត់ឲ្យត្រូវតាមគួរដល់កំហុសនោះ ៗ បុគ្គលនោះឯងទើបឈ្មោះថា ឋិតនៅក្នុងធម៌មែន; ហើយទ្រង់ត្រាស់ដោយព្រះពុទ្ធដីកាដូច្នេះថា ៖

ន តេន ហោតិ ធម្មដ្ឋោ យេនត្ថំ សហសា នយេ
យោ ច អត្ថំ អនត្ថញ្ច ឧភោ និច្ឆេយ្យ បណ្ឌិតោ
អសាហសេន ធម្មេន សមេន នយតី បរេ
ធម្មស្ស គុត្តោ មេធាវី ធម្មដ្ឋោតិ បវុច្ចតិ ។

បុគ្គលដែលកាត់សេចក្តីដោយរហ័ស ដោយហេតុឯណា នឹងបានឈ្មោះថា ជាអ្នកឋិតនៅក្នុងធម៌ ដោយហេតុនោះក៏ទេ , ចំណែកអ្នកឯណាដែលជាបណ្ឌិត កាត់សេចក្តីទាំងពីរ គឺសេចក្តីពិត នឹងសេចក្តីវៀចដោយត្រឹមត្រូវ ចេះពន្យល់ពួកជនដទៃដោយសមគួរ (ដល់មោសានុទោស) មិនប្រញាប់រួសរាន់ពេក អ្នកនោះឈ្មោះថា ជាអ្នកមានប្រាជ្ញាចេះគ្រប់គ្រងធម៌ ទើបតថាគតហៅថា អ្នកឋិតនៅក្នុងធម៌មែន ។

សំដែងរឿងនេះ ដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ថា បុគ្គលអ្នក

វិនិច្ឆ័យក្តី បើលុះក្នុងអំណាចអគតិទាំងឡាយមានឆន្ទាគតិជាដើម ; រមែងកាត់ក្តីដូចរឿងដែលសំដែងមកនោះឯង ; ចំណែកអ្នកដែលវៀរចាកធម៌ ៤ ប្រការ ដូចពោលមកហើយនោះ តែងកាត់សេចក្តីដោយសមគួរដល់សេចក្តីសុខ រក្សាធម៌ជាធំ បរិបូណ៌ដោយបញ្ញា ដំកល់នៅក្នុងធម៌ ឈ្មោះថាប្រព្រឹត្តយុត្តិធម៌មែន ។

អន្តរាយរបស់ភិក្ខុសាមណេរបួសថ្មី ៤ យ៉ាង

១ – អត់ធន់ចំពោះពាក្យទូន្មានមិនបាន ខ្ជិល ធ្វើតាម ;

២ – ជាមនុស្សឃើញតែការបរិភោគជាប្រមាណ អត់ធន់សេចក្តីស្រេកឃ្លានមិនបាន ;

៣ – ត្រេកអរក្នុងកាមគុណ ចង់បានសេចក្តីសុខលើសលប់ឡើងទៅ ;

៤ – ស្រឡាញ់ស្រីភាព ។

ភិក្ខុសាមណេរប្រាថ្នាសេចក្តីចំរើនដល់ គួរប្រយ័ត្នកុំឲ្យអន្តរាយ ៤ យ៉ាងនេះមកញាំញីបាន ។

អធិប្បាយថា :

ធម្មតាបុថុជ្ជន ដែលមានកិលេសត្រាំនៅក្នុងខន្ធសន្តានច្រើនមានសេចក្តីប្រព្រឹត្តខុសផ្លូវជានិច្ច ត្រូវអាស្រ័យការអប់រំ ហើយហាមប្រាមសេចក្តីអាក្រក់ជានិច្ច ទើបប្រព្រឹត្តឲ្យត្រឹមត្រូវតាមគន្លងធម៌បាន ។

បើភិក្ខុសាមណេរដែលបួសថ្មី ជាទំនាស់ដល់កិច្ចដែលត្រូវអត់ធន់ចំពោះពាក្យប្រៀនប្រដៅដោយពិត ព្រោះឃើញដល់សេចក្តីលំបាក, មិនមានសេចក្តីព្យាយាម ខ្ជិលច្រអូស បើគ្មានសេចក្តីព្យាយាមទេនឹងតាំងនៅក្នុងភេទព្រហ្មចរិយៈ មិនបាន មិនមានសេចក្តីចំរើនដល់ព្រះពុទ្ធសាសនា ទីបំផុតត្រូវលាសិក្ខាបទ វិលត្រឡប់មកកាន់ហីនភេទវិញ ទើបឈ្មោះថា អន្តរាយ ។

អ្នកបួសត្រូវដេកក្នុងវេលាដែលបរិភោគឬឆាន់នូវអាហារតាមកំណត់ដែលព្រះអង្គទ្រង់បញ្ញត្តទុក មិនត្រូវធ្វើសេចក្តីក្រវល់ក្រវាយរនះរនាតក្នុងការបរិភោគហួសហេតុ អត់ទ្រាំសេចក្តីស្រេកឃ្លានមិនបាន មិនត្រូវធ្វើការខ្វល់ខ្វាយឲ្យទាល់តែដល់ថ្នាក់ប្រព្រឹត្តអនាចារ ខុសចាកច្បាប់ព្រះវិន័យឡើយ ។

អ្នកបួសកាលបើមិនធ្វើចិត្តឲ្យភ្លើតភ្លើនក្នុងកាមគុណគឺរូប, សំឡេង ក្លិន, រស, សម្ផស្ស, មានសេចក្តីខ្ពប្រាថ្នាចង់បានសេចក្តីសុខលើសលប់ឡើងទៅ ព្រមទាំងមិនស្រឡាញ់ស្រី បើប្រតិបត្តិបានដូច្នេះក៏នឹងមានសេចក្តីចំរើនលូតលាស់ដុះដាលក្នុងព្រះពុទ្ធសាសនាទៅបាន ព្រហ្មចរិយធម៌នឹងឋិតនៅបានយូរអង្វែង ជាការប្រតិបត្តិត្រឹមត្រូវតាមព្រះពុទ្ធបំណងបើត្រឡប់ទៅជា ប្រតិបត្តិផ្ទុយគ្នាទៅវិញ ក៏នឹងក្លាយទៅជាអន្តរាយតែម្យ៉ាង ។

ហេតុនេះ ភិក្ខុសាមណេរដែលទើបបួសថ្មី ត្រូវប្រុងប្រយ័ត្នកុំឲ្យអន្តរាយ ៤ យ៉ាងនេះចូលមកញាំញីគ្របសង្កត់បាន ក្នុងទីនេះលោកមិនបានពោលដល់ភិក្ខុសាមណេរដែលបួសចាស់ទេ ព្រោះភិក្ខុសាមណេរចាស់ ៗ លោកធ្លាប់ប្រុងប្រយ័ត្នតាំងពីខ្លួនលោកនៅជាភិក្ខុសាមណេរមកហើយម្លេះ ។

បធាន « ព្យាយាម » ៤ យ៉ាង

១ – សំវរប្បធាន : ព្យាយាមប្រយ័ត្នមិនឲ្យបាបកើតឡើងក្នុងសន្តាន ;

២ – បហានប្បធាន : ព្យាយាមលះបាបដែលកើតឡើងហើយ ,

៣ – ភាវនាបធាន : ព្យាយាមញុំាងកុសលដែលកើតឡើងក្នុងសន្តាន ;

៤ – អនុរក្ខនាបធាន : ព្យាយាមរក្សាកុសលដែលកើតឡើងហើយមិនឲ្យសាបសូន្យទៅវិញ ។

ព្យាយាម ៤ យ៉ាងនេះជាធម៌ប្រពៃ គួរប្រកបឲ្យកើតមានក្នុងសន្តាន ។

អធិប្បាយថា :

សេចក្តីព្យាយាមមាន ២ គឺព្យាយាមប្រព្រឹត្តទៅក្នុងផ្លូវកាយ ១ , ប្រព្រឹត្តទៅក្នុងផ្លូវចិត្ត ១ , តែសេចក្តីព្យាយាមក្នុងទីនេះ បំណងយក

សេចក្តីព្យាយាមតាមផ្លូវចិត្ត , ការដែលមិនភ្លេចខ្លួនមានស្មារតីប្រុងប្រយ័ត្នគ្រប់ខណៈ មិនឲ្យឱកាសដល់សេចក្តីអាក្រក់ ឬមិនបណ្តាលឲ្យសេចក្តីអាក្រក់កើតឡើង មានសេចក្តីចាស់ក្លា , មិនគិតដល់លំបាកដោយហេតុណាមួយ យ៉ាងនេះហៅថា សំវរប្បធាន : ។

បើមានសេចក្តីភាំងភ្លាត់ក្នុងពេលខ្លះម្តងមួយកាលព្រោះខ្លួនមានសតិមិនបរិបូណ៌ សេចក្តីអាក្រក់បានឱកាសកើតឡើងក្នុងសន្តានបានហើយ ក៏មិនព្រងើយកន្តើយបណ្តោយឲ្យសេចក្តីអាក្រក់នោះកើតឡើង ហួសកាលនោះទេ , ក៏តាំងសេចក្តីព្យាយាមដើម្បីកំចាត់បង់នូវអកុសលដែលកើតឡើងនោះឲ្យឃ្លាតឆ្ងាយពីសន្តានយ៉ាងនេះហៅថា បហានប្បធាន : ។

ការព្យាយាមអប់រំបំពេញកុសល គឺសេចក្តីល្អដទៃ ៗ ឲ្យមានច្រើនក្នុងសន្តានដោយឧបាយផ្សេង ៗ ស្រេចហើយតែកុសលកើតមានឡើងដោយឧបាយយ៉ាងណា ក៏ខំប្រឹងព្យាយាមដោយឧបាយយ៉ាងនោះយ៉ាងនេះ ហៅថា ភាវនាបធាន ។

ការព្យាយាមរក្សាកុសលដែលខ្លួនបានអប់រំឲ្យកើតក្នុងសន្តានហើយ ក៏ខំប្រឹងព្យាយាមមិនឲ្យសាបសូន្យទៅវិញ ហៅថា អនុរក្ខនាបធាន : ។

សេចក្តីព្យាយាមទាំង ៤ ប្រការនេះ កាលបើបុគ្គលបានបំពេញឲ្យបរិបូណ៌ក្នុងសន្តានហើយ រមែងមានសេចក្តីសុខកាយសប្បាយចិត្តរុងរឿងក្នុងព្រះពុទ្ធសាសនាអស់កាលជាអង្វែងមិនខាន ។

អធិដ្ឋាន «ធម៌ដែលគួរតាំងទុកក្នុងចិត្ត» ៤ យ៉ាង

១- បញ្ញា : ដឹងរបស់ដែលគួរដឹង ;

២- សច្ចៈ: សេចក្តីពិតក្នុងចិត្ត គឺតាំងចិត្តនឹងធ្វើអ្វី ក៏ធ្វើពិត :

៣- ចាគៈ: លះរបស់ដែលជាសត្រូវដល់សេចក្តីពិតក្នុងចិត្ត ;

៤- ឧបសមៈ: ស្ងប់ចិត្តចាករបស់ដែលជាសត្រូវ ចំពោះសេចក្តីស្ងប់ ។

អធិប្បាយថា :

សេចក្តីដឹងរបស់ដែលគួរដឹងនោះ , បានសេចក្តីថា សិល្បសាស្ត្រវិជ្ជាណាដែលប្រាសចាកទោសគ្រប់យ៉ាង , ព្រមទាំងបណ្តាលឲ្យកើតប្រយោជន៍ដល់អ្នកដឹង ហើយប្រតិបត្តិតាមសិល្បសាស្ត្រវិជ្ជានោះ រមែងដឹងក្នុងបញ្ចក្ខន្ធ គឺរូប , វេទនា , សញ្ញា , សង្ខារ , វិញ្ញាណ រហូតដល់ការដឹងនូវអរិយសច្ច ៤ បានដ៏សមគួរដល់បញ្ញា ។ ឯបញ្ញាមានពីរយ៉ាងគឺលោកិយបញ្ញា ដឹងក្នុងរបស់ដែលជាវិស័យរបស់លោក ១ , លោកុត្តរបញ្ញា , ដឹងក្នុងរបស់ដែលផុតចាកវិស័យរបស់លោក ១ ។ បញ្ញាគឺសេចក្តីដឹងនេះ លោកចាត់ជាអធិដ្ឋានធម៌ ។

សច្ចៈ: សេចក្តីតាំងចិត្តពិតគឺកាលប្រើបញ្ញាពិចារណាឃើញរបស់អ្វី ដែលជាប្រយោជន៍ដល់ខ្លួនហើយមានសេចក្តីតាំងចិត្តមុតមាំមិនធុញ

ទ្រាន់នឿយណាយថយក្រោយ ដើម្បីប្រព្រឹត្តឲ្យបានសម្រេចផលដែលខ្លួនប្រាថ្នាមិនលះចោល ប្រឹងប្រែងស៊ូលះបង់សាច់ឈាមប្តូរយកផលប្រយោជន៍ដែលខ្លួនត្រូវការ សច្ចៈនេះលោកចាត់ជា អធិដ្ឋានធម៌ ។

ការលះនូវនីវរណធម៌ខ្លះ ដែលមានលក្ខណៈសង្ស័យក៏ដោយ , ការព្យាយាមផុតចំផ្លាញចោលនូវកិលេសាសវៈដទៃ ដែលជាសឹកសត្រូវដល់សេចក្តីពិតក្នុងចិត្តក៏ដោយ ការព្យាយាមលះរបស់ដែលជាសឹកសត្រូវដល់សេចក្តីពិតក្នុងចិត្តនោះ ឈ្មោះថា ចាគៈ ៗ នេះចាត់ជាអធិដ្ឋានធម៌ ។

កិលេសាសវៈណាដែលធ្វើចិត្តឲ្យរវើរវាយក្តៅក្រហាយ ក្រវល់ក្រវាយមានប្រការផ្សេង ៗ មិនឲ្យចិត្តស្ងប់រម្ងាប់បាន ការព្យាយាមធ្វើចិត្តឲ្យស្ងប់រម្ងាប់ចាករបស់ដែលជាសត្រូវដល់សេចក្តីស្ងប់ ដោយឧបាយដ៏សមគួរ ឈ្មោះថា ឧបសមៈ ៗ នេះ ចាត់ជាអធិដ្ឋានធម៌ ។

ឥទ្ធិបាទ «គុណធម៌ជាជំហានឱ្យសម្រេចប្រយោជន៍» ៤ យ៉ាង

១- ឆន្ទៈ: ចូលចិត្តស្រឡាញ់ក្នុងកិច្ចការនោះ ៗ ;

២- វីរិយៈ; ព្យាយាមប្រកបកិច្ចការនោះ ៗ ;

៣- ចិត្តៈ: យកចិត្តទុកដាក់ក្នុងកិច្ចការនោះ ៗ មិនដាក់ធុរៈ ;

៤- វិមំសា ឧស្សាហ៍ត្រិះរិះពិចារណា រកហេតុផលក្នុងកិច្ចការនោះ ៗ ។

ធម៌, ៤ យ៉ាងនេះ មានបរិបូណ៌ក្នុងសន្តានបុគ្គលណា អាចដឹកនាំ

បុគ្គលនោះឲ្យសម្រេចតាមសេចក្ដីប្រាថ្នាដែលមិនហួសវិស័យ ។

អធិប្បាយថា :

បុគ្គលត្រូវដំកល់នូវ : ឥទ្ធិបាទធម៌ទាំង ៤ យ៉ាងនេះ ទើបសម្រេចប្រយោជន៍បាន , បើខ្វះខាតអង្គណាមួយហើយ ក៏មិនអាចសម្រេចផលប្រយោជន៍តាមត្រូវការបានឡើយ ដូចជាបុគ្គលមានសេចក្ដីពេញនោះក្នុងរបស់ណាមួយយ៉ាងវិសេស តែមិនបានចុះដៃធ្វើ មិនបានប្រព្រឹត្តដើម្បីឲ្យបានសម្រេចរបស់វិសេសនោះទេ , តើនឹងមានផលប្រយោជន៍អ្វី? ការសិក្សាសូត្ររៀននឹងសម្រេចប្រយោជន៍ សមតាមបំណងក៏ដោយ, ដំណើរការចិញ្ចឹមជីវិតយ៉ាងណានីមួយ ដើម្បីជួបប្រទះជោគវាសនាគឺការបានទ្រព្យសម្បត្តិក៏ដោយ វត្ថុទាំងនេះក៏ព្រោះតែមនុស្សទាំងនោះដំកល់ខ្លួននៅក្នុងឥទ្ធិបាទទាំង ៤ នេះឯង ។

ម្យ៉ាងទៀត បុគ្គលដែលបរិបូណ៌ដោយធម៌ទាំង៤ ប្រការនេះហើយ ប្រាថ្នានិព្វានសម្បត្តិ ក៏អាចសម្រេចតាមសេចក្ដីបំណងបានពុំខាន , សូម្បីព្រះពុទ្ធជាម្ចាស់ក៏ទ្រង់ត្រាស់សំដែងចំពោះព្រះអានន្ទថា “ ម្នាលអានន្ទ ! ឥទ្ធិបាទធម៌ទាំង ៤ ប្រការនេះ កាលបើបុគ្គលអប់រំចំរើនឲ្យច្រើនក្នុងសន្តានហើយ , មានសេចក្ដីប្រាថ្នានឹងឲ្យអាយុសង្ខារស្ថិតនៅអស់កប្ប(១) មួយ ក៏នឹងសម្រេចតាមបំណងមិនខាន ! ”, ធម៌នេះឯងជា

១ – សំដៅយកអាយុកប្ប គឺអាយុក្ខ័យរបស់មនុស្ស ។

គ្រឿងចង្អុលបង្ហាញឲ្យឃើញច្បាស់ថា ឥទ្ធិបាទធម៌ទាំង ៤ ប្រការនេះមានអំណាចអាចឲ្យអ្នកដែលបានបំពេញជួបប្រទះនឹងវត្ថុ បំណងដែលខ្លួនប៉ុនប៉ងទុកមក មិនឲ្យហួសវិស័យបាន ។

គួរធ្វើសេចក្ដីមិនប្រមាទក្នុងទី ៤ ស្ថាន

១ - កាយទុច្ចរិតប្បហានៈ ក្នុងការលះកាយទុច្ចរិត ប្រព្រឹត្តកាយសុចរិត ;

២– វចីទុច្ចរិតប្បហានៈ ក្នុងការលះវចីទុច្ចរិត ប្រព្រឹត្តវចីសុចរិត ,

៣– មនោទុច្ចរិតប្បហានៈ ក្នុងការលះមនោទុច្ចរិត ប្រព្រឹត្តមនោសុចរិត ;

៤– មិច្ឆាទិដ្ឋិប្បហាន ក្នុងការលះសេចក្ដីឃើញខុសធ្វើសេចក្ដីឃើញឲ្យត្រូវ ។

អធិប្បាយថា

សេចក្ដីមិនប្រមាទ បានដល់សេចក្ដីមិនស្រវឹងវង្វេងក្នុងលាភ, យស, សរសើរ , សុខ , វ័យ , សេចក្ដីមិនមានរោគនឹងជីវិត មានសតិប្រចាំនៅគ្រប់ ៗ ឥរិយាបថ មិនមានភ្លេចភ្លាំង ក្នុងការលះកាយទុច្ចរិតវចីទុច្ចរិត មនោទុច្ចរិតនិងសេចក្ដីយល់ខុស , ការលះសេចក្ដីអាក្រក់បាន

ហើយគប្បីប្រឹងព្យាយាម បំពេញសេចក្តីល្អ គឺកាយសុចរិត វចីសុចរិត មនោសុចរិតនឹងសេចក្តីយល់ត្រូវតាមគន្លងធម៌ ។

មួយទៀត គួរប្រយ័ត្នចិត្តកុំឱ្យវង្វេងក្នុងទី ៤ ស្ថាន

១– រជនីយ: កុំត្រេកក្នុងអារម្មណ៍ដែលនាំឲ្យមានតម្រេក ;

២– ទោសនីយ: កុំខឹងក្នុងអារម្មណ៍ដែលនាំឲ្យខឹង ;

៣– មោហនីយ: កុំវង្វេងក្នុងអារម្មណ៍ដែលនាំឲ្យវង្វេង ;

៤– មទនីយ: កុំស្រវឹងក្នុងអារម្មណ៍ដែលនាំឲ្យស្រវឹង ។

អធិប្បាយថា :

អារម្មណ៍ដែលជាទីតាំងនៃសេចក្តីតម្រេកនោះបានដល់រូប, សំឡេង, ក្លិន, រស, សម្ផស្ស, ដែលជាទីស្រឡាញ់ ជាទីប្រាថ្នា ជាទីពេញចិត្ត ។ អារម្មណ៍ដែលជាទីតាំងនៃសេចក្តីក្រោធខឹងនោះក៏បានដល់កាមគុណ ៥ គឺ រូប, សំឡេង, ក្លិន, រស, សម្ផស្ស នេះដែរ ; តែជាអារម្មណ៍ មិនជាទីស្រឡាញ់ មិនជាទីប្រាថ្នា មិនជាទីពេញចិត្ត ។

កាមសុខ គឺសុខដែលកើតអំពីការសេពកាម ឈ្មោះថាអារម្មណ៍ជាទីតាំងនៃសេចក្តីវង្វេង ។ លាភ, យស, សរសើរ, សុខ, ឈ្មោះថាអារម្មណ៍ជាទីតាំងនៃសេចក្តីស្រវឹង ។ ការរក្សាប្រយ័ត្ន ក៏គឺការដំកល់ស្មារតី ឃាត់ឃាំងរាំងរាមិនឲ្យចិត្តរវើរវាយទៅតាមអារម្មណ៍នោះៗ

បញ្ញាពិចារណាឲ្យឃើញដល់ត្រៃលក្ខណ: នឹងប្រភេទនៃអារម្មណ៍ តាមសេចក្តីពិត មិនបណ្តោយចិត្តឲ្យកើតសេចក្តីតម្រេក, ក្រោធខឹង, វង្វេងនឹងស្រវឹងនោះឡើយ ។

បារិសុទ្ធិសីល ៤ យ៉ាង

១ – បាតិមោក្ខសំវរសីល សីលគឺការសង្រួមក្នុងព្រះបាតិមោក្ខ គឺវៀរចាកទោសដែលទ្រង់ហាម ហើយធ្វើតាមទ្វារដែលទ្រង់អនុញ្ញាតឲ្យមក ;

២ – ឥន្ទ្រិយសំវរសីល សីលគឺការសង្រួមឥន្ទ្រិយទាំង ៦ គឺ ភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ, ចិត្ត, មិនឲ្យស្អប់ មិនឲ្យស្រឡាញ់ ក្នុងវេលាឃើញរូប, ស្តាប់សំឡេង, ធុំក្លិន, ស្រូបរស, កាយពាល់ត្រូវ, ដឹងធម្មារម្មណ៍ដោយចិត្ត ;

៣ – អាជីវបារិសុទ្ធិសីល សីលដែលបរិសុទ្ធដោយការចិញ្ចឹមជីវិត វៀរចាកបាបធម៌ ៥ នឹងអនេសន: ២១ ;

៤ – បច្ចយសន្និស្សិតសីល សីលដែលអាស្រ័យដោយបច្ច័យ, ឯបច្ច័យមាន ៤ គឺ ចីវរប្បច្ច័យ ១, បិណ្ឌបាតប្បច្ច័យ ១, សេនាសនប្បច្ច័យ ១, គិលានភេសជ្ជប្បច្ច័យ ១, មិនបរិភោគដោយតណ្ហា ។

អធិប្បាយថា ៖

ការមិនប្រព្រឹត្តកន្លងព្រះវិន័យ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តិទុកក្នុងបាតិមោក្ខតាំងពីបារាជិក ៤ រហូតដល់សេខិយវត្ត. ៧៥ ហៅថា សង្រួមក្នុងព្រះបាតិមោក្ខ ។

មួយទៀត ការមិនប្រព្រឹត្តខុសដូចជាវត្តផ្សេង ៗ មានកិច្ចវត្តជាដើម វៀរនូវបញ្ញត្តិដែលព្រះអង្គទ្រង់ហាម ធ្វើតាមច្បាប់ដែលព្រះអង្គអនុញ្ញាតទុកមកទាំងនេះក៏អនុលោមចូលក្នុងបាតិមោក្ខសំវរសីលដែរ ។

ការដំកល់សតិសង្រួមរវាងឥន្ទ្រិយទាំង ៦ មានភ្នែកជាដើម មិនឲ្យកើតសោមនស្ស ទោមនស្ស ក្នុងវេលាដែលជួបប្រទះនូវអារម្មណ៍ទាំងឡាយ មានឃើញរូបជាដើម ហៅថា ឥន្ទ្រិយសំវរសីល ។

ការចិញ្ចឹមជីវិត ដោយត្រឹមត្រូវ វៀរចាកការលលួងបញ្ឆោតគេហើយចិញ្ចឹមជីវិត ដូចជាអួតឧត្តរិមនុស្សធម្មដែលមិនមានក្នុងខ្លួនជាដើម និងវៀរចាកការចិញ្ចឹមជីវិតខុសផ្លូវធម៌ ដែលជាទំនាស់ដល់ព្រះវិន័យដែលព្រះសម្ពុទ្ធទ្រង់បញ្ញត្តិទុកមក ហៅថា អាជីវបារិសុទ្ធិសីល ។

សីលដែលអាស្រ័យបច្ច័យនោះគឺ ក្នុងវេលាដែលបរិភោគប្រើប្រាស់បច្ច័យទាំង ៤ ណានីមួយ គប្បីពិចារណាជាមុនសិន ដូចជាបរិភោគប្រើប្រាស់ចីវរជាដើម គប្បីពិចារណាថា អាត្មាអញស្លៀកដណ្ដប់សំពត់ចីវរនេះដើម្បីស្អិតស្អាងរាងកាយក៏ទេ ស្លៀកដណ្ដប់ដើម្បីបន្ទោបង់នូវ

ត្រជាក់និងក្ដៅ ដើម្បីការពារសម្ផស្សមកប៉ះពាល់ គឺខ្យល់កំដៅនិងសត្វមូសស្រួយជាដើម និងស្លៀកដណ្ដប់ដើម្បីការពារនូវសេចក្ដីអៀនខ្មាស់ប៉ុណ្ណោះឯង មិនបរិភោគប្រើប្រាស់ដោយអំណាចនៃតណ្ហាទេ យ៉ាងនេះជាដើម ហៅថា បច្ច័យសន្និស្សិតសីល ។

អារក្ខកម្មដ្ឋាន ៤ យ៉ាង

១- ពុទ្ធានុស្សតិ រលឹកដល់គុណព្រះពុទ្ធដែលមានក្នុងព្រះអង្គ និងគុណដែលទ្រង់សង្គ្រោះដល់អ្នកដទៃ ,

២- មេត្តា ផ្សាយមេត្តាចិត្តគិតឲ្យមនុស្សសត្វទាំងពួងបានសុខគ្រប់គ្នា ;

៣- អសុភៈ ពិចារណារាងកាយខ្លួននិងអ្នកដទៃឲ្យឃើញថាជារបស់បដិកូលគួរខ្ពើម ,

៤- មរណស្សតិ នឹកដល់សេចក្ដីស្លាប់ដែលនឹងមានដល់ខ្លួន ។

អធិប្បាយថា ៖

គុណព្រះពុទ្ធជាម្ចាស់នោះមានច្រើនណាស់ តែបើពោលដោយខ្លីមាន ៣ ប្រការគឺ បញ្ញាគុណ ១ , វិសុទ្ធិគុណ ១ , ករុណាគុណ ១ ។

ព្រះប្រាជ្ញារបស់ព្រះអង្គជ្រួតជ្រាបរបស់ពិតគឺ អរិយសច្ចដោយចំពោះព្រះអង្គឯង មិនមានគ្រូអាចារ្យណាដឹកនាំបៀនប្រដៅព្រះអង្គ

ឡើយ នេះហៅថា បញ្ញាគុណ គឺគុណជាចំណែកអត្តហិតសម្បត្តិ ។

កាលដែលព្រះអង្គមានព្រះទ័យបរិសុទ្ធចាកកិលេសាសវៈ ព្រមទាំងវាសនា ហៅថា វិសុទ្ធិគុណ គឺគុណជាចំណែកអត្តហិតសម្បត្តិមាននៅក្នុងព្រះអង្គ ។

កាលដែលព្រះអង្គទ្រង់មានព្រះមហាករុណាធិគុណ អាណិតអាសូរសត្វ ទ្រង់យាងសំដែងធម៌ទេសនាប្រៀនប្រដៅដោយសមគួរដល់បុព្វូបនិស្ស័យ ហៅថា ករុណាគុណ គឺគុណជាចំណែកបរហិតសម្បត្តិមានដល់សត្វដទៃ ។

ការរលឹកដល់គុណព្រះពុទ្ធជាម្ចាស់ ដែលមានក្នុងព្រះអង្គនឹងគុណដែលទ្រង់អនុគ្រោះដល់អ្នកដទៃដូច្នេះហៅថា ពុទ្ធានុស្សតិ ។

មេត្តាសព្ទនេះបើពោលដោយព្យញ្ជនៈ បានដល់សេចក្ដីស្និទ្ធស្នាល សេចក្ដីស្រឡាញ់ ប្រាសចាកពាធៈ ; បើពោលដោយអត្ថបានដល់ការប្រាថ្នាសេចក្ដីសុខ - ចំរើនដល់អ្នកដទៃ , ការផ្សាយមេត្តាចិត្ត ដោយចំពោះមនុស្សនេះ; មនុស្សនោះ, ពួកនេះ, ពួកនោះ ហៅថា ឱទ្ទិសផរណា , ផ្សាយមេត្តាចិត្តដោយទូទៅ មិនចេះចំពោះ មិនមានកំណត់ ហៅថា អនោទ្ទិស្សផរណា, រួមសេចក្ដីទៅថា មានចិត្តគិតនឹងឲ្យសត្វទាំងពួងបានសេចក្ដីសុខ - ចំរើនគ្រប់ ៗ គ្នា ហៅថា មេត្តា ។

ការពិចារណារាងកាយខ្លួននឹងអ្នកដទៃតាំងអំពីសក់, រោម, ក្រចក

ធ្មេញ, ស្បែក ជាដើម, តាមអាការ ៣២ ប្រការឲ្យឃើញថាជារបស់មិនស្អាតគួរខ្ពើម ស្មោកគ្រោក, បើនៅមិនឃើញថាជារបស់បដិកូលទេ ក៏គប្បីពិចារណាដោយពណ៌សម្បុរសណ្ឋាន ទ្រង់ទ្រាយ ទីកើត ទីនៅ ទាល់តែប្រាកដឲ្យឃើញថាជារបស់មិនគួរប្រាថ្នា យ៉ាងនេះជាដើម ហៅថាអសុភៈ ។

ការរលឹកដល់សេចក្ដីស្លាប់ដែលនឹងមានមកដល់ខ្លួន ដោយការពិតថា យើងត្រូវស្លាប់ដោយពិត ឬ ថាសង្ខារទាំងឡាយមិនទៀងទាត់ឡើយ កើតឡើងហើយក៏រលត់ទៅវិញ ដូច្នេះជាដើមទាល់តែកើតចិត្តសង្វេគឡើង ហៅថា មរណស្សតិ ។ សមដូចរឿងបេសការធីតាមានសំដែងក្នុងគម្ពីធម្មបទថា :

កាលដែលព្រះសាស្ដាគង់នៅក្នុងចេតិយឈ្មោះ អគ្គាឡវៈ មានមួយថ្ងៃនោះទ្រង់យាងចូលទៅក្នុងក្រុង, ពួកជននៅក្នុងក្រុងអាឡវីទាំង-អស់ បាននាំគ្នាប្រគេនចង្ហាន់ដល់ព្រះអង្គ , លុះដល់ទីបំផុតភត្តកិច្ច ព្រះអង្គត្រាស់ថា បុគ្គលគប្បីចំរើននូវមរណស្សតិ យ៉ាងនេះថា « អធុវំ មេ ជីវិតំ ធុវំ មរណំ អវស្សំ មយា មរិតព្វំ, មរណបរិយោសានំ មេ ជីវិតំ, ជីវិតំ មេ អនិយតំ, មរណំ និយតំ = ជីវិតរបស់អាត្មាអញមិនទៀង , សេចក្ដីស្លាប់នៃអាត្មាអញ

ទៀង, អាត្មាអញទៀងតែស្លាប់ដោយពិត, ជីវិតរបស់អាត្មាអញមានសេចក្តីស្លាប់ជាទីបំផុត, ជីវិតរបស់អាត្មាអញមិនទៀង, សេចក្តីស្លាប់របស់អាត្មាអញទៀង » ដូច្នេះជាដើម; ដ្បិតថា សេចក្តីស្លាប់ បើជនណាមិនចំរើន, ជននោះរមែងដល់នូវសេចក្តីតក់ស្លុត គឺស្រែកនូវសម្រែកគួរខ្លាចហើយធ្វើកាលកិរិយាក្នុងទីបំផុត ដូចជាបុរសខ្លាចសត្វអាសិរពិស, បើជនណាបានអប់រំនូវមរណស្សតិ, ជននោះ រមែងមិនតក់ស្លុតក្នុងកាលជាទីបំផុត (ស្លាប់) ដូចជាបុរសឃើញសត្វអាសិរពិសចាប់ចោលដោយដំបងរួចឈរនៅមិនតក់ស្លុត, ព្រោះហេតុនោះ អ្នកទាំងឡាយ គួរចំរើននូវមរណស្សតិរាល់ៗថ្ងៃ ។ ពួកជនទាំងនោះ កាលបើឮធម្មទេសនានោះហើយ ក៏ប្រឹងខ្វល់ខ្វាយក្នុងកិច្ចរបស់ខ្លួនៗ ដោយមធ្យ័ត ។

កាលនោះ មានធីតានៃជាងតម្បាញម្នាក់អាយុ ១៦ ឆ្នាំ ប្រឹងចំរើនមរណស្សតិទាំងយប់ទាំងថ្ងៃ ដោយគំនិតថា ឱហ្ន៎! វាចាព្រះអង្គជាទីអស្ចារ្យពេកណាស់! បើដូច្នោះ មានតែអញចំរើនមរណស្សតិកុំខាន, នាងប្រឹងចំរើនយ៉ាងនេះអស់ ៣ ឆ្នាំ ។ ថ្ងៃមួយជាខាងក្រោយមក ព្រះត្រៃលោកាចារ្យទ្រង់រមិលមើលឧបនិស្ស័យសត្វលោក ក៏ទ្រង់ជ្រាបថា នាងកុមារិកានេះ ចូលក្នុងបណ្តាញញាណតថាគតហើយតើ! ដោយហេតុតែនាងនោះប្រឹងចំរើនមរណស្សតិអស់ ៣ ឆ្នាំ ចាប់តាំងពីថ្ងៃដែលនាងស្តាប់ធម្មទេសនាតថាគតម៉្លេះ; បើដូច្នោះ គួរតថាគតទៅក្នុងទីនោះ

ហើយសួរបញ្ហាធម៌ ៤ ប្រការ, ចំពោះនាងកុមារិកា កាលបើនាងដោះស្រាយបញ្ហារួចហើយតថាគតនឹងឲ្យសព្ទសាធុការពរ រួចសំដែងធម្មទេសនាប្រោសនាង ៗ នឹងសម្រេចធម៌អ្វីមួយមិនខាន, មួយទៀត ពួកមហាជនដែលបានសម្រេចធម៌ក៏ព្រោះតែអាស្រ័យនាងកុមារិកានេះដែរ ។ លុះដល់ព្រះអរុណបញ្ចេញវិភាគពេញផ្ទៃមេឃហើយ ព្រះអង្គទ្រង់យាងទៅកាន់ក្រុងអាឡវីជាមួយភិក្ខុសង្ឃ ៥០០ អង្គជាបរិវារ ។ ពួកមហាជនបានឃើញហើយ បបួលគ្នាអ៊ឹកអរឈូឆរចាត់ចែងចង្ហាន់ប្រគេនភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឆាន់ហើយអង្គុយចាំស្តាប់អនុមោទនា ។ ចំណែកនាងកុមារិកា បានឮដំណឹងថា ព្រះសាស្តានិមន្តមក ក៏មានចិត្តត្រេកអរដោយគិតថា បិតារបស់អញជាគ្រូនៃជនទាំងអស់ មានព្រះភក្ត្រដ៏ពេញនិមន្តមកហើយតើ! ហើយគិតតទៅទៀតថា អញខានឃើញព្រះសាស្តាចំនួន ៣ ឆ្នាំហើយ, បើដូច្នោះមានតែអញទៅដើម្បីឃើញព្រះអង្គផងនឹងបានស្តាប់ធម៌ព្រះអង្គផង ។ ចំណែកបិតានៃធីតានោះ បានទៅកាន់រោងតម្បាញហើយប្រាប់នាងថា ម្នាលកូន! ជនដទៃបានជួលឪពុកត្បាញសំពត់នោះ ឥឡូវនេះ សំពត់នោះសល់បន្តិច ចូរកូនការអម្បោះដាក់ខ្នារឲ្យឪពុកយកទៅបង្ហើយបន្តិច ។ នាងកុមារិកាគិតថា ឪពុកឲ្យអញការខ្នារអម្បោះសិន បើយ៉ាងនេះអញទៅស្តាប់ធម៌ឬ ឬជាការខ្នារឲ្យឪពុកសិនហ្ន៎! នាងគិតតទៅទៀតថា បើអញមិនការខ្នារអម្បោះ

ទេ , មុខជាគាត់វាយអញមិនខាន , ណ្ហើយការខ្វារអម្បោះសិនចុះ, សឹមទៅស្តាប់ធម៌ក្រោយ ! ។ ចំណែកព្រះសាស្តាទ្រង់ព្រះតម្រិះថា តថាគតមកអស់ចម្ងាយផ្លូវ ៣០ យោជន៍អាស្រ័យនាងកុមារិកាណា, នាងកុមារិកានោះមិនមានឱកាសទំនេរទេក្នុងថ្ងៃនេះ, កាលបើនាងមានឱកាសល្មមមកហើយ , ទើបតថាគតធ្វើអនុមោទនា ។ ក្នុងពេលនោះ ជនណាមួយក្នុងលោកព្រមទាំងទេវលោក ក៏មិនអាចពោលពាក្យបន្តិចបន្តួចចំពោះព្រះអង្គដែលគង់ស្ងៀមនោះឡើយ ។ ឯនាងកុមារិកានោះ លុះការខ្វាររួចដាក់ទុកក្នុងប្រែងហើយ ក៏ត្រឡប់ទៅកាន់សំណាក់ព្រះអង្គក្នុងពេលនោះឯង ។ ព្រះសាស្តា ក៏ទ្រង់មៀងមើលនាងដែលចូលមកអង្គុយត្រង់កណ្តាលបរិស័ទនោះឯង ។ នាងកុមារិកានោះដឹងថាព្រះអង្គមើលមើលដូច្នោះ ក៏គិតថាប្រហែលជាព្រះអង្គទ្រង់នឹកនូវអាត្មាអញដែលក្រមកហើយមើលទៅ ! ។ បុច្ឆាសួរថា ព្រោះហេតុអ្វី បានជាព្រះអង្គមើលនាងកុមារិកានោះ ? វិស្សជ្ជនាថា ព្រោះតែព្រះអង្គទ្រង់តម្រិះថា នាងកុមារិកានេះ ជាស្ត្រីមានគតិមិនទៀង , បើសិនជានាងមកកាន់សំណាក់តថាគតហើយ ស្តាប់ធម៌នឹងបានសម្រេចសោតាបត្តិផល ទៅជាមានគតិទៀង , ព្រោះនាងមុខជាស្លាប់ពិតក្នុងថ្ងៃនេះ ។ នាងចូលទៅរកព្រះអង្គតាមឆព្វណ្ណរង្សីដែលទ្រង់សាយចេញទៅ ហើយថ្វាយបង្គំអង្គុយក្នុងទីសមគួរ ។ កាលដែលនាងចូលទៅថ្វាយបង្គំអង្គុយដ៏សមគួរ

ហើយ ព្រះអង្គត្រាស់សួរចំពោះនាងថា ម្នាលនាងកុមារិកា នាងមកពីទីណា ? នាងក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន , ខ្ញុំព្រះអង្គមិនដឹង ។ ត្រាស់សួរទៀតថា នាងទៅកាន់ទីណា ? បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនដឹង ; នាងឯងមិនដឹងឬ ? , ខ្ញុំព្រះអង្គដឹង , នាងដឹងឬ ? , ខ្ញុំព្រះអង្គមិនដឹង ។ ពួកមហាជនឮពាក្យដូច្នោះក៏លើកទោសថា ម្នាលអ្នកដ៏ចំរើនទាំងឡាយ , អ្នកទាំងឡាយចូរមើល ធីតានៃជាងតម្បាញនេះ ពោលនូវពាក្យដែលខ្លួនប្រាថ្នាជាមួយនឹងព្រះសម្ពុទ្ធឥម្ល៉េះទេ ! , បេសកាធីតានេះ ព្រះអង្គសួរថា នាងមកពីទីណា ? គួរណាស់តែពោលថា ខ្ញុំព្រះអង្គមកពីរោងតម្បាញ , មួយទៀតព្រះអង្គសួរថា នាងទៅទីណា ? គួរណាស់តែពោលថា ខ្ញុំព្រះអង្គទៅរោងតម្បាញដូច្នោះ មិនមែនឬ ? , ព្រះសាស្តាឮមហាជនលើក ទោសដូច្នោះហើយ ទើបទ្រង់សួរនាងកុមារិកានោះទៀត ដើម្បីបំបាត់ពាក្យនិន្ទានៃមហាជនថា ម្នាលនាងកុមារិកា តថាគតសួរថា នាងមកពីទីណា ? ដូច្នោះ , ហេតុអ្វីក៏នាងពោលថា ខ្ញុំព្រះអង្គមិនដឹង ដូច្នេះវិញ ។ នាងកុមារិកាក្រាបទូលថា បពិតព្រះអង្គដ៏ចំរើន , ព្រះអង្គគង់ជ្រាបថា ខ្ញុំព្រះអង្គមកពីផ្ទះនៃជាងតម្បាញ , ព្រោះអ្វីបានជាព្រះអង្គសួរថា នាងមកពីណា ? ខ្ញុំព្រះអង្គទូលថាមិនដឹងខ្ញុំមកពីណាហើយមកកើតក្នុងទីនេះដូច្នេះទេតើ ! ។ ព្រះអង្គក៏ប្រទានសាធុការជាបឋមថា ម្នាលនាងកុមារិកាប្រពៃហើយ !

ប្រពៃហើយ !, បញ្ហាដែលតថាគតសួរ នាងឆ្លើយដោយប្រពៃហើយ; ទើបសួរទៀតថា តថាគតសួរថា នាងទៅទីណា ? ដូច្នេះ ហេតុអ្វីក៏នាងពោលថា ខ្ញុំព្រះអង្គមិនដឹងដូច្នេះ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គគង់ជ្រាបថា ខ្ញុំព្រះអង្គទៅរោងតម្បាញវិញដូច្នេះ, ហេតុអ្វីក៏សួរខ្ញុំព្រះអង្គថា នាងទៅពីទីនេះហើយទៅកើតទីណាទៀត ដូច្នេះទេតើ !, ចំណែកខ្ញុំព្រះអង្គ មិនដឹងជាខ្ញុំច្យុតនេះទៅកើតទីណា ? ដូច្នេះ ព្រោះហេតុនោះ បានជាខ្ញុំពោលថា មិនដឹង ។ ព្រះអង្គត្រាស់ថា បញ្ហាដែលតថាគតសួរ នាងឆ្លើយដោយប្រពៃ ហើយប្រទានសព្ទសាធុការពរជាគំរប់ពីរ ត្រាស់សួរតទៅទៀតថា តថាគតសួរថា នាងមិនដឹងឬ ? ដូច្នេះ ហេតុអ្វីក៏នាងពោលថា ខ្ញុំព្រះអង្គដឹងដូច្នេះវិញ ? បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គដឹងថាខ្ញុំព្រះអង្គទៀងតែស្លាប់, ព្រោះហេតុនោះ បានជាខ្ញុំព្រះអង្គពោលយ៉ាងនេះឯង ។ ព្រះអង្គក៏ប្រទានសព្ទសាធុការពរជាគំរប់បី ដោយព្រះពុទ្ធដីការថា បញ្ហាដែលតថាគតសួរ នាងបានដោះស្រាយដោយប្រពៃហើយ ទ្រង់ត្រាស់សួរទៀតថាតថាគតសួរថា នាងដឹងឬ ? ដូច្នេះ, ហេតុអ្វីក៏នាងពោលថា ខ្ញុំព្រះអង្គមិនដឹង ? ដូច្នេះវិញ ។ បពិត្រព្រះអង្គដ៏ចំរើន, ខ្ញុំព្រះអង្គដឹងថា ខ្ញុំព្រះអង្គទៀងតែស្លាប់, តែថាខ្ញុំព្រះអង្គមិនដឹងថាខ្ញុំព្រះអង្គស្លាប់ក្នុងទីណា? យប់ឬថ្ងៃ ? ដូច្នេះ, ព្រោះហេតុនោះបានជាខ្ញុំពោលយ៉ាងនេះ ។ ព្រះ

អង្គក៏ប្រទានសព្ទសាធុការពរជាគំរប់ ៤ ដោយព្រះពុទ្ធដីការដូចមុនទៀត ហើយត្រាស់ហៅបរិស័ទដោយព្រះពុទ្ធដីការថា អ្នកទាំងឡាយមិនដឹងជានាងកុមារិកានេះពោលដូច្នេះទេ, ហើយថែមទាំងលើកទោសតថាគតទៀត, មែនពិត បញ្ញាចក្ខុមិនមានដល់ជនអន្ធពាលទេ, រមែងមានដល់ជនដែលចាក់ធ្លុះនូវធម៌នៃតថាគត ! ហើយទ្រង់ត្រាស់តទៅ។ ទៀតដោយព្រះពុទ្ធដីកាជាគាថាថា :

អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ
សកុណោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ។

សត្វលោកនេះត្រូវងងឹតគឺអវិជ្ជាគ្របសង្កត់, បណ្ដាសត្វលោកទាំងនោះ សត្វលោកដែលពិចារណាឃើញច្បាស់នូវអនិច្ចលក្ខណៈ មានប្រមាណតិចទេ, ដូចជាសត្វស្លាបដែលរួចចាកសំណាញ់, សត្វលោកដែលទៅកាន់ស្ថានសួគ៌ ក៏មានតិចតួចដែរ ៗ

ទីបំផុតនៃធម្មទេសនា នាងកុមារិកាក៏បានសម្រេចសោតាបត្តិផល ហើយថ្វាយបង្គំព្រះអង្គត្រឡប់ទៅកាន់គេហដ្ឋានវិញ ។ ចំណែកបិតារបស់នាង ក៏អង្គុយដេកលក់តែដៃគាត់ព្យួរត្រល់ទៅទង្គិចចុងនៃផ្ទុំ ហើយភ្ញាក់ឡើងស្រឡាំងកាំងដោយអំណាចនៃចិត្តដែលកាន់យកនិមិត្តផ្សេង ៗ ក៏យកដៃទៅចាប់កន្ត្រាក់ចុងផ្ទុំ ៗ ចុងផ្ទុំក៏ចើង

ទៅទន្ទិចទ្រូងនៃនាងដែលនៅពីខាងម្ខាង ដួលស្លាប់ក្នុងទីនោះហើយ ទៅកើតក្នុងតុសិតភព ។ បិតាកាលបើឃើញកូនដួលស្លាប់ដូច្នោះហើយ មិនអាចញុំាងសេចក្ដីទុក្ខឲ្យរលត់ទៅបាន ក៏ទៅកាន់សំណាក់ព្រះសាស្ដាហើយក្រាបបង្គំទូលរឿងរ៉ាវសព្វគ្រប់ ។ ព្រះអង្គត្រាស់ថា ចូរអ្នកកុំសោយសោកឡើយ , ដ្បិតថា បើអ្នកសោយសោក ទឹកភ្នែកដែលហូរចេញក្នុងកាលដែលធីតានៃអ្នកស្លាប់ មានទីបំផុតនៃសង្សារគឺពុទ្ធញាណក៏កំណត់មិនបានដែរ , ព្រោះទឹកភ្នែកទាំងនោះច្រើនជាងមហាសមុទ្រទាំង ៤ ទៅទៀត ។ ជាងតម្បាញកាលបើរន់ធូរចាកសេចក្ដីសោកនោះហើយ ក៏សូមផ្នួសបួសរួចសម្រេចព្រះអរហត្តក្នុងទីបំផុតនៃឧបសម្បទាដែលខ្លួនបានហើយ ។

សំដែងរឿងនេះ ដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ថាមរណស្សតិដែលបុគ្គលណាចំរើនរាល់ ៗ ថ្ងៃហើយ , បុគ្គលនោះរមែងមិនតក់ស្លុតក្នុងកាលជាទីបំផុត (ស្លាប់) នោះទេ , ដូចរឿងដែលពោលមកនោះឯង គឺថានាងកុមារិកានោះដែលទៅកើតក្នុងតុសិតភពបាន ព្រោះអាស្រ័យកម្មដែលនាងប្រឹងចំរើនមរណស្សតិមែនពិត ។ ព្រោះហេតុនោះបានជាព្រះអង្គសំដែងថា បុគ្គលគប្បីចំរើនកម្មដ្ឋានបួននោះរាល់ ៗ ថ្ងៃកុំខាន ។

ព្រហ្មវិហារ ៤ យ៉ាង

១.– មេត្តា សេចក្ដីប្រាថ្នាចង់ឲ្យគេបានសុខ ;

២– ករុណា សេចក្ដីអាណិតគិតជួយឲ្យគេរួចចាកទុក្ខ ;

៣– មុទិតា សេចក្ដីត្រេកអរក្នុងវេលាគេបានល្អ ;

៤– ឧបេក្ខា សេចក្ដីតាំងចិត្តជាកណ្ដាលមិនឲ្យមានសោមនស្សទោមនស្សក្នុងវេលាដែលគេបានសេចក្ដីវិបត្តិ ។

ធម៌ ៤ យ៉ាងនេះជាគ្រឿងប្រព្រឹត្តរបស់អ្នកធំ ។

អធិប្បាយថា :

មេត្តា ប្រែថា " រាប់អាន , ស្រឡាញ់ , កើតមានក្នុងមិត្រ , ប្រព្រឹត្តទៅដល់មិត្រ ,, , ករុណា ប្រែថា ,, អាណិត , ធ្វើនូវសេចក្ដីញាប់ញ័រដោយហឫទ័យដល់ពួកសប្បុរស ក្នុងកាលដែលសត្វដទៃមានទុក្ខ , ធ្វើនូវសេចក្ដីទុក្ខរបស់សត្វដទៃឲ្យវិនាស , បោះបោលនូវសេចក្ដីទុក្ខរបស់អ្នកដទៃ , ផ្សាយទៅក្នុងសត្វដទៃដែលមានសេចក្ដីទុក្ខ ,, , មុទិតា ប្រែថា « ត្រេកអរ , រីករាយ » , ឧបេក្ខាប្រែថា ព្រងើយកន្តើយ ក្រឡេកយកឫសំឡឹងមើល ដោយការដល់នូវភាពនៃចិត្តជាកណ្ដាល » ។

បើសំដែងតាមលក្ខណៈ កិច្ច ផល និងអាសន្នហេតុ ហិតាការប្បវត្តិលក្ខណា មេត្តានោះ មានការប្រព្រឹត្តទៅដោយអាការជាប្រយោជន៍ជាលក្ខណៈគ្រឿងកំណត់កត់សំគាល់ , ហិតូបសំហារសារា មេត្តានោះ មានការប្រមូលទុកនូវប្រយោជន៍ជាកិច្ចភ្នាក់ងារ , អាឃាតវិនយបច្ចុ-

បដ្ឋានា មេត្តានោះ មានការកំចាត់បង់នូវគំនុំផល, សត្តានំ មនាបភាវតស្សនបទដ្ឋានា មេត្តានោះ មានការឃើញនូវភាពនៃសត្វទាំងឡាយជាទីស្រឡាញ់គាប់ចិត្តជាអាសន្នហេតុ គឺជាហេតុជិតនឹងឲ្យកើតមេត្តា ។ ទុក្ខាបនយនាការប្បវត្តិលក្ខណា ករុណានោះ មានការប្រព្រឹត្តទៅដោយអាការ គឺនាំចេញនូវសេចក្តីទុក្ខលក្ខណៈគ្រឿងកំណត់សំគាល់, បរទុក្ខាសហនរសា ករុណានោះ មានសេចក្តីមិនអត់ធន់នូវសេចក្តីទុក្ខរបស់សត្វដទៃជាកិច្ចភ្ញាក់ងារ, អវិហឹសាបច្ចុបដ្ឋានា ករុណានោះ មានសេចក្តីមិនបៀតបៀនគេជាផល, ទុក្ខាភិភូតានំ អនាថភាវទស្សនបទដ្ឋានា ករុណានោះ មានការឃើញនូវភាពនៃសត្វដែលត្រូវសេចក្តីទុក្ខគ្របសង្កត់ ជាសត្វឥតទីពឹង ជាអាសន្នហេតុ ។ បមោទលក្ខណា មុទិតានោះ មានសេចក្តីរីករាយជាលក្ខណៈគ្រឿងកំណត់កត់សំគាល់, អនិស្សាយនរសា មុទិតានោះ មានសេចក្តីមិនច្រណែនឈ្នានីស ជាកិច្ចភ្ញាក់ងារ, អរតិវិឃាដបច្ចុបដ្ឋានា មុទិតានោះ មានការកំចាត់បង់នូវសេចក្តីអផ្សុក ឬសេចក្តីមិនត្រេកអរជាផល, សត្តានំ សម្បត្តិទស្សនបទដ្ឋានា មុទិតានោះ មានការឃើញនូវសម្បត្តិរបស់សត្វទាំងឡាយ ជាអាសន្ន

ហេតុ ។ សត្តេសុ មជ្ឈត្តាការប្បវត្តិលក្ខណា ឧបេក្ខានោះ មានការប្រព្រឹត្តទៅដោយអាការជាកណ្តាល ក្នុងសត្វទាំងឡាយ ជាលក្ខណៈគ្រឿងកំណត់សំគាល់, សត្តេសុ សមភាវទស្សនរសា ឧបេក្ខានោះ មានការឃើញឬសំដែងនូវភាពស្មើគ្នា ក្នុងសត្វទាំងឡាយ ជាកិច្ចភ្ញាក់ងារ, បដិឃានុនយវូបសមបច្ចុបដ្ឋានា ឧបេក្ខានោះ មានការរំងាប់នូវសេចក្តីខឹងនឹងសេចក្តីត្រេកអរ ឬសេចក្តីស្អប់នឹងសេចក្តីស្រឡាញ់ ជាផល, កម្មស្សកតាទស្សនបទដ្ឋានា ឧបេក្ខានោះ មានការឃើញនូវភាពនៃសត្វ មានកម្មជារបស់ខ្លួន ជាអាសន្នហេតុ ។

វិធិផ្សាយព្រហ្មវិហារធម៌

ការផ្សាយមេត្តាមាន ៣ យ៉ាងគឺ: អនោធិសោ ផរណា ផ្សាយទៅដោយមិនមានចំណែកថាប្រុសថាស្រីជាដើម ១, ឱធិសោ ផរណា ផ្សាយទៅដោយចំណែកថាប្រុសថាស្រីជាដើម ១, ទិសា ផរណា ផ្សាយទៅកាន់ទិសទាំងពួង ១ ។

អនោធិសោ ផរណា ផ្សាយទៅដោយមិនមានចំណែកនោះដោយអាការ ៥ ប្រការគឺ:

១– សព្វេ សត្តា អវេរា អព្យាបជ្ឈា អនិឃា

សុខីអត្តានំ បរិហរន្តុ *សត្វទាំងឡាយទាំងពួងកុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ,*

២- សព្វេ បាណា ។ល។ *បាណៈទាំងឡាយទាំងពួង កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ :*

៣- សព្វេ ភូតា ។ល។ *ភូតទាំងឡាយទាំងពួង កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;*

៤- សព្វេ បុគ្គលា ។ល។ *បុគ្គលទាំងឡាយទាំងពួង កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;*

៥- សព្វេ អត្តភាវបរិយាបន្នា អវេរា អព្យាបជ្ឈា អនីឃា សុខីអត្តានំ បរិហរន្តុ *អត្តភាវបរិយាបន្នៈទាំងឡាយទាំងពួង កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ។*

ពាក្យថា “សត្វ” ប្រែថា ជាប់នៅក្នុងខន្ធទាំង ៥ មានរូបខន្ធជាដើម ដោយឆន្ទរាគគឺសេចក្ដីប្រាថ្នានឹងសេចក្ដីត្រេកអរ ។ ពាក្យថា

„បាណ” ប្រែថា ជាប់មក ឬរស់ដោយខ្យល់ដកដង្ហើមចេញចូល ។ ពាក្យថា «ភូត» ប្រែថា កើតនៅក្នុងលោក ។ ពាក្យថា «បុគ្គល» ប្រែថា ជាប់នៅក្នុងភក់ គឺកិលេស ( )។ ពាក្យថា អត្តភាវបរិយាបន្ន” ប្រែថារាប់បញ្ចូល ឬកំណត់ក្នុងអត្តភាពគឺខន្ធទាំង ៥ ។ ពាក្យទាំង ៥ នេះ ជាពាក្យផ្លាស់ប្ដូរគ្នា បានសេចក្ដីថា សត្វប៉ុណ្ណោះឯង ។

អនិសោ ផរណា ផ្សាយទៅដោយចំណែកនោះដោយអាការ៧ យ៉ាងគឺៈ

១- សព្វា ឥត្ថិយោ អវេរា អព្យាបជ្ឈា អនីឃា សុខីអត្តានំ បរិហរន្តុ *ស្ត្រីទាំងឡាយទាំងពួង កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;*

២- សព្វេ បុរិសា ។ល។ *បុរសទាំងឡាយទាំងពួង កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;*

៣- សព្វេ អរិយា ។ល។ *ព្រះអរិយបុគ្គលទាំងឡាយទាំងពួង កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;*

៤- សព្វេ អនរិយា ។ល។ *បុគ្គលមិនមែនជាព្រះអរិយៈ*

---

១ = ក្នុងវិសុទ្ធិមគ្គប្រែថា ទៅកាន់នរក ។

គឺបុថុជ្ជនទាំងឡាយទាំងពួង កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;

៥- សព្វេ ទេវា ។ល។ *ទេវតាទាំងឡាយទាំងពួងកុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ;*

៦- សព្វេ មនុស្សា ។ល។ *មនុស្សទាំងឡាយទាំងពួង កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខ ;*

៧- សព្វេ វិនិបាតិកា អវេរា អព្យាបជ្ឈា អនីឃា សុខីអត្តានំ បរិហរន្តុ *វិនិបាតិកសត្វ គឺសត្វដែលកើតក្នុងអបាយទាំងឡាយទាំងពួង កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ។*

ឯទិសាផរណា ផ្សាយទៅកាន់ទិសទាំងពួងនោះ ដោយអាការ ១០ គឺ :

១- សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខីអត្តានំ បរិហរន្តុ *សត្វទាំងឡាយទាំងពួងក្នុងទិសខាងកើត កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;*

២- សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា ។ល។ *សត្វទាំងឡាយទាំងពួងក្នុងទិសជាលំដាប់នៃទិសខាងកើត គឺទិសអគ្នេយ៍ កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;*

៣- សព្វេ បច្ឆិមាយ ទិសាយ សត្តា ។ល។ *សត្វទាំងឡាយទាំងពួងក្នុងទិសខាងលិច កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;*

៤- សព្វេ បច្ឆិមាយ អនុទិសាយ សត្តា ។ល។ *សត្វទាំងឡាយទាំងពួងក្នុងទិសជាលំដាប់នៃទិសខាងលិច គឺទិសពាយ័ព្យ កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;*

៥- សព្វេ ឧត្តរាយ ទិសាយ សត្តា ។ល។ *សត្វទាំងឡាយទាំងពួងក្នុងទិសខាងជើង កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;*

៦- សព្វេ ឧត្តរាយ អនុទិសាយ សត្តា ។ល។ *សត្វទាំងឡាយទាំងពួងក្នុងទិសជាលំដាប់នៃទិសខាងជើង គឺទិសឦសាន កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួន*

ឲ្យជាសុខចុះ ;

៧- សព្វេ ទក្ខិណាយ ទិសាយ សត្តា ។ល។ សត្វទាំងឡាយទាំងពួងក្នុងទិសខាងត្បូង កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;

៨- សព្វេ ទក្ខិណាយ អនុទិសាយ សត្តា ។ល។ សត្វទាំងឡាយទាំងពួងក្នុងទិសជាលំដាប់នៃទិសខាងត្បូង គឺទិសនិរតី កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;

៩- សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា ។ល។ សត្វទាំងឡាយទាំងពួងក្នុងទិសខាងក្រោម កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ;

១០- សព្វេ ឧបរិមាយ ទិសា សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខីអត្តានំ បរិហរន្តុ សត្វទាំងឡាយទាំងពួងក្នុងទិសខាងលើ កុំបីមានពៀរនឹងគ្នា កុំបីមានព្យាបាទនឹងគ្នា កុំបីមានទុក្ខ ចូររក្សាខ្លួនឲ្យជាសុខចុះ ។

ឯករុណាក្តី មុទិតាក្តី ឧបេក្ខាក្តី គឺមានវិធីផ្សាយទៅដោយអាការ ៥ ឬ ៧ ក៏ ១០ ដូចមេត្តានោះដែរ ។

ម្យ៉ាងទៀត ព្រហ្មវិហារទាំង ៤ នោះ បើនឹងផ្សាយដោយសេចក្តីសង្ខេបដូច្នេះ គឺមេត្តាត្រូវផ្សាយថា សព្វេ សត្តា អវេរា ហោន្តុ សត្វទាំងឡាយទាំងពួង កុំបីមានពៀរនឹងគ្នា ។ ករុណាត្រូវផ្សាយថា សព្វេ សត្តា ទុក្ខា បមុញ្ចន្តុ សត្វទាំងឡាយទាំងពួងចូររួចចាកទុក្ខរួច ។ មុទិតាត្រូវផ្សាយថា សព្វេ សត្តា លទ្ធសម្បត្តិតោ មាវិគច្ឆន្តុ សត្វទាំងឡាយទាំងពួង កុំបីព្រាត់ប្រាសចាកសម្បត្តិ គឺសេចក្តីសុខ-ចំរើន ដែលខ្លួនបានហើយ ។ ឧបេក្ខា ត្រូវផ្សាយថា សព្វេ សត្តា កម្មស្សកា កម្មទាយាទ សត្វទាំងឡាយទាំងពួង មានកម្មជារបស់ខ្លួន មានកម្មជាមត៌ក ។

បើតាមសេចក្តីនេះ គួរចូលចិត្តថា មេត្តា មានសត្វខ្លួនទៅក្នុងត្រៃលោកជាអារម្មណ៍ , ករុណា មានសេចក្តីទុក្ខរបស់សត្វទាំងនោះជាអារម្មណ៍ , មុទិតា មានសម្បត្តិរបស់សត្វទាំងនោះជាអារម្មណ៍ , ឧបេក្ខា មានកម្មរបស់សត្វនោះជាអារម្មណ៍ ។

ក៏ឯមេត្តានោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សំដែងថា បើបុគ្គលឯណាចំរើនឲ្យដុះដាលកើតមានក្នុងសន្តានហើយ , បុគ្គលនោះរមែងបានអានិសង្ស ១១ ប្រការគឺ :

១- សុខំ សុបតិ បុគ្គលអ្នកប្រកបដោយមេត្តា រមែង

ដេកលក់ជាសុខស្រួលល្អ ;

២– សុខំ បដិពុជ្ឈតិ អ្នកប្រកបដោយមេត្តា រមែងភ្ញាក់រលឹកអំពីលក់ក៏ជាសុខស្រួលល្អ ;

៣– ន បាបកំ សុបិនំ បស្សតិ អ្នកប្រកបដោយមេត្តា កាលនឹងដេកលក់ទៅ មិនបានយល់សប្តិឃើញអាក្រក់ឡើយ គឺយល់សប្តិឃើញល្អ ៗ ឃើញហាក់ដូចជាថ្វាយបង្គំចេតិយ ហាក់ដូចជាបូជាព្រះរតនៈ ហាក់ដូចជាស្តាប់ធម៌ជាដើម ;

៤– មនុស្សានំ បិយោ ហោតិ អ្នកប្រកបដោយមេត្តា រមែងជាទីស្រឡាញ់ជាទីគាប់ចិត្តនៃមនុស្សទាំងឡាយ ប្រៀបដូចកែវមុក្តាហារសម្រាប់ពាក់ដើមទ្រូង នឹងកម្រងផ្កាសម្រាប់ប្រដាប់ក្បាល ។

៥– អមនុស្សានំ បិយោ ហោតិ អ្នកប្រកបដោយមេត្តា រមែងជាទីស្រឡាញ់ជាទីគាប់ចិត្តនៃអមនុស្សទាំងឡាយ មានទេវតាជាដើម ;

៦– ទេវតា រក្ខន្តិ ពួកទេវតាតែងរក្សាបុគ្គលដែលប្រកបដោយមេត្តា ប្រៀបដូចមាតាបិតាថែរក្សាបុត្រ ;

៧– នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ បុគ្គលដែលប្រកបដោយមេត្តា មិនបានឆេះរលាកប្តៅក្រហាយដោយ

ភ្លើង មិនបានស្លាប់វិនាសដោយថ្នាំពិសបំពុល មិនបានមុតដោយគ្រឿងសាស្ត្រាវុធផ្សេង ៗ ដូចជាមេគោកំពុងបំបៅកូន ;

៨– តុវដំ ចិត្តំ សមាធិយតិ ចិត្តរបស់អ្នកប្រកបដោយមេត្តារមែងតាំងនៅខ្ជាប់ខ្ជួនល្អដោយឆាប់រហ័សឬមិនបានយឺតយូរឡើយ ;

៩– មុខវណ្ណោ វិប្បសីទតិ អ្នកប្រកបដោយមេត្តា រមែងមានមុខស្រស់បស់ ប្រៀបដូចជាផ្លែត្នោតទុំដែលទើបនឹងជ្រុះចាកទង ;

១០– អសម្មូឡ្ហោ កាលំ ករោតិ អ្នកប្រកបដោយមេត្តាមិនបានធ្វើមរណកាលដោយសេចក្តីវង្វេង គឺគ្មានសេចក្តីវង្វេងហើយស្លាប់ គឺថាស្លាប់ដូចជាគេដេកលក់ស្រួល ;

១១– ឧត្តរិ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ អ្នកប្រកបដោយមេត្តា ទុកជាមិនបានត្រាស់ដឹងនូវគុណធម៌ដ៏ខ្ពង់ខ្ពស់ជាងមេត្តាសមាបត្តិនោះ លុះច្យុតអំពីលោកនេះទៅហើយ ក៏គង់តែបានទៅកើតក្នុងព្រហ្មលោកមិនខាន ។

ចំណែកខាងករុណាក្តី មុទិតាក្តី ឧបេក្ខា ក៏មានអានិសង្ស ១១ ប្រការដូចគ្នា , តែប្រយោជន៍របស់ព្រហ្មវិហារទាំង ៤ ប្រការនោះមានដោយឡែក គឺការលះបង់នូវព្យាបាទ ជាប្រយោជន៍របស់មេត្តា ការលះបង់នូវសេចក្តីបៀតបៀន ជាប្រយោជន៍របស់ករុណា , ការលះ

បង់នូវសេចក្តីអផ្សុក ឬ សេចក្តីមិនត្រេកអរ ជាប្រយោជន៍របស់មុទិតា, ការលះបង់នូវរាគៈតឹតម្រេក ជាប្រយោជន៍របស់ឧបេក្ខា ។

ម្យ៉ាងទៀត មេត្តាជាផ្លូវបរិសុទ្ធរបស់បុគ្គលដែលមានព្យាបាទច្រើន ករុណា ជាផ្លូវបរិសុទ្ធរបស់បុគ្គលដែលមានសេចក្តីបៀតបៀនច្រើន, មុទិតា ជាផ្លូវបរិសុទ្ធរបស់បុគ្គលដែលមានសេចក្តីអផ្សុក ឬ សេចក្តីមិនត្រេកអរច្រើន, ឧបេក្ខា ជាផ្លូវបរិសុទ្ធរបស់បុគ្គលដែលមានរាគៈច្រើន ។

សតិប្បដ្ឋាន ៤ យ៉ាង

១- **កាយានុបស្សនា** សតិរលឹកពិចារណាកាយជាអារម្មណ៍ថា កាយនេះគ្រាន់តែជាកាយប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ;

២- **វេទនានុបស្សនា** សតិរលឹកពិចារណាវេទនាគឺសេចក្តីសុខ ទុក្ខ ឧបេក្ខាជាអារម្មណ៍ថា វេទនានេះគ្រាន់តែជាវេទនាប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ;

៣- **ចិត្តានុបស្សនា** សតិរលឹកពិចារណាចិត្តដែលសៅហ្មងនឹងផូរផង់ជាអារម្មណ៍ថា ចិត្តនេះគ្រាន់តែជាចិត្តប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ;

៤- **ធម្មានុបស្សនា** សតិរលឹកពិចារណាធម៌ជាកុសល ឬ

អកុសលដែលកើតឡើងជាមួយនឹងចិត្តជាអារម្មណ៍ថា ធម៌នេះគ្រាន់តែជាធម៌ប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ ។

អធិប្បាយថា :

សតិប្បដ្ឋាន: សតិជាទីតាំងជាប្រធានបានសេចក្តីថា ការចំរើនធម៌ទាំង ៤ ប្រការនេះ, ក្នុងទីនេះត្រូវមានសតិជាទីតាំង បំណងតាមប្រភេទរបស់អារម្មណ៍ ឯប្រភេទរបស់អារម្មណ៍នោះលោកចែកជា ៤ យ៉ាងគឺកាយ បានដល់រូប ១, វេទនា បានដល់ការសោយអារម្មណ៍ ១, ចិត្តបានដល់ការគិតនឹក ១, ធម្ម បានដល់សភាពដែលកើតឡើងជាមួយនឹងចិត្ត ១, ការដំកល់សតិពិចារណាអារម្មណ៍ដែលមកប្រាកដចំពោះមុខនឹងតាមធម្មតារបស់អារម្មណ៍តែក្នុង ១ គ្រាៗ ព្រោះថាសញ្ញាតិរបស់អារម្មណ៍ជាចំណែកល្អដែលជាទីពេញចិត្ត នឹងជាចំណែកអាក្រក់ដែលមិនជាទីពេញចិត្ត ក៏កើតឡើងហើយ តែងសូន្យទៅវិញដូចគ្នាទាំងអស់, ចំណែកល្អចង់ឲ្យគង់នៅយូរ, ចំណែកមិនល្អចង់ឲ្យអន្តរធានវិនាសទៅដោយឆាប់រហ័ស, ទោះបីយ៉ាងណាក៏ដោយកើតឡើងហើយក៏សូន្យទៅវិញដូចគ្នា; កិរិយាមិនបណ្តោយសតិ នឹងដល់ប្រភេទរបស់អារម្មណ៍ដូច្នេះ ហៅថា សតិប្បដ្ឋាន: ។ ក្នុងមហាសតិប្បដ្ឋានសូត្រលោកពោលថា អ្នកដែលចំរើនសតិប្បដ្ឋាន ត្រូវប្រកបដោយអង្គ ៣

គឺ សតិ ១, សម្បជញ្ញៈ ១, សេចក្ដីព្យាយាម ១, ទើបអាចនាំអភិជ្ឈា និងទោមនស្សឲ្យថយចេញទៅបាន ។

ម្យ៉ាងទៀត សតិប្បដ្ឋាន ៤ នេះមិនចាំបាច់ចំរើនទាំងអស់នោះទេ, ចំរើនតែណាមួយក៏គង់សម្រេចប្រយោជន៍បានដែរ, ប្រៀបដូចជាព្រះរាជវាំងមានទ្វារ ៤ ទុកជាចូលទៅតាមទ្វារណាក៏គង់ដល់ប្រាសាទដូច្នោះ ។ កាយានុបស្សនា ទុកដូចជាទិសខាងកើត, វេទនានុបស្សនា ទុកដូចជាទិសខាងត្បូង, ចិត្តានុបស្សនា ទុកដូចជាទិសខាងលិច, ធម្មានុបស្សនា ទុកដូចជាទិសខាងជើង, អដ្ឋង្គិកមគ្គ ទុកដូចជាផ្លូវដែលចូលទៅតាមទ្វារ ប្រាសាទទុកដូចជាព្រះមហានិព្វាន ។

ធាតុកម្មដ្ឋាន ៤ យ៉ាង

១-បឋវីធាតុ ធាតុដី ;

២-អាបោធាតុ ធាតុទឹក ;

៣-តេជោធាតុ ធាតុភ្លើង ;

៤-វាយោធាតុ ធាតុខ្យល់ ;

ធាតុណាមានលក្ខណៈរឹង ធាតុនោះឈ្មោះថា បឋវីធាតុ ៗ នោះដែលជាខាងក្នុង ១៩ គឺៈ កេសា សក់, លោមា រោម, នខា ក្រចក ទន្តា ធ្មេញ, តចោ ស្បែក, មំសំ សាច់, ន្ហារូ សរសៃ; អដ្ឋិ ឆ្អឹង, អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង, វក្កំ តាច, ហទយំ បេះដូង, យកនំ ថ្លើម, កិលោមកំ វាវ, បិហកំ ក្រពះ, បប្ផាសំ សួត, អន្តំ ពោះវៀនធំ, អន្តគុណំ ពោះវៀនតូច, ឧទរិយំ អាហារថ្មី, ករីសំ អាហារចាស់ ។

ធាតុណាមានលក្ខណៈរាវជ្រួតជ្រាប ធាតុនោះឈ្មោះថា អាបោធាតុ ៗ នោះដែលជាខាងក្នុង ១២ គឺ បិត្តំ ប្រមាត់, សេម្ហំ ស្លេស្ម៍, បុព្វោ ខ្ទុះ, លោហិតំ ឈាម, សេទោ ញើស, មេទោ ខ្លាញ់ខាប់, អស្សុ ទឹកភ្នែក, វសា ខ្លាញ់រាវ, ខេឡោ ទឹកមាត់ សិង្ឃាណិកា ទឹកសម្បោរ, លសិកា រំអិល, មុត្តំ មូត្រ ។

ធាតុណាមានលក្ខណៈក្ដៅ ធាតុនោះឈ្មោះថា តេជោធាតុ ៗ នោះដែលជាខាងក្នុង ៤ គឺ :

១- សន្តប្បគ្គិ ភ្លើងដែលញុំាងកាយឲ្យក្ដៅ ;

២- ជិរណគ្គិ ភ្លើងដែលញុំាងកាយឲ្យទ្រុឌទ្រោម ;

៣- បរិណាមគ្គិ ភ្លើងដែលញុំាងកាយឲ្យក្រហល់ក្រហាយ ;

៤- បរិទយ្ហគ្គិ ភ្លើងដែលដុតអាហារឲ្យរលួយ ។

ធាតុណាមានលក្ខណៈបក់ទៅមកធាតុនោះឈ្មោះថាវាយោធាតុ ៗ នោះដែលជាខាងក្នុង ៦ គឺ :

១- ឧទ្ធង្គមាវាត ខ្យល់បក់ឡើងលើ ;

២- អធោគមវាត ខ្យល់បក់ចុះក្រោម ;

៣- កុច្ឆិយវាត ខ្យល់បក់ក្នុងពោះ ;

៤- កោដ្ឋាសយវាត ខ្យល់បក់ក្នុងពោះវៀន ;

៥- អង្គមង្គានុសារីវាត ខ្យល់បក់ក្នុងរាងកាយ ;

៦- អស្សាសបស្សាសវាត ខ្យល់ដកដង្ហើមចេញចូល ។

សេចក្ដីកំណត់ពិចារណាកាយនេះឲ្យឃើញថា គ្រាន់តែជាធាតុ ៤ គឺ : ដី ទឹក ភ្លើង ខ្យល់ , ប្រជុំគ្នាប៉ុណ្ណោះ មិនមែនយើង មិនមែនរបស់យើង ដូច្នេះហៅថា ធាតុកម្មដ្ឋាន ។

អធិប្បាយថា :

ពាក្យថា «ធាតុ» ប្រែថាទ្រទ្រង់ , ធាតុសព្ទនេះ បានដល់របស់ដែលញែកចេញទៅទៀតមិនបាន ដូចជាដីញែកចេញទៅជាអ្វីទៀតមិនបានជាដើម ។

ការប្រជុំគ្នានៃធាតុទាំង ៤ ហៅថារាងកាយ ។ នេះអាស្រ័យដោយធាតុទាំង៤ប្រជុំគ្នាជាបច្ច័យឲ្យកើតបុទ្ធិអំណាចដ៏សំខាន់, មួយទៀតដែលហៅថា មនោ ប្រែថា បង្អោនទៅរកអារម្មណ៍ , មនោឬចិត្តនេះមានច្រកផ្លូវ ៥ យ៉ាងដែលហៅថា វិថី គឺភ្នែក , ត្រចៀក, ច្រមុះ , អណ្ដាត, កាយ , ចំណែកខាងភ្នែក បានឃើញរូប, ត្រចៀកស្ដាប់សំឡេង, ច្រមុះធុំក្លិន, អណ្ដាតជញ្ជក់រស , កាយប៉ះពាល់, ចិត្តតែងដឹងការគ្រប់យ៉ាងអំពីវិថីទាំង ៥ នេះ ។

រូប, សំឡេង, ក្លិន, រស, ផោដ្ឋព្វ ដូចជាស្រមោលឆ្លុះឲ្យប្រាកដដល់ចិត្ត ហៅជា ធម្ម ឬ ធម្មារម្មណ៍ , តពីនោះមកចិត្តក៏បញ្ជូនទៅកាមវិថីនៃកាយ ឬ កាមវិថីដទៃ ៗ ឲ្យអវយវៈធ្វើកិច្ចនោះ ៗ សម្រេចបាន , ព្រោះហេតុនោះហើយ បានជារាងកាយប្រព្រឹត្តទៅកើត , និយាយបាន , ធ្វើអ្វីផ្សេង ៗ បាន, ប្លែកខុសអំពីរូបកុក្កតាដែលគេធ្វើអំពីដី គេគួរនឹងក្រដាស , ការពិចារណារាងកាយ ញែកចេញទៅជាចំណែក ៗ ទំលាយឃនសញ្ញា គឺសេចក្ដីសំគាល់ថាជាដុំចេញបាន ឲ្យឃើញថាជាដី , ទឹក , ភ្លើង , ខ្យល់ , ប្រជុំគ្នាប៉ុណ្ណោះ មិនមែនយើង មិនមែនរបស់យើងយ៉ាងនេះ ហៅថា ធាតុកម្មដ្ឋាន ។

អរិយសច្ច ៤ យ៉ាង

១- ទុក្ខសច្ច បានដល់ទុក្ខទាំង ១២ កងមានជាតិទុក្ខជាដើម;

២- សមុទយសច្ច ហេតុដែលនាំឲ្យកើតទុក្ខ ១២ កង គឺតណ្ហាទាំង ៣ ;

៣- និរោធសច្ច សេចក្ដីរំលត់ទុក្ខទាំង ១២ កងគឺព្រះនិព្វាន :

៤- មគ្គសច្ច ឧបាយរំលត់នូវតណ្ហាទាំង ៣ ។

អធិប្បាយថា :

សេចក្ដីមិនសប្បាយកាយ មិនសប្បាយចិត្ត ឈ្មោះថាទុក្ខ ព្រោះជារបស់ដែលសត្វអត់ធន់បានដោយកម្រ ។

ទុក្ខសច្ចមាន ១២ ខទគឺ:

១- ជាតិទុក្ខ សេចក្ដីទុក្ខមានជាតិជាបច្ច័យ រាប់ចាប់ដើមតាំងអំពីថ្ងៃចូលមកចាប់បដិសន្ធិក្នុងផ្ទៃមាតា បានសេចក្ដីក្ដៅក្រហាយជានិរន្តរឥតស្រាកស្រាន្តឡើយ ;

២- ជរាទុក្ខ ទុក្ខព្រោះជរាជាបច្ច័យ រាប់តាំងអំពីប្រសូតិចេញចាកគភ៌មាតារៀងមក ដោយរូបកាយនេះចេះតែទ្រុឌទ្រោមគ្រាំគ្រាទៅ ;

៣- ព្យាធិទុក្ខ ទុក្ខព្រោះមានរោគបៀតបៀនយាយីជាបច្ច័យឲ្យឈឺចាប់ជានិច្ចឥតល្ហែល្ហើយ ;

៤- មរណទុក្ខ ទុក្ខព្រោះមានសេចក្ដីស្លាប់ជាបច្ច័យ កាលបើព្យាធិទុក្ខចូលមកលុកលុយរូបកាយយ៉ាងនេះហើយ មរណសង្គ្រាមក៏ទន្ទ្រានចូលមកជិត ម្ល៉ោះហើយសត្វក៏កើតសេចក្ដីទុក្ខព្រួយជាពន្លឹក ព្រោះឃើញមរណសង្គ្រាមទៅស្ទាក់រាំងពីមុខ ;

៥- សោកទុក្ខ ទុក្ខបណ្ដាលឲ្យស្ដាយស្រណោះអាឡោះអាល័យចំពោះសត្វ និងសង្ខារ(១) ជាទីស្រឡាញ់ពេញចិត្តដែលព្រាត់ប្រាសទៅ ;

៦- បរិទេវទុក្ខ ទុក្ខបណ្ដាលឲ្យត្អូញត្អែរ រៀបរាប់ពីការកំសត់កម្រផ្សេង ៗ និងសង្ខារដែលព្រាត់ប្រាសទៅ ;

៧- ទុក្ខ ទុក្ខ ទុក្ខលំបាកតែចំណែកផ្លូវកាយ ដោយការនឿយហត់ផ្សេង ៗ ;

៨- ទោមនស្សទុក្ខ ទុក្ខព្រោះសេចក្ដីអាក់អន់ ចំពោះអារម្មណ៍ដែលឃ្នើសចិត្ត ;

៩- ឧបាយាសទុក្ខ ទុក្ខបណ្ដាលឲ្យអាក់អួលទង្គិះ ដោយអាការតានតឹងក្នុងចិត្ត ព្រោះនឹកឃើញដល់សត្វនិងសង្ខារជាទីស្រឡាញ់ពេញចិត្តដែលព្រាត់ប្រាសទៅយូរហើយ ;

១០- អប្បិយេហិ សម្បយោគទុក្ខ ទុក្ខព្រោះជួបប្រសព្វសត្វនិងសង្ខារដែលមិនត្រូវចិត្ត ;

១១- បិយេហិ វិប្បយោគទុក្ខ ទុក្ខព្រោះព្រាត់ប្រាសនិរាសចាកសត្វនិងសង្ខារដែលខ្លួនពេញចិត្ត ;

(១) សត្វបានដល់កូន, ប្រពន្ធ, ប្ដី : សង្ខារបានដល់ទ្រព្យសម្បត្តិ ។

១២- យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ទុក្ខកើតមកពីប្រាថ្នារបស់មិនបានដូចបំណង ចង់បានរបស់ណា មិនបានរបស់នោះ ។

សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ទុក្ខទាំងអស់ប្រមូលមកមានតែឧបាទានក្ខន្ធទាំង ៥ ជាមេទុក្ខ ។

មានទុក្ខដទៃ ៧ យ៉ាងទៀតគឺ :

១- ទុក្ខ ទុក្ខ ទុក្ខវេទនាដែលប្រព្រឹត្តទៅ ក្នុងកាយនឹងចិត្តហើយ ព្រោះកាយសម្រាប់ទទួលនូវទុក្ខ ថែមទាំងទុក្ខដទៃមួយមកត្រួតទៀតជាពីរ ឈ្មោះថាទុក្ខទុក្ខ :

២- វិបរិណាមទុក្ខ វេទនាដែលសោយនូវសេចក្ដីសុខហើយកើតទុក្ខឡើងវិញ នាំឲ្យប្រាសចាកសេចក្ដីសុខឈ្មោះថាវិបរិណាមទុក្ខ,

៣- សង្ខារទុក្ខ សង្ខារដែលប្រព្រឹត្តទៅក្នុងភព ៣ ប្រកបដោយឧបេក្ខាវេទនាគឺ សេចក្ដីកើតនឹងវិនាសចូលទៅបៀតបៀន ឈ្មោះថា សង្ខារទុក្ខ ;

៤- បដិច្ឆន្នទុក្ខ អាពាធដែលប្រព្រឹត្តទៅក្នុងកាយនឹងចិត្តមានឈឺត្រចៀកនឹងធ្មេញជាដើម លុះតែមានគេសួរទើបដឹង កើតតែខាងក្នុងមិនប្រាកដដល់ភ្នែកអ្នកទាំងពួងឡើយ យ៉ាងនេះឈ្មោះថា បដិច្ឆន្នទុក្ខ ;

៥- អបដិច្ឆន្នទុក្ខ ជម្ងឺដែលមានសមុដ្ឋានផ្សេងៗ នូវអាការ ៣២

មានសក់ស្កូវជាដើម មិនចាំបាច់អ្នកណាសួរក៏គង់ដឹងបានដូច្នេះ ឈ្មោះថា អបដិច្ឆន្នទុក្ខ ;

៦- បរិយាយទុក្ខ ទុក្ខទាំងអស់លើកលែងតែទុក្ខទុក្ខមួយចេញទេ មានជាតិទុក្ខជាដើម ដែលមានក្នុងសច្ច ឈ្មោះថា បរិយាយទុក្ខ ;

៧- និប្បរិយាយទុក្ខ ចំណែកទុក្ខទុក្ខ ឈ្មោះថា បរិយាយទុក្ខ ;

ជាតិទុក្ខមាន ១០ យ៉ាងគឺ :

១- គព្ភោក្កន្តិមូលកទុក្ខ ទុក្ខដែលកំពុងនៅក្នុងគភ៌ជាមូល ;

២- គព្ភបរិហរណមូលកទុក្ខ ទុក្ខព្រួយនឹងរក្សាគភ៌ជាមូល;

៣- គព្ភវិបត្តិមូលកទុក្ខ ទុក្ខលំបាកព្រោះវិបត្តិចាកគភ៌ជាមូល ;

៤- វិជាយនមូលកទុក្ខ ទុក្ខលំបាកព្រោះកិរិយាប្រសូត្រចាកគភ៌ជាមូល ;

៥- ពហិនិក្ខមនមូលកទុក្ខ ទុក្ខលំបាកព្រោះកិរិយា ចេញចាកខាងក្រៅគភ៌មាតាជាមូល ;

៦- អត្តូបក្កមមូលកទុក្ខ ទុក្ខលំបាកព្រោះព្យាយាមរបស់ខ្លួន មានសម្លាប់ខ្លួនឯងជាដើម ជាមូល ;

៧- បរូបក្កមមូលកទុក្ខ ទុក្ខលំបាកព្រោះព្យាយាម នៃបុគ្គលដទៃ ជាមូល;

៨- ទុក្ខំ ទុក្ខដែលកើតក្នុងនរក ;

៩- ទុក្ខំ ទុក្ខដែលកើតក្នុងកំណើតនៃសត្វតិរច្ឆាន ;

១០- ទុក្ខំ ទុក្ខដែលកើតក្នុងកំណើតនៃប្រេតនិងអសុរកាយ សោយទុក្ខដោយសេចក្តីស្រេកឃ្លានជាដើម ។

សមុទយសច្ចៈ

សមុទយដែលប្រជុំឲ្យកើតកងទុក្ខទាំង ១២ កង បានដល់តណ្ហាទាំង ៣ គឺ : កាមតណ្ហា ១, ភវតណ្ហា ១, វិភវតណ្ហា ១ , បើចែកដោយពិស្តារមាន ១០៨ គឺ : តណ្ហាខាងក្រៅ ១៨ , តណ្ហាខាងក្នុង ១៨, រួមជា ៣៦, ចាត់ជាអតីត ៣៦ , អនាគត ៣៦ , បច្ចុប្បន្ន ៣៦ ត្រូវជា ១០៨ ។

តណ្ហាខាងក្រៅ ១៨ នោះគឺ ចែកតាមអាយតនៈខាងក្រៅ ៦ គឺរូប សំឡេង , ក្លិន , រស , ផោដ្ឋព្វៈ , ធម្មារម្មណ៍ ក្នុងអាយតនៈមួយៗ ចែកជាបីៗ គឺកាមតណ្ហា, ភវតណ្ហា វិភវតណ្ហាបី ៦ ដងត្រូវជា ១៨ ។

អាយតនៈខាងក្នុង ១៨ ទៀត ត្រូវជា ៣៦ ។

កាមតណ្ហាសេចក្តីប្រាថ្នាក្នុងរូបនោះ គឺឃើញរូបកាមគុណហើយត្រេកអរចំពោះទៅរកកាមតែម្យ៉ាង , ភវតណ្ហា ប្រកបដោយសស្សតទិដ្ឋិ យល់ឃើញថារូបនោះទៀងទាត់ឋិតថេរល្អជាដើម ហើយក៏ប្រាថ្នាទៅរករូបនោះៗ, វិភវតណ្ហា ប្រកបដោយឧច្ឆេទទិដ្ឋិ យល់ឃើញថារូបនេះស្លាប់ទៅសូន្យមិនកើតទៀត ចិត្តក៏ប្រព្រឹត្តធ្វើនូវអំពើទុច្ចរិតផ្សេងៗ ព្រោះយល់ឃើញថាសត្វស្លាប់ទៅសូន្យមិនកើតទៀត រូបនេះមិនមែនរូបដទៃៗ ពីណាមកទេ គឺរូបកាមដដែលគ្រាន់តែផ្សេងដោយទិដ្ឋិប៉ុណ្ណោះ អាយតនៈ ៥ ខាងចុងនេះ ចែកដូចគ្នានឹងរូប តែធម្មតណ្ហាខាងចុង ១ ប្រាថ្នាអារម្មណ៍ណាឆ្ងាយៗ ដែលភ្នែកត្រចៀកដឹងមិនដល់ ចិត្តស្រាវជ្រាវរំពឹងឃើញ ធម៌ក្នុងទីនេះមិនមែនធម៌មែនៗ នោះទេ គឺចំពោះធម្មារម្មណ៍តែម្យ៉ាង ទាំងនេះហៅថាតណ្ហាខាងក្រៅ ។

ចំណែកតណ្ហាខាងក្នុងគឺ ត្រេកអរនឹងអាយតនៈរបស់ខ្លួនឯង តណ្ហាខាងក្នុង ៦ នោះ ក៏ចែកដូចតណ្ហាខាងក្រៅនោះដែរ , តណ្ហានឹងលោភចិត្តនោះផ្សេងគ្នាតែបាលីទេ លោភចិត្តក៏ប្រកបដោយសស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិតណ្ហាក៏ប្រកបដោយទិដ្ឋិទាំងពីរនេះដែរ , បានជាតណ្ហាចាត់ជាអកុសលសុទ្ធ មិនមែនជាកុសលទេ; អ្នកខ្លះចូលចិត្តថា តណ្ហានាំសត្វឲ្យទៅកើតក្នុងឋានសួគ៌និងឋានព្រហ្ម ការចូលចិត្តដូច្នេះមិនត្រូវឡើយ,

ព្រោះសត្វដែលទៅកើតក្នុងឋានសួគ៌និងឋានព្រហ្មនោះ ទៅដោយអំណាចកុសលចិត្ត ចំណែកមនុស្សនិងឆកាមាវចរសួគ៌ទៅដោយកាមាវចរកុសល ៨ រូបព្រហ្ម ទៅដោយរូបាវចរកុសល ៥ អរូបព្រហ្ម ទៅដោយអរូបាវចរកុសល ៤ ឥតមាននិយាយពីតណ្ហានាំឲ្យបដិសន្ធិឡើយ, បើតណ្ហានាំឲ្យបដិសន្ធិក្នុងភពនោះៗ លោភចិត្តទាំង ៨ នោះ ក៏នាំឲ្យបដិសន្ធិក្នុងភពនោះៗ ដែរ, ព្រោះតណ្ហានិងលោភចិត្តប្រកបដោយទិដ្ឋិដូចគ្នា ។

ម្យ៉ាងទៀត ភពទាំងនោះមិនមែនរបស់តណ្ហាទេ ប៉ុន្តែមិនមែនកម្លាំងតណ្ហានាំទៅកើតឡើយ គឺកើតដោយអំណាចកុសលផ្សេងៗ ដូចអធិប្បាយរួចមកហើយ សេចក្តីនេះប្រៀបដូចជាខ្លែងមានខ្សែនិងខ្យល់ទើបឋិតនៅឯអាកាសបាន, សត្វដូចតួខ្លែង ខ្យល់ដូចជាកុសល តណ្ហាដូចជាខ្សែខ្លែង ខ្សែគ្រាន់តែទប់ខ្លែងមិនឲ្យទៅកាន់ទីដទៃទៀតបាន គឺតណ្ហាគ្រាន់តែទាញសត្វមិនឲ្យទៅកាន់ស្ថានព្រះនិព្វានប៉ុណ្ណោះឯង ។

ម្យ៉ាងវិញទៀត ធម៌ទាំង ៤ គឺអវិជ្ជា ១, តណ្ហា ១, ឧបាទាន ១, កម្ម ១, ដែលជាបច្ច័យឲ្យកើតនាមធម៌និងរូបធម៌នេះ មិនមែនខុសទេ ធម៌នោះគ្រាន់តែជាបច្ច័យទេតើ! មានណាទៅនាំបដិសន្ធិ ឲ្យសត្វខ្ពស់ទាប ល្អ អាក្រក់, ដែលល្អឬអាក្រក់នោះស្រេចលើកុសលរបស់សត្វដែលបានកសាងតិចច្រើន ។

ដែលចាត់ជាអតីតនោះ គឺអារម្មណ៍ដែលមកប៉ះពាល់កន្លងហួសទៅហើយ ចិត្តភវរកខាងក្រោយមិនមែនអតីតជាតិនោះទេ ; ចាត់ជាអនាគតនោះ គឺអារម្មណ៍ដែលមិនទាន់មានមក ចិត្តក៏ប្រុងទទួលអារម្មណ៍នោះៗ, បច្ចុប្បន្ននោះអារម្មណ៍កើតឡើងចំពោះមុខចិត្តក៏ប្រាថ្នានូវអារម្មណ៍នោះៗ ដូច្នេះឈ្មោះថាបច្ចុប្បន្ន ។

និរោធសច្ចៈ

ព្រះនិព្វានរំលត់បង់នូវកងទុក្ខទាំង ១២ កង ។ ព្រះនិព្វានមានឈ្មោះច្រើនយ៉ាងដូចតទៅនេះ វិរាគោ ព្រះនិព្វានប្រាសចាករាគៈ គឺតម្រេកក្នុងកាមផ្សេងៗ ១, និរោធោ ព្រះនិព្វានរំលត់បង់នូវគ្រឿងទុក្ខ ១, ចាគោ ព្រះនិព្វានលះបង់នូវតណ្ហា ១, បដិនិស្សគ្គោ ព្រះនិព្វានលះបង់ចំពោះនូវតណ្ហា ១, មុត្តិ ព្រះនិព្វានរួចផុតស្រឡះចាកអាសវៈដែលជាគ្រឿងត្រាំ ១, អនាលយោ ព្រះនិព្វានមិនមានសេចក្តីអាឡោះអាល័យក្នុងកាមគុណប្រាំ ១, រាគក្ខយោ ព្រះនិព្វានជាទីអស់ទៅនៃរាគៈ ១, ទោសក្ខយោ ព្រះនិព្វានជាទីអស់ទៅនៃទោសៈ ១, មោហក្ខយោ ព្រះនិព្វានជាទីអស់ទៅនៃមោហៈ ១, តណ្ហក្ខយោ ព្រះនិព្វានជាទីអស់ទៅនៃតណ្ហា ១, អនុប្បាទោ ព្រះនិព្វានមិនបានកើតទៀត ១, អប្បវត្តំ ព្រះនិព្វានមិនបានប្រព្រឹត្តទៅ ១, អនិមិត្តំ ព្រះនិព្វានមិនមាននិមិត្ត ១, អប្បណិហិតំ

ព្រះនិព្វានមិនមានអ្វីសម្រាប់ដំកល់នូវបញ្ចក្ខន្ធ ១, អនាយូហនំ ព្រះនិព្វានមិនបានប្រមូលមកនូវបញ្ចក្ខន្ធ ១, អប្បដិសន្ធិ ព្រះនិព្វានមិនមានបដិសន្ធិ ១, អប្បវត្តិ ព្រះនិព្វានមិនត្រឡប់មកវិញ ១, អគតិ ព្រះនិព្វានមិនមានដំណើរមកពីភពនេះទៅភពនោះទៀត ១, អជាតិ ព្រះនិព្វានមិនមាន ជាតិ ១, អជរំ ព្រះនិព្វានមិនមានចាស់ជរា ១, អព្យាធិ ព្រះនិព្វានមិនមានព្យាធិ ១, អមតំ ព្រះនិព្វានមិនចេះស្លាប់ ១, អសោកំ ព្រះនិព្វានមិនមានសេចក្តីសោកស្រណោះ ១, អប្បរិទេវំ ព្រះនិព្វានមិនមានសេចក្តីខ្សឹកខ្សួល ១, អនុបាយាសំ ព្រះនិព្វានមិនមានរអាក់រអួលក្នុងចិត្ត ១, អសង្កិលិដ្ឋំ ព្រះនិព្វានមិនមានសេចក្តីសៅហ្មង ១, ។ ពាក្យទាំងអស់នេះជាឈ្មោះរបស់ព្រះនិព្វាន ឬជាគុណរបស់ព្រះនិព្វាន ។

ដែលរំលត់នូវកងទុក្ខបាននោះ លុះតែរំលត់នូវតណ្ហាដែលជាមេបណ្តាលឲ្យកើតទុក្ខ បើតណ្ហាមាននៅឯភពណា, ទុក្ខក៏មាននៅឯភពនោះ, សមដូចពុទ្ធភាសិតទ្រង់សំដែងប្រៀបថា :

យថា បិមូលេអនុបទ្ទវេ ទឡ្ហេ ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ
ឯវំបិ តណ្ហានុសយេ អនុហតេ និព្វត្តេ ទុក្ខមិទំ បុនប្បុនំ ។

ដើមឈើដែលគេកាត់ដាច់ហើយ តែឫសនៅមាំមួនមិនទាន់មានសេចក្តីអន្តរាយខូចខាតកន្លែងណាទេ ក៏គង់ដុះឡើងបាន យ៉ាងណា

មិញ, តណ្ហានុស័យដែលព្រះយោគាវចរមិនទាន់កំចាត់បង់ដោយអរហត្តមគ្គញាណទេ សេចក្តីទុក្ខគង់កើតឡើងរឿយ ៗ ដូច្នោះឯង ។

មគ្គសច្ចៈ

អដ្ឋង្គិកមគ្គ ៨ ជាឧបាយរំលត់នូវកងទុក្ខគឺ :

១– សម្មាទិដ្ឋិ បញ្ញាយល់ត្រូវដូច្នេះគឺ ទុក្ខេញាណំ យល់ក្នុងកងទុក្ខទាំង ១២ ; ទុក្ខសមុទយេ ញាណំ យល់ក្នុងហេតុដែលបណ្តាលឲ្យកើតទុក្ខ, ទុក្ខនិរោធេ ញាណំ យល់ក្នុងកន្លែងដែលរលត់ទុក្ខ, ទុក្ខនិរោធគាមិនីយាបដិបទាយ ញាណំ យល់ក្នុងសេចក្តីប្រតិបត្តិដែលជាដំណើរទៅកាន់កន្លែងរំលត់ទុក្ខ ។ សម្មាទិដ្ឋិនេះមានពីរយ៉ាងគឺ លោកិយសម្មាទិដ្ឋិ បញ្ញាយល់ត្រូវជាលោកិយ គឺយល់ថាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ជាដើម ១ លោកុត្តរសម្មាទិដ្ឋិ បញ្ញាយល់ត្រូវជាលោកុត្តរ គឺយល់ក្នុងសច្ចៈទាំង ៤ មានទុក្ខសច្ចជាដើម ១ ។ សម្មាទិដ្ឋិនេះ បើចែកតាមឈ្មោះបុគ្គលវិញ មាន ៣ យ៉ាងគឺ បុថុជ្ជនសម្មាទិដ្ឋិ បញ្ញាយល់ត្រូវរបស់បុថុជ្ជន ១, សេក្ខសម្មាទិដ្ឋិ បញ្ញាយល់ត្រូវរបស់សេក្ខបុគ្គល ៧ ចំពូក មានសោតាបត្តិមគ្គដ្ឋៈជាដើម មានអរហត្តមគ្គដ្ឋៈជាបរិយោសាន១, អសេក្ខសម្មាទិដ្ឋិ បញ្ញាយល់ត្រូវរបស់អសេក្ខបុគ្គល គឺព្រះអរហន្ត ១ ;

២ – សម្មាសង្កប្បោ តំនិតត្រិះរិះត្រូវ គឺ នេក្ខម្មសង្កប្បោ ត្រិះរិះដើម្បីចេញចាកកាម ១, អព្យាបាទសង្កប្បោ ត្រិះរិះដើម្បីមិនព្យាបាទគេ ១, អវិហឹសាសង្កប្បោ ត្រិះរិះដើម្បីមិនបៀតបៀនគេ ១ ;

៣ – សម្មាវាចា សំដីនិយាយត្រូវគឺ មុសាវាទាវេរមណី វៀរពាក្យកុហក ១, បិសុណាវាចាវេរមណី វៀរពាក្យញុះញង់ឬអុជអាល ១; ផរុសវាចាវេរមណី វៀរពាក្យទ្រគោះឃ្លើសឃ្លង ១, សម្ផប្បលាបាវេរមណី វៀរពាក្យឥតប្រយោជន៍ ១;

៤ – សម្មាកម្មន្តោ ការងារត្រូវគឺបាណាតិបាតាវេរមណី វៀរបាណាតិបាត ១, អទិន្នាទានាវេរមណី វៀរអទិន្នាទាន ១, កាមេសុមិច្ឆាចារាវេរមណី វៀរប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១, ហើយប្រព្រឹត្តធ្វើនូវកុសលដែលសម្រេចដោយនូវកាយ មានបោសប្រាសទីលានព្រះចេតិយជាដើម ;

៥ – សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ លះមិច្ឆាជីវៈ គឺ ការចិញ្ចឹមជីវិតខុស បើគេហស្ថលះបង់ជំនួញមិនគួរជួញ ៥ ប្រការជាដើម, បើអ្នកបួសត្រូវលះបង់អនេសនៈ ២១ និងបាបធម៌ ៥ ជាដើម ,

៦ - សម្មាវាយាមោ ព្យាយាមត្រូវគឺ ព្យាយាមផ្គងចិត្តឡើង ដើម្បីមិនឲ្យកើតអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង ១ ;

ដើម្បីលះបង់អកុសលធម៌ដែលកើតឡើងហើយ ១ , ដើម្បីញុំាងកុសលធម៌ដែលមិនទាន់កើតឲ្យកើតឡើង ១ , និងដើម្បីញុំាងកុសលធម៌ដែលកើតឡើង ហើយឲ្យឋិតថេរនៅឲ្យពេញលេញជាភិយ្យោភាពឡើង ១ ;

៧– សម្មាសតិ រឭកត្រូវគឺ រឭកក្នុងសតិប្បដ្ឋាន ៤ កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក និងរឭកក្នុងអនុស្សតិទាំង ១០ យ៉ាង ;

៨ - សម្មាសមាធិ ដំកល់ចិត្តត្រូវគឺ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមចាកអកុសលធម៌ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កវិចារៈ មានបីតិនិងសុខដែលកើតអំពីវិតក្កៈ លុះរម្ងាប់បង់នូវវិតក្កៈវិចារៈ ហើយ ចូលកាន់ទុតិយជ្ឈានដែលសទ្ធាដ៏ថ្លាផូរផង់តាំងនៅក្នុងខាងក្នុង ជាគ្រឿងញុំាងសមាធិចិត្តយ៉ាងឯកឲ្យកើតឡើង មិនមានវិតក្កៈវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសមាធិ ។ ជាអ្នកព្រងើយកន្តើយ ព្រោះខ្ពើមបីតិ មានស្មារតីមានប្រាជ្ញាដឹងសព្វនិងសោយសុខដោយកាយផង រួចចូលកាន់តតិយជ្ឈាន ចូលកាន់ចតុត្ថជ្ឈាន មានស្មារតីដ៏ស្អាតដែលកើតអំពីឧបេក្ខាឥតទុក្ខឥតសុខឡើយ ព្រោះលះបង់នូវសុខនិងទុក្ខផង , ព្រោះអស្តង្គតរលត់ទៅនៃសោមនស្សនិងទោមនស្សអំពីមុនផង យ៉ាងនេះទើបឈ្មោះថា សម្មាសមាធិ ។

អត្ថរបស់អរិយសច្ចៈទាំង ៤

ទុក្ខសច្ចមានអត្ថ ៤ គឺ :

១- បីឡនត្ថោ　មានអត្ថថាបៀតបៀននូវសត្វ ;

២- សង្ខតត្ថោ　មានអត្ថថាជាធម៌　គឺបច្ច័យទាំងឡាយ មានតណ្ហាជាដើមចោមប្រជុំតាក់តែងឲ្យកើត ;

៣- សន្តាបត្ថោ　មានអត្ថថាញុំាងសត្វឲ្យក្តៅក្រហាយ អន្ទះអន្ទែង ;

៤- បរិណាមត្ថោ　មានអត្ថថាចេះតែប្រែប្រួលមិនឋិតថេរ ចិរកាល ។

សមុទយសច្ចៈ មានអត្ថ ៤ គឺ :

១- អាយុហនត្ថោ　មានអត្ថថាកៀរគរសេចក្តីទុក្ខឲ្យកើត

២- និទានត្ថោ　មានអត្ថថា នាំយកសេចក្តីទុក្ខមកប្រគល់ឲ្យ ជាផលរបស់ខ្លួន ;

៣- សំយោគត្ថោ　មានអត្ថថាប្រកបទាក់ចងសត្វដោយ សេចក្តីទុក្ខ ;

៤- បលិពោធនត្ថោ　មានអត្ថថាធ្វើឲ្យសត្វរវល់រំខានចិត្ត

ស្កាក់ដំណើរមិនឲ្យបាននូវមគ្គនិងផល ។

និរោធសច្ចៈមានអត្ថ ៤ គឺ :

១- និស្សរណត្ថោ　មានអត្ថថារលាស់ចោលនូវឧបធិធម៌ ដែលសំរាប់ឲ្យសេចក្តីទុក្ខចូលទៅអែបនែបនៅ

២- វិវេកត្ថោ　មានអត្ថថាស្ងប់ស្ងាត់ក្នុងសង្ខារទាំងពួង ·

៣- អសង្ខតត្ថោ　មានអត្ថថាលែងមានធម៌ជាបច្ច័យ ប្រជុំ តាក់តែងឲ្យកើតទៀត ;

៤- អមតត្ថោ　មានអត្ថថាជាធម្មជាតិមិនចេះស្លាប់ ព្រោះជា របស់ទៀង ។

មគ្គសច្ចៈមានអត្ថ ៤ គឺ :

១- និយ្យានត្ថោ មានអត្ថថាដឹកជញ្ជូនសត្វឲ្យចេញពីវដ្តសង្សារ;

២- ហេតុត្ថោ　មានអត្ថថាជាហេតុញុំាងសត្វឲ្យដល់ព្រះនិព្វាន ;

៣- ទស្សនត្ថោ　មានអត្ថថាឃើញនូវព្រះនិព្វានដែលជាធម៌ដ៏ ល្អិតសុខុមយ៉ាងក្រៃលែង ។

៤- អធិបតេយ្យត្ថោ　មានអត្ថថាជាអធិបតីនៃសម្បយុត្តធម៌ ក្នុងកិរិយាឃើញនូវព្រះនិព្វាន ។

លក្ខណៈកិច្ចនឹងផលនៃអរិយសច្ចទាំង ៤

ពាធនលក្ខណំ ទុក្ខសច្ចំ *ទុក្ខសច្ចមានកិរិយាបៀតបៀន (នូវបញ្ចក្ខន្ធ) ជាលក្ខណៈ ;*

សន្តាបនរសំ ទុក្ខសច្ចំ *ទុក្ខសច្ចមានកិរិយាក្តៅក្រហាយជាកិច្ច,*

បវត្តិប្បច្ចុប្បដ្ឋានំ ទុក្ខសច្ចំ *ទុក្ខសច្ចមានកិរិយាប្រព្រឹត្តទៅជាផល ។*

បភវលក្ខណំ សមុទយសច្ចំ *សមុទយសច្ច មានភវៈជាដែនកើត (នៃទុក្ខ) ជាលក្ខណៈ ;*

អនុបច្ឆេទករណរសំ សមុទយសច្ចំ *សមុទយសច្ច មានកិរិយាមិនធ្វើនូវការផ្តាច់បង់ជាកិច្ច ;*

បលិពោធប្បច្ចុប្បដ្ឋានំ សមុទយសច្ចំ *សមុទយសច្ច មានកិរិយារវល់រំខានចិត្តជាផល ។*

សន្តិលក្ខណំ និរោធសច្ចំ *និរោធសច្ច មានកិរិយាស្ងប់រម្ងាប់ជាលក្ខណៈ ;*

អច្ចុតិរសំ និរោធសច្ចំ *និរោធសច្ច មានកិរិយាមិនច្យុតិជាកិច្ច;*

អនិមិត្តប្បច្ចុប្បដ្ឋានំ និរោធសច្ចំ *និរោធសច្ច មានកិរិយាមិនមាននិមិត្តជាផល ។*

និយ្យានលក្ខណំ មគ្គសច្ចំ *មគ្គសច្ច មានកិរិយានាំ (នូវសត្វចេញពីវដ្តសង្សារ) ជាលក្ខណៈ ;*

កិលេសប្បហានករណរសំ មគ្គសច្ចំ *មគ្គសច្ច មានកិរិយាធ្វើនូវការលះបង់នូវកិលេសជាកិច្ច ;*

វុដ្ឋានប្បច្ចុប្បដ្ឋានំ មគ្គសច្ចំ *មគ្គសច្ច មានកិរិយាចេញចាកកិលេសជាផល ។*

ឧបមារបស់អរិយសច្ច

ភារោ វិយ ហិ ទុក្ខសច្ចំ *ទុក្ខសច្ច ឧបមាដូចជាគ្រឿងធ្ងន់ដែលនៅលើស្មា (អម្រែក)*, ភារាទានមិវ សមុទយសច្ចំ *សមុទយសច្ច ដូចជាហេតុរបស់ធ្ងន់*, ភារនិក្ខេបនមិវ និរោធសច្ចំ *និរោធសច្ច ឧបមាដូចជាកិរិយាដាក់ចុះនូវគ្រឿងធ្ងន់ចេញអំពីស្មា ;* ភារនិក្ខេបនុប្បាយោ វិយ មគ្គសច្ចំ *មគ្គសច្ច ឧបមាដូចជាឧបាយដាក់នូវទម្ងន់ចេញ ។*

ម្យ៉ាងទៀតថា រោគោ វិយ ទុក្ខសច្ចំ *ទុក្ខសច្ច ដូចជាភាគ...ដោតនូវរាងកាយ ។* រោគនិទានមិវ សមុទយសច្ចំ

សមុទយសច្ច ដូចជាពិសរបស់រោគ រោគវូបសមោរិយ និរោធសច្ចំ និរោធសច្ច ដូចជាកិរិយាសះស្បើយទៅនៃរោគ, ភេសជ្ជមិវ មគ្គសច្ចំ មគ្គសច្ចៈ ដូចជាថ្នាំសម្រាប់រម្ងាប់នូវរោគ ។

ម្យ៉ាងវិញទៀតថា ទុព្ភិក្ខមិវ ទុក្ខសច្ចំ ទុក្ខសច្ច ដូចជាស្រុកទុរ្ភិក្សអត់បាយ, ទុព្វុដ្ឋិ វិយ សមុទយសច្ចំ សមុទយសច្ច ដូចជាស្រុកមានភ្លៀងមិនស្រួល (គឺរាំងភ្លៀង) សុភិក្ខមិវ និរោធសច្ចំ និរោធសច្ច ដូចជាស្រុកសម្បូណ៌ដោយអាហារ សុវុដ្ឋិ វិយ មគ្គសច្ចំ មគ្គសច្ចៈ ដូចជាស្រុកមានភ្លៀងល្អ ។

ទុក្ខសច្ច មានខន្ធ ៥ ជាមេទុក្ខ គួរឲ្យខ្លាចប្រៀបដូចមេខ្មាំង ៥ នាក់តាមពាធាយាយីជាធម្មតា ; សមុទយសច្ច តណ្ហាទាំង ៣ ប្រការដូចជាអ្នកបង្ហាញខ្មាំងឲ្យចូលមក ; និរោធសច្ច ព្រះនិព្វានជាគ្រឿងបិទស្ទះដំណើរខ្មាំង មគ្គសច្ច អដ្ឋង្គិកមគ្គទាំង ៨ ជាឧបាយសម្លាប់ពួកខ្មាំង ។

ទុក្ខសច្ច ជាបរិញ្ញាកិច្ច ជាកិច្ចគឺព្រះយោគាវចរគប្បីកំណត់ដឹង ; សមុទយសច្ច ជាបហានកិច្ច ជាកិច្ចគឺព្រះយោគាវចរគប្បីលះបង់ ; និរោធសច្ច ជាសច្ឆិកាតព្វកិច្ច ជាកិច្ចគឺព្រះយោគាវចរគប្បីធ្វើឲ្យជាក់ច្បាស់ មគ្គសច្ច ជាភាវេតព្វកិច្ច ជាកិច្ចគឺព្រះយោគាវចរគប្បីចំរើន ។

កិច្ចទាំង ៤ នេះក្នុងមគ្គមួយៗ មាន ៤ ១ គឺសោតាបត្តិមគ្គមានកិច្ច ៤ , សកទាគាមិមគ្គមានកិច្ច ៤ អនាគាមិមគ្គមានកិច្ច ៤ , អរហត្តមគ្គមានកិច្ច ៤, បួន ១ ដងត្រូវជា ១៦ ហៅថាសោឡសកិច្ច ។

អធិប្បាយមកក្នុងអរិយសច្ចដោយសង្ខេបប៉ុណ្ណោះ ដើម្បីជាភ័ស្តុតាងដល់អស់លោក អ្នកដែលបានមើលគ្រាន់ជាឧបាយគំនិតប្រាជ្ញា មិនបានអធិប្បាយឲ្យពិស្ដារទេ សូមលោក អ្នកមើលក្នុងគម្ពីរវិសុទ្ធិមគ្គឯនោះទើបមានសេចក្ដីពិស្ដារជាងនេះទៀត ។

ចប់ ចតុក្កៈ , ពួក ៤

បញ្ចកៈ ពួក ៥

អនន្តរិយកម្ម ៥ យ៉ាង

១ – មាតុឃាត សម្លាប់មាតា ;

២ – បិតុឃាត សម្លាប់បិតា ;

៣– អរហន្តឃាត សម្លាប់ព្រះអរហន្ត ;

៤ – លោហិតុប្បាទ ប្រទូស្តព្រះពុទ្ធអង្គរហូតដល់ញុំាងព្រះលោហិតឲ្យពុរពង ឬឲ្យជាំដាំ ;

៥ – សង្ឃភេទ ញុំាងសង្ឃឲ្យបែកគ្នា ។

អធិប្បាយថា :

កម្ម ៥ យ៉ាងនេះបាបធ្ងន់ ឃាត់សួគ៌ ឃាត់ព្រះនិព្វានតាំងនៅក្នុងឋានៈជាបរាជិករបស់អ្នកកាន់ព្រះពុទ្ធសាសនា ហាមមិនឲ្យធ្វើយ៉ាងដាច់ខាត ។

អនន្តរិយកម្ម ប្រែថា កម្មដែលឲ្យផលគ្មានចន្លោះ គឺមិនមានកម្មដទៃៗ នឹងជ្រៀតជ្រែកឲ្យផលមុនបាន កាលបើចុតិចាកភពនេះទៅហើយ ត្រូវទៅកើតក្នុងអវិចីនរកជាមិនខាន ។ ន័យមួយទៀតថា ជាកម្មដែលធ្ងន់បំផុត មិនមានកម្មឯណា ៗ នឹងធ្ងន់ជាងអនន្តរិយកម្មនេះមិនមាន ។ បណ្តាកម្មដែលជាបាបដូចគ្នាក្នុងផ្លូវព្រះពុទ្ធសាសនា បញ្ញាតិអកុសលកម្ម គឺអនន្តរិយកម្មនេះថាជាបាបធ្ងន់យ៉ាងក្រៃលែង បណ្តាអ្នកកាន់ព្រះពុទ្ធ-

សាសនា បើធ្វើកម្មនេះហើយ ត្រូវតាំងនៅក្នុងឋានៈជាបរាជិក គឺដាច់ចាកព្រះពុទ្ធសាសនា ។ មាតាបិតាចាត់ជាបុព្វបុរសរបស់ត្រកូលមានគុណានុគុណយ៉ាងក្រៃលែង ។ ជនណាសម្លាប់មាតាបិតារបស់ខ្លួនយ៉ាងនេះហើយ មុខជាហ៊ានសម្លាប់មនុស្សដទៃក្នុងពេលដែលខ្លួនក្រោធខឹង ។ ព្រះអរហន្តលោកមានកាយវាចារៀបរយល្អ មិនដែលប្រទូស្តដល់ជនណាឡើយ ហើយជាទីពឹងអានរបស់មហាជនផង ។ អ្នកណាហ៊ានសម្លាប់ព្រះអរហន្តហើយ អ្នកនោះឈ្មោះថាបំផ្លាញសេចក្តីពឹងអានរបស់មហាជន , មួយទៀតក្នុងពេលដែលខ្លួនក្រោធខឹង មុខជាហ៊ានសម្លាប់អ្នកដទៃមិនខានឡើយ ។ មនុស្សដែលហ៊ានប្រទូស្តព្រះពុទ្ធអង្គជាព្រះសាស្តារបស់ខ្លួនឯង រហូតដល់ញុំាងព្រះលោហិតឲ្យពុរពង ឬឲ្យជាំដាំដោយអាការផ្សេង ៗ ហើយ ក៏ឈ្មោះថាអស់គោលក្នុងផ្លូវព្រះពុទ្ធសាសនា ដូចជាមនុស្សដែលគិតក្បត់ប្រទូស្តព្រះរាជាម្ចាស់ផែនដីរបស់ខ្លួន ។ ភិក្ខុអ្នកញុំាងសង្ឃឲ្យបែកគ្នាចេញទៅជាពួក ៗ បើហ៊ានបំបែកគណៈរបស់ខ្លួនដូច្នេះហើយ គណៈដទៃដែលមិនមែនជាគណៈរបស់ខ្លួនមុខជាហ៊ានបំបែកមិនខានឡើយ ដូចមនុស្សដែលគិតញុះញង់ធ្វើឲ្យជាតិរបស់ខ្លួនបែកសាមគ្គីគ្នា ។

បុ– អនន្តរិយកម្ម ទាំង ៥ ណាមានទោសធ្ងន់ជាងគេ ?

វិ– អនន្តរិយកម្ម ទាំង ៥ សង្ឃភេទ មានទោសធ្ងន់ជាងគេ

បន្ទាប់មក លោហិតុប្បាទ តមកអរហន្តឃាត តមកទៀត មាតុឃាត ឯ បិតុឃាត មានទោសស្រាលជាងគេតែគង់ធ្លាក់ទៅអវិចីនរកមិនខាន ។

បុ– គ្រហស្ថធ្វើ អនន្តរិយកម្ម បានទាំង ៥ ឬទេ ?

វិ – គ្រហស្ថធ្វើបានតែ ៤ ទេ លើកសង្ឃភេទមួយចេញ ។ ឯសង្ឃភេទធ្វើបានតែបព្វជិតជាភិក្ខុ ។

បុ– អនន្តរិយកម្មទាំង ៥ បើបុគ្គលធ្វើគ្រប់ទាំង ៥ តើទៅសោយទុក្ខគ្រប់អំពើទាំង ៥ ដែរឬ ?

វិ – បើបុគ្គលណាធ្វើ អនន្តរិយកម្មទាំង ៥ នេះហើយ បុគ្គលនោះតែងទៅសោយទុក្ខតាមកម្មណាដែលមានទោសធ្ងន់ជាងគេ ។

បុ – ចុះទោសសល់នោះទៅឯណាទៅ ?

វិ – ទោសសល់ពីនោះជាអហោសិកម្ម ។

បុ– អហោសិកម្ម ប្រែថាម៉េច ?

វិ – អហោសិកម្ម ប្រែថា កម្មមិនឲ្យផល ឬកម្មក្រិន ។

អភិណ្ហប្បច្ចវេក្ខណៈ ៥ យ៉ាង

១ – ជរាធម្មោម្ហិ អាត្មាអញមានសេចក្ដីចាស់ជរាជាធម្មតា មិនកន្លងសេចក្ដីចាស់ជរាបានឡើយ ;

២ – ព្យាធិធម្មោម្ហិ អាត្មាអញមានសេចក្ដីឈឺចាប់ជាធម្មតា

មិនកន្លងសេចក្ដីឈឺចាប់បានឡើយ ;

៣– មរណធម្មោម្ហិ អាត្មាអញមានសេចក្ដីស្លាប់ជាធម្មតា មិនកន្លងសេចក្ដីស្លាប់បានទេ ;

៤– សព្វេហិមេបិយេហិ អាត្មាអញមានសេចក្ដីព្រាត់ប្រាសចាករបស់ជាទីគាប់ចិត្តទាំងអស់ ;

៥– កម្មស្សកោម្ហិ អាត្មាអញមានកម្មជារបស់ខ្លួន , អាត្មាអញធ្វើកម្មល្អនឹងបានផលល្អ , ធ្វើកម្មអាក្រក់បានផលអាក្រក់ ។

អធិប្បាយថា :

គ្រហស្ថបព្វជិតគួរពិចារណាធម៌ ៥ ប្រការនេះជានិច្ចដូចមានបាលីខាងដើមស្រាប់ ។ ការពិចារណាក្នុងធម៌ ៥ ប្រការនេះជាវិបស្សនាការនាមួយយ៉ាង ដែលធ្វើឲ្យអ្នកពិចារណារឿយ ៗ បាត់ប្រមាទក្នុងវ័យ ក្នុងសេចក្ដីមិនមានរោគ ក្នុងជីវិត ក្នុងសេចក្ដីតម្រេក ក្នុងសេចក្ដីប្រព្រឹត្តខុសចេញបាន ។ ធម្មតាអ្នកប្រមាទ ច្រើនតែស្រវឹងក្នុងការប្រព្រឹត្តទុច្ចរិតព្រោះហេតុមិនបានពិចារណានឹកដល់អារម្មណ៍ទាំងនេះ ឲ្យដឹងច្បាស់តាមពិតថា ជាយ៉ាងដូចម្ដេចទើបបានជាប្រមាទថា វេលានេះយើងនៅជាកម្លោះក្រមុំ មិនទាន់ចាស់ មិនទាន់ឈឺ មិនទាន់ស្លាប់ងាយទេបើនឹងចាស់ក៏ទាល់តែដល់អាយុកន្លងទៅច្រើនហើយ នឹងឈឺទាល់តែដល់

ចាស់ជរា នឹងស្លាប់គឺទាល់តែដល់ចាស់ ។ សេចក្តីប្រមាទនាំឲ្យយល់ឃើញវិបរិតដូច្នេះជាហេតុបណ្តាលឲ្យភ្លេចស្មារតី កំរើកចិត្តគិតស្វែងរកចំពោះតែកាមារម្មណ៍ ដែលជាគ្រឿងបំភាន់ខ្លួនមិនឲ្យប្រព្រឹត្តត្រូវតាមធម៌, តែខ្លួនយល់ឃើញថាជាគន្លងផ្លូវនៃសេចក្តីសុខ ការប្រព្រឹត្តអាក្រក់នោះក៏ត្រឡប់ក្លាយឲ្យកើតទុក្ខតទៅក្នុងកាលជាខាងក្រោយ ។ ព្រោះតែសេចក្តីស្រវឹងច្រើនដូច្នេះហើយ ទើបមិនដឹងច្បាស់តាមពិត ។ បើអ្នកណាឧស្សាហ៍ពិចារណារឿយ ៗ ហើយ សេចក្តីប្រមាទក្នុងអារម្មណ៍នោះ ៗ ក៏ស្រាលស្តើងបានខ្លះសេចក្តីប្រព្រឹត្តខុស សំគាល់ខុសក៏ថយចុះទៅតាមគ្នាជាលំដាប់ ។ ចំណែកអ្នកដែលមិនបានពិចារណាក្នុងវិយោគធម៌ គឺសេចក្តីព្រាត់ប្រាសទេ លុះដល់វត្ថុទាំងនោះវិនាសទៅអ្នកនោះតែងមានសេចក្តីសោកទោមនស្ស កើតទុក្ខ, នឹងជាហេតុធ្វើចិត្តឲ្យរីករាយក្នុងកាលជួបប្រទះឥដ្ឋារម្មណ៍ ដែលជាមូលហេតុឲ្យប្រព្រឹត្តទុច្ចរិតផ្សេង ៗ ទៀតបាន ។ បើអ្នកណាឧស្សាហ៍នឹកពិចារណារឿយ ៗ ហើយ កាលដល់គ្រាវិបត្តិដ៏មិនកើតទោមនស្សពេកដល់គ្រាជួបប្រទះសម្បត្តិ ក៏មិនសោមនស្សពេក ។ ឯអ្នកដែលឧស្សាហ៍ពិចារណានឹកដល់កម្មល្អនិងអាក្រក់, ដែលជាអតីតក្តី អនាគតក្តី បច្ចុប្បន្នក្តីរមែងជាហេតុឲ្យឃើញច្បាស់ថា កម្មដែលអាត្មាអញធ្វើជារបស់អាត្មាអញបើអាត្មាអញធ្វើល្អនិងបានទទួលផលល្អ បើអាត្មាអញ

ធ្វើអាក្រក់និងបានទទួលផលអាក្រក់ ដូច្នេះជាហេតុឲ្យលះអំពើអាក្រក់ចេញ ប្រព្រឹត្តអំពើល្អ នឹងមិនកាន់តាមលទ្ធិដែលយល់ខុស ក៏ព្រោះមានការដឹងតាមពិតដូច្នេះឯង ។

វេសារជ្ជករណធម៌ ៥ យ៉ាង

១ – សទ្ធា ជឿរបស់ដែលគួរជឿ ;

២ – សីល រក្សាកាយវាចាឲ្យរៀបរយ ;

៣ – ពាហុសច្ចៈ ភាពជាអ្នកសិក្សារៀនសូត្រច្រើន ,

៤ – វីរិយារម្ភៈ ប្រារព្ធសេចក្តីព្យាយាម ;

៥ – បញ្ញា ដឹងរបស់ដែលគួរដឹង

អធិប្បាយថា :

ពាក្យថា „ វេសារជ្ជករណធម៌ ,, ធម៌ដែលធ្វើឲ្យក្លាហាន បានដល់បុគ្គលណាប្រតិបត្តិវេសារជ្ជករណធម៌នេះ បានតែ ២-៣-៤ ប្រការ មិនបានគ្រប់ទាំង ៥ ទេ បុគ្គលនោះរមែងជាអ្នកអង់អាច ក្លាហានក្នុងការចូលទៅកាន់ទីប្រជុំក៏មិនខ្លាច មិនកោតញញើត នឹងសន្ទនាប្រាស្រ័យរកអ្នកណា ក៏មិនញាប់ញ័រកើតភ័យឡើយ ព្រោះហេតុនេះធម៌ទាំង ៥ យ៉ាងនេះឯង ទើបមាននាមថា វេសារជ្ជករណធម៌ ។ ក្នុងធម៌មួយ ៗ នោះមានឧទាហរណ៍ដូចតទៅនេះ (លើកយកការប្រតិបត្តិ

ធម៌វិន័យមកជាឧទាហរណ៍) សទ្ធា ការប្រតិបត្តិធម្មវិន័យនោះ អ្នកប្រតិបត្តិត្រូវមានសេចក្ដីជឿ គឺជឿថាព្រះធម្មវិន័យនោះ ជានិយ្យានិកធម៌ នាំសត្វឲ្យផុតទុក្ខបានពិត ហើយមានគុណានុភាព អាចនឹងគ្រប់គ្រងអ្នកប្រតិបត្តិមិនឲ្យធ្លាក់ទៅក្នុងទីអាក្រក់បានដោយពិត ហើយមានសេចក្ដីជឿក្នុងចិត្តខ្លួនទៀតថា ការប្រតិបត្តិនោះ ខ្លួនអាចនឹងប្រតិបត្តិបានហើយ នាំឲ្យបានសម្រេចប្រយោជន៍សមតាមបំណង ប្រយោជន៍ដែលខ្លួននឹងបានមកនោះក៏ព្រោះសេចក្ដីប្រតិបត្តិ មិនមែនបានមកដោយផ្លូវដទៃទេ ។ កាលបើមានសេចក្ដីជឿស៊ប់ដូច្នេះហើយ មុខជាកើតក្លាហានរីករាយចិត្តក្នុងកុសលមិនខាន អាចដឹកនាំឲ្យរឹតខំប្រតិបត្តិធម៌វិន័យដោយឥតរួញរា ។ សូម្បីបើមានឧបសគ្គយ៉ាងណាក៏អាចរកឧបាយជ្រៀតជ្រែក ទំលុះទំលាយកំចាត់បង់ឧបសគ្គនោះៗ ចេញបាន លែងខ្លាចកោតញញើត ចេះតែខំព្យាយាមប្រតិបត្តិទៅ ដរាបដល់បានសម្រេចផល ព្រោះហេតុយ៉ាងនេះ សទ្ធា ទើបចាត់ថាជា វេសារជ្ជករណធម៌ ប្រការ ១ ។

សីល បុគ្គលអ្នកមានកាយវាចារៀបរយ គឺវៀរចាកការប្រព្រឹត្តិអាក្រក់ទាំងកាយទាំងវាចា ជាមនុស្សសុភាពរាបសា នឹងទៅក្នុងទីណាកន្លែងណាក៏មិនកោតញញើតខ្លាចគយន្ដរាយឡើយ មានសេចក្ដីអង់អាចជានិច្ច សូម្បីនឹងចូលទៅកាន់ទីប្រជុំណា ៗ ក៏ក្លាហានមិនខ្លាច

នរណាតិះដៀលថាជាអ្នកខូចកាច ព្រោះសេចក្ដីប្រព្រឹត្តរបស់ខ្លួនឡើយ ហេតុនេះ សីលទើបចាត់ថាជា វេសារជ្ជករណធម៌ ប្រការ ១ ។

ពាហុសច្ចៈ ភាពនៃបុគ្គលជាអ្នករៀនសូត្រច្រើន គឺជាអ្នកបានសិក្សាសិល្បវិជ្ជាច្រើន និយាយឲ្យងាយថា មនុស្សរៀនសូត្រច្រើនរមែងជាអ្នកឈ្លាសវៃក្នុងអត្ថធម៌ នឹងចូលទៅកាន់ទីប្រជុំណា ៗ ក៏មិនជាអ្នកខ្លាចកោតញញើត រមែងជាអ្នកឈ្លាសវៃក្នុងការចរចា អាចកែខប្រស្នាផ្សេង ៗ ដែលជ្រាលជ្រៅសុខុមបានដោយលំដាប់មិនតិតក់យកោតខ្លាចអ្នកណាដែលគេសួរ ហើយអាចឆ្លើយតបទៅគេវិញបាន ដោយហេតុនេះ ពាហុសច្ចៈ ទើបចាត់ថាជា វេសារជ្ជករណធម៌ប្រការ ១ ។

វីរិយារម្ភៈ ការបំពេញសេចក្ដីព្យាយាម គឺតាំងសេចក្ដីព្យាយាមមិនបានឈប់ មានសេចក្ដីក្លាហានមោះមុត មិនខ្លាចឧបសគ្គណាមួយដែលមានក្នុងចន្លោះ ៗ បំណាងផលគឺការបានសម្រេចជាទីបំផុតតែគប្បីចូលចិត្តថាសេចក្ដីព្យាយាមក្នុងទីនេះ សំដៅយកការប្រព្រឹត្តទៅក្នុងផ្លូវលោកផ្លូវធម៌ដែលមិនមានទោស បណ្ឌិតមិនគប្បីតិះដៀលបាន ហៅថា វីរិយារម្ភៈ ។

បញ្ញា បុគ្គលអ្នកមានបញ្ញាឈ្លាសវៃ ក្នុងហេតុនៃសេចក្ដីសាបសូន្យ នឹងហេតុនៃសេចក្ដីចំរើន រមែងចូលចិត្តក្នុងកិរិយាប្រកបកិច្ច

ការមិនបង្អង់ អាចញ៉ាំងប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃឲ្យសម្រេចបាន កាលបើភ័យអន្តរាយតាំងនៅជុំវិញទិស រមែងអាចរិះរកការបន្ធូរបន្ថយកែខៃឲ្យការងារនោះសម្រេច រហូតទៅបានដោយសួស្តី បើទុកជាការងារនោះ ៗ លំបាកយ៉ាងណាក៏ដោយ ក៏អាចកែខៃបាន ទាំងអស់មិនគេចញញើតចំពោះសេចក្តីលំបាកនោះ ៗ ដោយអំណាចចិត្តមានកម្លាំងគឺបញ្ញដែលគួរឲ្យក្លាហាន អាចញ៉ាំងកិច្ចការនោះឲ្យសម្រេចតាមសេចក្តីដែលបានគ្មមក ព្រោះហេតុនេះ បញ្ញាទើបថាជាវេសារជ្ជករណធម៌ដោយប្រការដូច្នេះឯង ។

អង្គនៃភិក្ខុបួសថ្មី ៥ យ៉ាង

១- សង្រួមក្នុងព្រះបាតិមោក្ខ គឺវៀរចាកទោសដែលទ្រង់ហាម ធ្វើតាមតែទ្រង់អនុញ្ញាត ;

២- សង្រួមឥន្ទ្រិយគឺប្រយ័ត្នភ្នែក, ត្រចៀក, ច្រមុះ អណ្តាត. កាយ, ចិត្ត មិនឲ្យសោមនស្សទោមនស្សគ្របសង្កត់ចិត្តក្នុងវេលាដែលបានឃើញអារម្មណ៍មានរូបជាដើម ;

៣- ជាអ្នកមិននិយាយសប្បាយហេហា ;

៤- នៅក្នុងសេនាសនៈស្ងាត់ ;

៥- មានសេចក្តីឃើញត្រូវ ។

អធិប្បាយថា

ភិក្ខុបួសថ្មីត្រូវតាំងនៅក្នុងធម៌ ៥ យ៉ាងនេះឲ្យខ្ជាប់ខ្ជួន ។ ធម្មតាពួកបុសមាគមដែលនឹងចំរើនហើយតាំងនៅបានយូរ ព្រោះលោកជាប្រមុខ បានបញ្ញត្តច្បាប់ និងទំនៀមទំលាប់សម្រាប់មនុស្សក្នុងពួក ឬសមាគមនោះប្រព្រឹត្តនិងប្រតិបត្តិ ។ ពួកភិក្ខុក៏ដូច្នោះដែរ ត្រូវមានច្បាប់ និងទំនៀមទំលាប់ ដែលព្រះសាស្តាទ្រង់បញ្ញត្តទុក ។ ព្រោះហេតុដូច្នោះបុគ្គលអ្នកស្ម័គ្រចូលមកឧបសម្ប័ទជាភិក្ខុ ទើបជាឋានៈដែលនឹងត្រូវប្រព្រឹត្តតាម ។ ការមិនបំពានកន្លងល្មើសច្បាប់ គឺពុទ្ធបញ្ញត្តដែលជាសិក្ខាបទក្នុងព្រះបាតិមោក្ខតាំងអំពីបារាជិក ដរាបដល់សេក្ខិយវត្ត និងការមិនប្រព្រឹត្តខុសទំនៀមទំលាប់គឺអភិសមាចារ ដែលចាត់ទុកជាពួក ៗ ក្នុងខន្ធកវិន័យបិដក ដូចវត្តផ្សេង ៗ មានឧបជ្ឈាវត្តជាដើម ហៅថាសង្រួមក្នុងព្រះបាតិមោក្ខជាកិច្ចដែលភិក្ខុបួសថ្មីគួរយកចិត្តទុកដាក់ ។

មួយទៀត ភិក្ខុថ្មីដែលទើបលះឃរាវាសចេញមកបួស នៅមិនទាន់ស្ទាត់ជំនាញក្នុងការអត់សង្កត់ចិត្ត បើមិនប្រយ័ត្នឥន្ទ្រិយមានភ្នែកជាដើម ដែលជួបប្រទះនូវអារម្មណ៍មានរូបជាដើមហើយ នឹងបណ្តោយឲ្យសោ-មនស្សក្នុងអារម្មណ៍ដែលគួរសោមនស្ស ទោមនស្សក្នុងអារម្មណ៍ដែលគួរទោមនស្ស រមែងកើតអន្តរាយដល់ព្រហ្មចារិយៈ ប្រតិបត្តិតាមធម្មវិន័យមិនបាន រវល់តែអផ្សុកឬក្រោធខឹងច្រើន អាស្រ័យហេតុនេះ

ភិក្ខុបួសថ្មីទើបត្រូវសង្រួមឥន្ទ្រិយ ប្រយ័ត្នចិត្តមិនឲ្យសោមនស្សទោមនស្សក្នុងកាលអាយតនៈខាងក្នុង និងខាងក្រៅមកខ្ទប់គ្នា ។

ការដែលលះភេទជាឃរាវាសចេញ ចូលមកកាន់ភេទជាភិក្ខុហើយ ក៏គប្បីស្វែងរកសន្តិធម៌ សេចក្ដីស្ងប់រម្ងាប់ដែលជាសេចក្ដីសុខយ៉ាងប្រសើរ បើមករវល់តែប្រជុំគ្នានិយាយលេងសើចសប្បាយហើយ ក៏កើតអន្តរាយចំពោះផលដែលខ្លួនត្រូវប្រាថ្នា ផ្លូវដែលត្រូវគួរបំពេញខ្លួន ឲ្យស្ងប់ស្ងៀមតាំងចិត្តសិក្សាធម្មវិន័យដែលជាកិច្ចដោយត្រង់ សូម្បីនិងសន្ទនាប្រាស្រ័យគ្នា ក៏គួរឲ្យប្រព្រឹត្តទៅក្នុងរឿងដែលជាប់ទាក់ទងនិងធម្មវិន័យ ផ្លាស់ប្ដូរសេចក្ដីដឹងដល់គ្នានិងគ្នា ដូច្នេះទើបសម្រេចប្រយោជន៍ ព្រោះហេតុនេះ ភិក្ខុបួសថ្មីគួរលះវៀរអន្តរាយប្រការនេះចេញ ។

ទីកន្លែងដែលនៅអាស្រ័យសមគួរដល់ភិក្ខុបួសថ្មីនោះ គួរនឹងស្វែងរកសេនាសនៈដ៏ស្ងាត់ស្ងៀម ប្រាសចាកសម្លេងគឹកកងនៃមនុស្សពួកច្រើន ព្រោះការដែលនៅក្នុងទីដូច្នោះ រមែងជាប្រយោជន៍សម្រាប់ធ្វើចិត្តឲ្យស្ងប់មិនឲ្យរាយមាយទៅក្នុងអារម្មណ៍ផ្សេង ៗ និងជាផ្លូវនៃសមាធិ ។ មែនពិតការខ្វល់ខ្វាយដើម្បីធ្វើចិត្តឲ្យជាសមាធិនោះ សម្រាប់អ្នកដែលផ្ដើមហាត់ថ្មីត្រូវតែប្រាថ្នារកស្ថានដូច្នោះបើស្ទាត់ជំនាញហើយ សូម្បីក្នុងទីណា ៗ ក៏ធ្វើបាន ហេតុនេះភិក្ខុបួសថ្មី លោកប្រដៅឲ្យនៅក្នុងសេនាសនៈស្ងាត់ ។

សេចក្ដីយល់ឃើញរបស់មនុស្សចាត់ទុកជាការសំខាន់ ព្រោះជាមូលហេតុនៃសេចក្ដីប្រតិបត្តិ បើមានសេចក្ដីយល់ឃើញខុស ប្រតិបត្តិក៏ខុស បើមានសេចក្ដីយល់ឃើញត្រូវ ប្រតិបត្តិក៏ត្រូវ ព្រោះហេតុដូច្នោះ ទើបលោកប្រដៅឲ្យភិក្ខុបួសថ្មីខ្វល់ខ្វាយ ធ្វើសេចក្ដីយល់ឃើញរបស់ខ្លួនឲ្យប្រព្រឹត្តទៅក្នុងផ្លូវដែលប្រពៃ ។ សេចក្ដីយល់ឃើញថា ការធ្វើកម្មឯណានីមួយ ក៏គ្រាន់តែធ្វើមិនមានអ្នកណាបានទទួលផលរបស់កម្មនោះទេ ឬយល់ឃើញថាបុណ្យបាបមិនមាន ដូច្នេះជាសេចក្ដីយល់ឃើញខុស សេចក្ដីយល់ឃើញថា ពួកសត្វទាំងឡាយរមែងមានកម្មជារបស់ខ្លួន បើធ្វើល្អក៏បានទទួលផលល្អ បើធ្វើអាក្រក់ក៏បានទទួលផលអាក្រក់ បុណ្យបាបជាគ្រឿងបែងចែកសត្វឲ្យផ្សេងគ្នា ដូច្នេះជាសេចក្ដីយល់ឃើញត្រូវ សេចក្ដីយល់ឃើញត្រូវនេះ ក្នុងមគ្គមានអង្គ ៨ លោកសំគាល់យកការយល់ឃើញអរិយសច្ចធម៌ ៤ យ៉ាង ដែលជាសេចក្ដីយល់ឃើញត្រូវយ៉ាងខ្ពស់បំផុត ។

ភិក្ខុបួសថ្មីគួរតាំងនៅក្នុងធម៌ ៥ ប្រការដូចពោលមកនេះ សូម្បីភិក្ខុបួសចាស់ក៏គួរតាំងនៅក្នុងធម៌ ៥ ប្រការនេះដូចគ្នាដែរ តែក្នុងទីនេះ លោកមិនបានពោលដល់ ព្រោះភិក្ខុបួសចាស់ក៏ធ្លាប់ជាភិក្ខុបួសថ្មីមកអំពីមុនរួចហើយ ។

អង្គនៃធម្មកថិក ៥ យ៉ាង

១– សំដែងធម៌តាមលំដាប់ មិនប្រួតកាត់ពាក្យឲ្យខូចសេចក្ដី:

២- លើកយកហេតុផលមកអាងណែនាំឲ្យអ្នកស្តាប់ចូលចិត្ត;

៣- តាំងចិត្តមេត្តាប្រាថ្នាឲ្យជាប្រយោជន៍ដល់អ្នកស្តាប់ ;

៤- មិនសំដែងធម៌ព្រោះឃើញអាមិស ;

៥- មិនសំដែងលើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ។

អធិប្បាយថា :

ភិក្ខុជាធម្មកថិក គប្បីតាំងអង្គទាំង ៥ នេះទុកក្នុងខ្លួន ។ ពាក្យថាអង្គនៃធម្មកថិកនោះ គឺជាអង្គរបស់លោកអ្នកសំដែងធម៌ដែលនឹងត្រូវប្រតិបត្តិតាមអង្គ ៥ យ៉ាងនេះ ។ បើលោកអ្នកសំដែងអង្គណាមិនប្រតិបត្តិតាមលោកអ្នកសំដែងអង្គនោះ រមែងមិនមានអ្នកណានិយមរាប់អានហើយជ្រះថ្លា នឹងទៅជាអ្នកសំដែងដែលរាប់ថាល្អមិនបាន ប្រការ ១ ពាក្យថា « សំដែងធម៌តាមលំដាប់ មិនច្រូតកាត់ពេកឲ្យខូចសេចក្តី » នោះសំគាល់ថាសំដែងទៅតាមគោលរឿង មិនយកការខ្ទិលច្រអូសមកជាទីតាំងហើយនឹងកាត់ ៗ ច្រូត ៗ ឲ្យខូចសេចក្តីទាល់តែអ្នកស្តាប់មិនដឹងបានគោលរឿងសោះ ។ ប្រការ ២ សំគាល់សេចក្តីថា ត្រូវចង្អុលអាងហេតុ សំដែងផលណែនាំឲ្យអ្នកស្តាប់ចូលចិត្តជាក់ច្បាស់មិនឲ្យមានសេចក្តីសង្ស័យ ប្រការ ៣ សំគាល់ថាតាំងចិត្តមេត្តាគឺប្រាថ្នាប្រយោជន៍ឲ្យអ្នកស្តាប់ចូលចិត្ត ហើយបានទទួលសេចក្តីដឹងពិត ៗ ។ ប្រការ ៤ សំគាល់សេចក្តីថា ការសំដែង

ធម៌កុំសម្លឹងឃើញតែអាមិសឬលាភសក្ការៈនឹងគ្រឿងបូជាប៉ុណ្ណោះ ។ ប្រការទី ៥ សំគាល់សេចក្តីថា កុំប្រកាន់យកការសំដែងធម៌នោះដៀលត្មះអ្នកដទៃដោយចេតនាដ៏អាក្រក់ មិនលើកខ្លួន ហើយបន្តុះបង្អាប់អ្នកដទៃដោយធម្មទេសនា ។

អានិសង្សស្តាប់ធម៌ ៥ យ៉ាង

១- អសុតំ សុណាតិ រមែងបានស្តាប់ធម៌ដែលមិនទាន់បានស្តាប់ ;

២- សុតំ បរិយោទបេតិ ធម៌ណាដែលធ្លាប់ស្តាប់ហើយតែមិនទាន់ចូលចិត្តនឹងចូលចិត្តច្បាស់ឡើង ;

៣- កង្ខំវិហនតិ រមែងកំចាត់បង់នូវសេចក្តីសង្ស័យចេញបាន ;

៤- ទិដ្ឋិឧជុំ ករោតិ រមែងធ្វើសេចក្តីឃើញឲ្យត្រង់តាមការណ៍ពិត;

៥- ចិត្តមស្ស បសីទតិ ចិត្តអ្នកស្តាប់នោះរមែងជ្រះថ្លា ។

អធិប្បាយថា :

ធម៌ ៥ ប្រការនេះជាផលហូរមកកាន់អ្នកស្តាប់ធម៌មែនពិត ។ កាលណាពិចារណាឃើញច្បាស់ហើយ អ្នកស្តាប់ធម៌ រមែងបានឮ បានស្តាប់រឿងដែលខ្លួនមិនទាន់ធ្លាប់បានឮបានស្តាប់ រមែងដឹងរឿងដែល

មិនទាន់បានដឹង ហើយរឿងណាដែលធ្លាប់បានឮបានស្ដាប់មកហើយ តែបើបានស្ដាប់ យូរ ៗ ទៅរមែងភ្លេចភ្លាំងក៏មាន ដូចកាំបិតពូថៅ ឬគ្រឿងសស្ត្រាវុធឯណានីមួយ ដែលម្ចាស់សំលៀងទុកចោលយូរ ច្រេះរមែងកើតឡើង ដល់ពេលនឹងប្រើត្រូវសំលៀងទៀតយ៉ាងណា ការស្ដាប់ធម៌ បើបានស្ដាប់យូរៗ ទៅ រមែងភ្លេចភ្លាំងយ៉ាងនោះដែរ គ្រឿងសស្ត្រាវុធបើឧស្សាហ៍សំលៀងក៏រឹតតែមុតឡើងយ៉ាងណា ការស្ដាប់ធម៌បើឧស្សាហ៍ស្ដាប់ក៏រឹតតែចូលចិត្តច្បាស់ជំនាញឡើងយ៉ាងនោះដែរ ។ ការចូលចិត្តស្ទាត់ជំនាញហើយក៏ពិតមែន , តែអាចកើតសេចក្ដីយល់ឃើញដែលមិនប្រាកដក្នុងចិត្ត ជាហេតុឲ្យកើតសង្ស័យក៏មាន ន័យនេះត្រូវអាស្រ័យការស្ដាប់ថែមទៀត ទើបកំចាត់បង់សេចក្ដីសង្ស័យចេញបានខ្លះ កាលកំចាត់បង់សេចក្ដីសង្ស័យបានមួយដងមួយគ្រា ហើយបើមិនអាចកំណត់យកសេចក្ដីដឹងយល់ឃើញនោះ មកទុកដាក់ក្នុងចិត្តឲ្យត្រង់តាមការណ៍ពិតរបស់ធម៌ទេ ក៏ត្រូវអាស្រ័យការស្ដាប់ថែមទៀតនោះឯង ។ កាលបើឧស្សាហ៍ស្ដាប់រឿយ ៗ ទៅ ចិត្តរបស់អ្នកស្ដាប់នោះរមែងជ្រះថ្លា ព្រោះដឹងច្បាស់តាមការណ៍ពិត ដែលកើតអំពីការស្ដាប់នោះជាឫសគល់ ហេតុនេះទើបលោកពោលថា ធម៌៥ ប្រការនេះជាអានិសង្សនៃអ្នកស្ដាប់ធម៌ដែលត្រូវបាន ។

ពលៈ ៥ យ៉ាង

១– សទ្ធា សេចក្ដីជឿ ;

២– វីរិយ សេចក្ដីព្យាយាម ;

៣– សតិ សេចក្ដីរលឹកបាន ;

៤– សមាធិ សេចក្ដីតាំងចិត្តខ្ជាប់ ;

៥– បញ្ញា សេចក្ដីដឹងស្គាល់ការណ៍ខុសត្រូវ ;

អធិប្បាយថា :

ធម៌ ៥ យ៉ាងនេះហៅថា „ ឥន្រ្ទិយ „ ក៏បានព្រោះជាធំក្នុងកិច្ចរបស់ខ្លួន ធម៌ ៥ ប្រការនេះបានជាឈ្មោះថាពលៈនោះ ព្រោះមានអធិប្បាយថា បុគ្គលឯណាដែលប្រកបដោយគុណធម៌ ៥ ប្រការឬមិនគ្រប់ ៥ ក៏ដោយ បុគ្គលនោះឈ្មោះថាមានកម្លាំងចិត្តអាចនឹងប្រកបកិច្ចការឯណាមួយបាន ហើយសម្រេចសមតាមបំណង ដែលមិនហួសវិស័យ ដូចកម្លាំងកាយមាំមួនរឹងប៉ឹងអាចលី ឬសែងនូវវត្ថុគ្រប់យ៉ាងទៅបានដូច្នេះ ។

អធិប្បាយសេចក្ដីឲ្យល្មមជានិទស្សន៍ដូចតទៅនេះ ១– សទ្ធា បុគ្គលប្រកបការងារឯណានីមួយលំបាកក៏ដោយ ស្រួលក៏ដោយ ក្នុងជាន់ដើមត្រូវអាស្រ័យសទ្ធា សេចក្ដីជឿជាមុន គឺជឿថាការងារដែលនឹងប្រកប

នោះមានប្រយោជន៍ពិត មិនឥតប្រយោជន៍ទេ ជាការងារដែលអំណោយប្រយោជន៍ឲ្យសមនឹងដើមទុន ឬតាមកម្លាំង ហើយត្រូវជឿក្នុងចិត្តខ្លួនទៀតថា ខ្លួនមានសមត្ថភាពអាចធ្វើបានក្នុងការងារនោះ ៗ ។ ឯការងារដែលធ្វើនោះទៀតក៏នឹងនាំឲ្យសម្រេចផលប្រយោជន៍ពិត ៗ ។ ផលដែលនឹងត្រូវបាននោះ ក៏ព្រោះការងារដែលធ្វើនេះឯង មិនមែនបានដោយផ្លូវដទៃឡើយ យ៉ាងនេះ កម្លាំងចិត្តរមែងកើតឡើង ។ កាលបើកម្លាំងចិត្តកើតឡើងហើយ រមែងដឹកនាំឲ្យប្រកបការងារនោះ ៗ ដោយមិនរួញរាសទ្ធាសេចក្ដីជឿជាកម្លាំងរបស់ចិត្តបាន យ៉ាងនេះ ។

ប៉ុន្តែកម្លាំងចិត្តនេះក៏អាចរាថយទៅវិញបានខ្លះ ដោយអំណាចនៃសេចក្ដីប្រមាទនិងខ្ជិលច្រអូសនាំបណ្ដាលឲ្យធ្វើសង្សឹម ៗ យឺតយូរ ឬធ្វើខ្លះមិនធ្វើខ្លះ បណ្ដោះបណ្ដែថា ថ្ងៃនេះជាថ្ងៃនោះ ចាំដល់ពេលនេះចាំដល់នោះ ការងារនោះក៏មិនបានសម្រេចឡើយ ព្រោះហេតុនេះ ក្នុងលំដាប់ទី ២ បន្ទាប់អំពីសទ្ធាមក ត្រូវមានវីរិយៈសេចក្ដីព្យាយាម ដែលជាគុណធម៌អាចទាញចិត្តឲ្យប្រកបកិច្ចដោយមិនរាថយ ផ្គត់ផ្គង់ចិត្តឲ្យខិតខំព្យាយាមជាត្រីមុខ ។ វីរិយៈជាធម៌អាចឲ្យកើតកម្លាំងចិត្តបានយ៉ាងនេះ ។

តាមធម្មតាការងារដែលធ្វើដោយអំណាចសេចក្ដីព្យាយាម ពេលខ្លះរមែងមានវត្ថុដែលជំទាស់រាំងរាក្នុងចន្លោះដែលកើតតាមធម្មតារបស់ការងារក្នុងលោក កាលជួបប្រទះសេចក្ដីជំទាស់រាំងរាដូច្នេះហើយ បើមិនមាន

សតិគ្រប់គ្រងចិត្តទេ ចិត្តរមែងមិនគួរដល់ការងារ គឺច្រើនតែព្រមលះបង់ការងារនោះចេញដោយងាយ ៗ មិនស្វែងរកឧបាយគិតបន្ធូរបន្ថយកែខៃឲ្យផុតចាកសេចក្ដីជាប់ជំពាក់នោះ ៗ ចោលចេញ ។ កាលបើដូច្នេះ ការងារដែលធ្វើនោះ រមែងមិនឈានឡើងទៅដល់សេចក្ដីសម្រេចបាន ព្រោះហេតុនេះក្នុងលំដាប់អំពីវីរិយៈនេះទៅ ទើបត្រូវអាស្រ័យសតិសេចក្ដីរលឹក ដែលជាធម៌ត្រៀងទប់ចិត្តឲ្យនៅត្រង់នឹងការងារ ជារបស់តៀនចិត្តឲ្យសំគាល់តែខាងសេចក្ដីសម្រេចជានិច្ច បើមានឧបសគ្គ ក៏ជំរុញចិត្តឲ្យគិតរកឧបាយកែខៃ មិនតែប៉ុណ្ណោះ សតិនោះរមែងជាគុណធម៌គាំពារការងារដែលធ្វើនោះ មិនឲ្យខុស មិនឲ្យភ្លាត់ ជាហេតុឲ្យចាំឲ្យរលឹកដល់ការងារដែលធ្វើហើយយូរ ៗ បាន ដើម្បីជាបច្ច័យទំនុកបំរុងការងារដែលធ្វើតទៅក្នុងខាងមុខផង បើនិយាយឲ្យខ្លីថាសតិជាធម៌ដែលគួរ ដល់ការងារនឹងជាកម្លាំង បានយ៉ាងនេះ ។

តាមធម្មតារបស់ចិត្ត សូម្បីនៅក្នុងសេចក្ដីគ្រប់គ្រងរក្សាក៏ពិតមែន ហើយប៉ុន្តែមានពេលខ្លះសតិក៏ទប់មិនឈ្នះដែរ ព្រោះមានកម្លាំងចិត្តច្រើនជាង ។ ដល់វេលាល្អក៏ល្អ ដល់វេលាអាក្រក់មិនកោតខ្លាច មានសតិក៏គ្រាន់តែថាមានប៉ុណ្ណោះ ។ ប៉ុន្តែមិនអាចនឹងទប់កម្លាំងចិត្តបានឡើយ ។ ដូច្នេះតួសតិឯង ដែលជាអ្នកគ្រប់គ្រងនោះគង់តែនៅមានវេលាដែលភ្លេចភ្លាំងបាន ។ កាលបើដូច្នេះមានធម៌ណាទៀតដែលនឹង

ធ្វើចិត្តឲ្យនឹងនួនជាគោលចារឹក ធ្វើឲ្យការងារសម្រេចបាន ។ បន្ទាប់អំពីសតិក៏គឺសមាធិ ព្រោះជាធម៌ដែលធ្វើចិត្តឲ្យនឹងនួនតាំងនៅខ្ជាប់ជានិច្ច មិនឲ្យប្រែប្រួលប្រព្រឹត្តទៅជាយ៉ាងដទៃ ធ្វើឲ្យចិត្តចងចាំ នៅចំពោះតែក្នុងការងារនោះ សមាធិជាកម្លាំងរបស់ចិត្តបានយ៉ាងនេះ ។

សូម្បីមានសមាធិហើយ ក៏នៅតែមិនសម្រេចដោយពិតប្រាកដដែរព្រោះខ្វះបញ្ញាដែលជាកម្លាំងសំខាន់បំផុតក្នុងពលៈ ៥ ប្រការនេះ ព្រោះហេតុដូច្នោះក្នុងលំដាប់ទី ៥ បន្ទាប់អំពីសមាធិនោះមក ទើបត្រូវតែប្រកបដោយបញ្ញាផង ព្រោះជាធម៌ធ្វើឲ្យអ្នកដឹងស្គាល់ការខុសត្រូវក្នុងការងារតាមធម្មតានិយមមានប្រាជ្ញាស្ទង់ដឹងហេតុនៃសេចក្ដីសាបសូន្យ និងសេចក្ដីចំរើនឲ្យដំណើរការងាររបស់ខ្លួននោះ ផុតចាកសេចក្ដីអាក្រក់ សេចក្ដីវិនាស ឲ្យដំណើរតែក្នុងផ្លូវដែលល្អប្រពៃ ។ កាលបើដូច្នេះកិច្ចការដែលប្រកបនោះរមែងឲ្យសម្រេចផល តាមទំនងដែលបានគាញ់ត្នេរមក់ហើយ ។ ការងារដែលល្អបំផុតដោយអាស្រ័យហេតុផល ដូចបានអធិប្បាយមកខាងលើនេះ ។ ពលៈធម៌ទាំង ៥ ប្រការនេះ បើបុគ្គលណាធ្វើឲ្យតាំងនៅក្នុងខន្ធសន្ដាន អាចទប់បុគ្គលនោះមិនឲ្យធ្លាក់ទៅក្នុងអបាយភូមិបាន ។

ដែលហៅថាឥន្ទ្រិយនោះព្រោះជាធំក្នុងកិច្ចការខ្លួន គឺសទ្ធាជាធំក្នុងសេចក្ដីជឿ ។ វីរិយៈជាធំក្នុងសេចក្ដីព្យាយាម ។ សតិជាធំក្នុងសេចក្ដីរលឹកបាន ។ សមាធិជាធំក្នុងសេចក្ដីតាំងចិត្តខ្ជាប់ ។ បញ្ញាជាធំក្នុងសេចក្ដីដឹងស្គាល់ការខុសត្រូវដូច្នេះ ។

នីវរណៈ ៥ យ៉ាង

១- កាមច្ឆន្ទៈ ស្រឡាញ់ចូលចិត្តក្នុងអារម្មណ៍មានរូបជាដើមដែលជាទីគាប់ចិត្ត ;

២- ព្យាបាទៈ ចងចិត្តគំនុំគុំគួនអ្នកដទៃ ;

៣- ថីនមិទ្ធៈ ដំណើរដែលចិត្តរួញថយ និងដំណើរងងុយងោកងងក់ ;

៤- ឧទ្ធច្ច កុក្កុច្ចៈ ដំណើរដែលចិត្តរាយមាយ និងរសាប់រសល់ ;

៥- វិចិកិច្ឆាៈ សេចក្ដីសង្ស័យមិនចេះដាច់ស្រេច ។

អធិប្បាយថា :

ពាក្យថា និវរណៈ ប្រែថាធម៌ដែលជាគ្រឿងរាំងរាសំគាល់សេចក្ដីថា រាំងរាចិត្តមិនឲ្យបានសម្រេចសេចក្ដីល្អ គឺមិនបានធ្វើសេចក្ដីល្អដោយអំណាចមានធម៌ទាំងនោះចូលមករាំងរាព្រោះហេតុនេះ ធម៌អម្បាលនេះណាមួយគ្របសង្កត់ចិត្តក្នុងសម័យណាហើយ បុគ្គលនោះរមែងមិនអាចសម្លឹងឃើញ ឬគិតឃើញអត្ថធម៌ក្នុងសម័យនោះឡើយ

កាលបើដូច្នេះ អ្នកនោះរមែងមិនអាចប្រកបកិច្ចការឲ្យសម្រេចប្រយោជន៍បាន ។ ការដែលធ្វើចិត្តផុតចាក នីវរណៈ អម្បាលនេះ ហៅថា សមាធិ ។

ការមិនធ្វើចិត្តឲ្យនឹងធឹងក្នុងសុភនិមិត្ត ចេះតែឃើញវិប្បរិតខុសធម្មតានិយម គឺកំណត់សំគាល់ក្នុងសុភនិមិត្តនោះជាស្រស់បស់ល្អ ជាហេតុឲ្យកើត កាមច្ឆន្ទៈ ។ កាលបើ កាមច្ឆន្ទៈ កើតឡើងហើយ រមែងស្រឡាញ់ចូលចិត្តក្នុងវត្ថុកាម មានរូបសម្លេងជាដើម ។ វេលាដែលកាមច្ឆន្ទៈកើតឡើងហើយចិត្តរបស់អ្នកនោះទុកជាផូរផង់ ក៏ត្រឡប់ក្លាយទៅជាសៅហ្មងវិញបាន ប្រៀបដូចទឹកដែលលាយដោយពណ៌ផ្សេង ៗ អ្នកមានប្រាជ្ញានឹងឆ្លុះមើលមុខក៏មើលមិនឃើញ ។ អ្នកមានចរិតបែបនេះត្រូវចំរើនអសុភកម្មដ្ឋាននឹងកាយគតាសតិកម្មដ្ឋានឲ្យឃើញថាជារបស់មិនស្អាតគួរខ្ពើម ទើបនឹងអាចជាឧបាយកែចរិតនេះបាន ។ កម្មដ្ឋានទាំងពីរនេះ ទុកដូចជាថ្នាំរំងាប់រោគ ។

ការមិនមានមនសិការៈក្នុងបដិឃនិមិត្តរមែងជាហេតុឲ្យវិប្បរិតកំណត់សំគាល់តែក្នុងរឿងថ្នាំងថ្នាក់ចិត្ត ជាផ្លូវឲ្យកើតព្យាបាទ ។ លុះព្យាបាទកើតឡើង ក្នុងវេលាណា ចិត្តរមែងប្រទូស្តមនុស្សឬសត្វដទៃវេលានោះជាដរាប ។ កាលដែលព្យាបាទកើតឡើងហើយ ចិត្តដែលជាធម្មជាតិដ៏បរិសុទ្ធក៏ក្លាយទៅជាសៅហ្មងវិញ ប្រៀបដូចទឹកដែលកំពុង

ពុះ ។ បុគ្គលអ្នកមានព្យាបាទច្រើនក្រោធខឹង ប្ដូចង់ចិត្តគុំគួនអ្នកដទៃដែលខ្លួនស្អប់ខ្ពើម , ត្រូវចំរើនព្រហ្មវិហារ ៣ ប្រការ គឺ មេត្តា១ , ករុណា ១ , មុទិតា ១ , ។ ដើម្បីទាញចិត្តឲ្យត្រឡប់គិតក្នុងផ្លូវដែលជាហេតុឲ្យកើតសេចក្តីស្រឡាញ់ កើតសោមនស្ស ព្រោះកម្មដ្ឋាននេះសម្រាប់រំងាប់ទោសចរិត ។

ការមិនមានមនសិការៈក្នុងអរតិ សេចក្តីមិនត្រេកអរនឹងសេចក្តីខ្ជិលច្រអូសជាអាហារ ជាហេតុធ្វើឲ្យចិត្តវិប្បរិតប្រកាន់យករឿងនេះជាគ្រឿងសំគាល់ នាំបណ្តាលឲ្យកើតថីនមិទ្ធៈ ។ ថីនមិទ្ធៈកើតឡើងមានលក្ខណៈធ្វើឲ្យចិត្តរួញថយ ងងុយងោកងក់វេលាណា ចិត្តដែលជាធម្មជាតិផូរផង់ស្រស់ថ្លាក៏ក្លាយជាកករល្អក់វេលានោះ ដូចទឹកដែលមានចកនឹងសារាយគ្របបិទបាំង ។ បុគ្គលអ្នកមានថីនមិទ្ធៈ ច្រើនរួញរាបន្ធូរបន្ថយក្នុងការងារ និងងងុយងោកងក់ជាដើមត្រូវចំរើនអនុស្សតិកម្មដ្ឋាន ពិចារណាសេចក្តីល្អរបស់ខ្លួនខ្លះ ពិចារណាគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ខ្លះដើម្បីធ្វើចិត្តឲ្យមានសេចក្តីឧស្សាហ៍ព្យាយាម ដើម្បីប្រើសេចក្តីនឹករលឹកឲ្យឆ្ងាយទូលាយជាឧបាយបំបាត់ថីនមិទ្ធៈ ។ កម្មដ្ឋាននេះជាទីរំងាប់ចរិតបុគ្គលបែបនេះ ។

ចេតសោអវូបសម ការមិនចូលទៅស្ងប់រម្ងាប់នៃចិត្ត ជាហេតុឲ្យកើត-ឧទ្ធច្ចៈ កុក្កុច្ចៈ ។ ឧទ្ធច្ចៈ កុក្កុច្ចៈ កើតឡើងរមែងធ្វើចិត្តឲ្យរាយ

មាយរសាប់រសល់ ។ ចិត្តដែលធ្លាប់បរិសុទ្ធស្អាតត្រឡប់ក្លាយជាធម្មជាតិសៅហ្មងវិញ ប្រៀបដូចទឹកដែលខ្យល់បក់ជាត់ឲ្យរលកជានិច្ច ។ បុគ្គលអ្នកមានថីនមិទ្ធៈគួរសំឡឹងកសិណ ចងចិត្តទុកឲ្យនៅក្នុងអារម្មណ៍តែមួយឬចំរើនកម្មដ្ឋានដែលធ្វើចិត្តឲ្យកើតសង្វេគ មានមរណស្សតិជាដើម ។ កម្មដ្ឋាននេះ ជាទីរំងាប់ចរិតរបស់បុគ្គលបែបនេះ ។

អយោនិសោមនសិការៈ ការមិនបានធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ជាហេតុឲ្យកើតវិចិកិច្ឆា ។ អ្នកមានវិចិកិច្ឆាមានសេចក្តីសង្ស័យមិនចេះដាច់ស្រេច ។ ចិត្តដែលមានវិចិកិច្ឆាគ្របសង្កត់ ប្រៀបដូចទឹកមានកករល្អក់ជាដើម តាំងនៅក្នុងទីងងឹត ត្រូវចំរើនធាតុកម្មដ្ឋានឬវិបស្សនាកម្មដ្ឋាន ដើម្បីកំណត់ដឹងសភាវធម៌ដែលពិត ។

ខន្ធ ៥

កាយនិងចិត្តនេះ ចែកចេញជា ៥ កង ហៅថាខន្ធ ៥ គឺរូប ១, វេទនា ១, សញ្ញា ១, សង្ខារ ១, វិញ្ញាណ ១, ។

អធិប្បាយថា :

ធាតុ ៤ គឺ ដី, ទឹក, ភ្លើង, ខ្យល់, ប្រជុំគ្នាជាកាយ ហៅថា រូប ។

ការកំណត់ដឹងអារម្មណ៍ជាសុខ គឺសប្បាយកាយសប្បាយចិត្តឬជាទុក្ខ មិនសប្បាយកាយ មិនសប្បាយចិត្ត ឬឧបេក្ខាព្រងើយមិនសុខ

មិនទុក្ខ ហៅថា វេទនា ។

សេចក្តីកត់សំគាល់ចាំបាន គឺចាំរូប, សម្លេង, ក្លិន, រស, ផោដ្ឋព្វៈ ធម្មារម្មណ៍ជាអារម្មណ៍ ដែលកើតចំពោះចិត្ត ហៅថាសញ្ញា ។

ចេតសិកធម៌ អារម្មណ៍ដែលកើតរួមជាមួយចិត្ត; ចំណែកខាងល្អហៅថា កុសល, ខាងអាក្រក់ ហៅថា អកុសល ខាងកណ្តាល មិនល្អមិនអាក្រក់ ហៅថាអព្យាក្រិត, រួមទាំង ៣ យ៉ាងនេះហៅថា សង្ខារ ។

សេចក្តីដឹងអារម្មណ៍ ក្នុងវេលាដែលអាយតនៈ ខាងក្រៅមានរូបជាដើម មកប៉ះអាយតនៈខាងក្នុង មានភ្នែកជាដើមហៅថាវិញ្ញាណ ។

ខន្ធ ៥ នេះហៅដោយបំព្រួញថានាមរូប ។ វេទនា, សញ្ញា, សង្ខារ, វិញ្ញាណរួមចូលគ្នាជានាមឬជានាមធម៌, ឯរូបគង់នៅជារូបឬ ជារូបធម៌ ។

ដែលហៅថា ខន្ធព្រោះចែកចេញជាកង ១ គឺរូបខន្ធកងរូប ។ល។ វិញ្ញាណខន្ធ កងវិញ្ញាណ ។

ឆក្កៈពួក ៦

គារវៈ ៦ យ៉ាង

១- ពុទ្ធគារវតា គោរពក្នុងព្រះពុទ្ធ ;

២- ធម្មាគារវតា គោរពក្នុងព្រះធម៌ ;

៣- សង្ឃគារវតា គោរពក្នុងព្រះសង្ឃ ;

៤- សិក្ខាគារវតា គោរពក្នុងការសូត្ររៀន ;

៥- អប្បមាទគារវតា គោរពក្នុងសេចក្តីមិនប្រមាទ ;

៦-បដិសណ្ឋារគារវតា គោរពក្នុងបដិសណ្ឋារៈ ។

អធិប្បាយថា :

ពាក្យថា " គោរព " បានដល់ការថ្វាយបង្គំ ឬ បូជារហូតដល់ការប្រព្រឹត្តនឹងប្រតិបត្តិផង ចាត់ជាសេចក្តីគោរពក្នុងទីនេះ ។

ការបណ្តុះសទ្ធា សេចក្តីជឿ នឹងបសាទៈ សេចក្តីជ្រះថ្លាចំពោះព្រះពុទ្ធយ៉ាងពិតប្រាកដ ហើយសំដែងខ្លួនជាពុទ្ធមាមកៈ គឺអ្នកទទួលយកព្រះអង្គមកជាទីពឹងអាង ដោយកាយវាចាចិត្តព្រមទាំងត្រៃទ្វារ តរំពីនោះទៅ ក៏ប្រតិបត្តិតាមសាសនាដែលជាពាក្យប្រដៅរបស់ព្រះអង្គយ៉ាងហ្មត់ចត់ ដូច្នេះចាត់ជាសេចក្តីគោរពក្នុងព្រះពុទ្ធ ។ ការនឹកដល់គុណរបស់ព្រះអង្គ នឹងព្រះពុទ្ធចរិយា ដោយប្រាជ្ញា ក៏ជាក់

ច្បាស់ដើម្បីផ្តត់ផ្គង់សទ្ធា សេចក្តីជឿ បសាទៈសេចក្តីជ្រះថ្លាឲ្យកើតឡើងហើយ កាន់យកមកជាបែបសម្រាប់ប្រតិបត្តិចំពោះខ្លួន ដូច្នេះក៏ចាត់ថាជាសេចក្តីគោរពក្នុងព្រះពុទ្ធដែរ ប្រការមួយទៀត ការដែលមិនប្រារព្ធយករឿងរបស់ព្រះអង្គមកលេងជាល្បែង ឬនិយាយលេងដោយកិរិយាប្រមាថ កំប្លែង ដើម្បីជាសេចក្តី សប្បាយរីករាយ ដូច្នេះក៏ចាត់ថាជាសេចក្តីគោរពក្នុងព្រះពុទ្ធដែរ បូជនីយដ្ឋានដែលជាទីប្រតិស្ឋាន បូជនីយវត្ថុផ្សេង ៗ ដូចព្រះស្តូប ព្រះ ព្រះបដិមាក ព្រះចេតិយ ដើមមហាពោធិព្រឹក្ស ការចូលទៅជិតដល់ហើយសំដែងសេចក្តីគោរពកោតខ្លាចជាដើមថា បើបាំងឆ័ត្រឬពាក់មួក ត្រូវដម្លោះ ឬដោះចេញ បើពាក់ស្បែកជើងក៏ត្រូវដោះចេញ តាំងអម្បាលនេះជាដើម ហើយធ្វើសក្ការបូជាដូច្នេះចាត់ថាជាសេចក្តីគោរពក្នុងព្រះពុទ្ធ ។

ការប្រព្រឹត្ត នឹងប្រតិបត្តិតាមនាទីរបស់ខ្លួន ជាធម្មាធិបតេយ្យ មិនប្រព្រឹត្ត នឹងប្រតិបត្តិជាអត្តាធិបតេយ្យនឹងលោកាធិបតេយ្យ ចាត់ជាសេចក្តីគោរពក្នុងព្រះធម៌ ដោយអធិប្បាយថា បុគ្គលអ្នកប្រព្រឹត្តប្រតិបត្តិតាមនាទីរបស់ខ្លួនជា អត្តាធិបតេយ្យ គឺប្រារព្ធខ្លួនជាធំ ប្រាថ្នានឹងឲ្យគេសរសើរបុគ្គលអ្នកប្រព្រឹត្តប្រតិបត្តិ តាមនាទីរបស់ខ្លួនជាលោកាធិបតេយ្យ គឺប្រារព្ធយកអ្នកដទៃជាធំ ខ្លាចក្រែងគេនិន្ទាតិះដៀល បុគ្គល ២ ចំពូកនេះឈ្មោះថាធ្ងន់ក្នុងនាទីរបស់ខ្លួនពេក នឹងឲ្យ

ឈ្មោះថាគោរពក្នុងព្រះធម៌មិនបាន ។ ចំណែកបុគ្គលអ្នកប្រព្រឹត្តប្រតិបត្តិតាមនាទីរបស់ខ្លួនជាធម្មាធិបតេយ្យ ប្រារព្ធធម៌ជាធំគឺសំគាល់នៅក្នុងព្រះធម៌ ធ្ងន់ក្នុងព្រះធម៌បុគ្គលមានសភាពយ៉ាងនេះ ឈ្មោះថាគោរពក្នុងព្រះធម៌ ឬមានសេចក្តីគោរពចំពោះពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ដែលហៅថា ធម្មវិន័យក្តី ឬការបូជាចំពោះភិក្ខុជាពហុស្សុតក្តី នេះឯងឈ្មោះថាគោរពក្នុងព្រះធម៌ ។

សាវ័កអ្នកបានសម្រេចធម៌វិសេស ដោយប្រភេទជាសោតាបន្ន-សកទាគាមី អនាគាមី និងព្រះអរហន្ត ពោលដោយបរិយាយយ៉ាងខាបអនុលោមតាមវិន័យនេះប្រាថ្នាយកអ្នកមានសីលបរិសុទ្ធ មានមារយាទរៀបរយ រម្យទម្យ មានគុណគួររាប់អាន ឈ្មោះថា គោរពក្នុងព្រះសង្ឃ ។

ការគោរពថ្វាយបង្គំលោក ការក្រោកទទួលធ្វើអញ្ជលីកម្ម សាមីចិកម្ម រហូតដល់ការជឿស្តាប់ពាក្យប្រដៅរបស់លោកប្រតិបត្តិតាមឱវាទរបស់លោក មិនសំដែងអាការមើលងាយ សំគាល់ឃើញថាលោកជាដំណាងព្រះបរមសាស្តា ជាឃ្លាំងនៃសាសនារបស់ព្រះអង្គ ដូច្នេះចាត់ថាជាសេចក្តីគោរពក្នុងព្រះសង្ឃ ។

ការតាំងចិត្តសិក្សារៀនសូត្រធម្មវិន័យ វិជ្ជាផ្សេងៗ ដោយគោរពទាំងគតិលោក គតិធម៌ ដែលនឹងនាំមកនូវ ហិតានុហិតប្រយោជន៍ដល់

ខ្លួននិងអ្នកដទៃ ដោយមិនខ្ជិលច្រអូសប្រកបដោយគុណធម៌ ៤ ប្រការគឺ ឆន្ទៈ វីរិយៈ ចិត្តៈ វីមំសា ដោយបរិបូណ៌ដូច្នេះ ចាត់ជាសេចក្តីគោរពក្នុងសិក្ខាសូត្ររៀន ។

ភាពជាអ្នកមានសតិមាំមួន មិនភាយមាយទៅក្នុងអារម្មណ៍ផ្សេងៗ ឈ្មោះថាសេចក្តីមិនប្រមាទ ។ ការបំពេញសេចក្តីមិនប្រមាទឲ្យបរិបូណ៌ក្នុងសន្តាន គឺប្រយ័ត្នចិត្តកុំឲ្យត្រេកអរ កុំឲ្យខឹងក្នុងអារម្មណ៍ ដែលនាំឲ្យមានតម្រេក ដែលនាំឲ្យខឹង និងប្រយ័ត្នចិត្ត កុំឲ្យស្រវឹងក្នុងវ័យ ក្នុងសេចក្តីមិនមានរោគក្នុងជីវិត ក្នុងលាភ យស សុខ សរសើរ កុំបណ្តោយចិត្តឲ្យវង្វេងក្នុងអារម្មណ៍ដែលនាំឲ្យវង្វេង ដូច្នេះចាត់ថាជាសេចក្តីគោរពក្នុងសេចក្តីមិនប្រមាទ ។ ពោលដោយរួបរួមទៅថាការដែលប្រតិបត្តិធម៌ តាមផ្លូវពុទ្ធសាសនាក្តី ឬធ្វើកិច្ចការងារតាមនាទីរបស់ខ្លួនដែលជាចំណែកគតិលោកក្តី ត្រូវឲ្យមានសតិប្រចាំនៅជានិច្ចគ្រប់ខណៈនោះ ឈ្មោះថាគោរពក្នុងសេចក្តីមិនប្រមាទ ។

បដិសណ្ឋារៈ បានដល់ការទទួលប្រស្រ័យដោយមេត្រីចិត្តក្នុងខណៈកាលមានអ្នកដទៃមកកាន់សំណាក់របស់ខ្លួន ចែកចេញជា ២ យ៉ាងគឺ : អាមិសប្បដិសណ្ឋារៈ ១ ធម្មប្បដិសណ្ឋារៈ ១ ។ ការទទួលប្រស័យដោយឲ្យវត្ថុរបស់ខ្លួន សមគួរដល់សេចក្តីត្រូវការ ដូចឲ្យ បាយ ទឹក ភោជនាហារ និងទីសំណាក់ជាដើម ដូច្នេះហៅថា

អាមិសប្បដិសណ្ឋារ: ។ ឯការផ្សាយសេចក្តីល្អឲ្យប្រព្រឹត្តទៅតាមគម៌ដូចសំដែងខ្លួនតាមឆន្ទ:ដែលនឹងគួរសមយ៉ាងណា ហើយឲ្យភ្ញៀវអ្នកមកនោះ បានទទួលសេចក្តីលើកតម្កើង រាប់អានដោយសមគួរដល់គេដូច្នោះជាដើម ហៅថា ធម្មប្បដិសណ្ឋារ: ។ សេចក្តីគោរពក្នុងបដិសណ្ឋារ:នោះ គឺបំពេញបដិសណ្ឋារ:ចំពោះភ្ញៀវដែលមកដល់ទីកន្លែងរបស់ខ្លួន ដោយអាមិសនឹងដោយធម៌ ដូចពោលមកហើយនោះ ឬ សូម្បីតែត្រឹមដោយវាចា ដូចជាហៅថា សម្មោទនា គឺចរចាប្រស្រ័យឲ្យកើតសេចក្តីត្រេកអរមានសួរដល់សុខទុក្ខ ឬ ឈឺចាប់ជាដើមដូច្នោះចាត់ការថោជាសេចក្តីគោរពក្នុងបដិសណ្ឋារ: ។

កាលពោលដោយខ្លួទៅ ការគោរពជាសំខាន់បំផុត ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ព្រះពុទ្ធសាសនាដែលនឹងបានសេចក្តី[illegible] ឬ សាបសូន្យទៅ ក៏ព្រោះសេចក្តីគោរព នឹងមិនគោរពជាហេតុ ។ ន័យនេះគប្បីជ្រាបដោយទេសនា ដែលទ្រង់ប្រទានដល់មហាកស្សបទ្រង់ប្រារព្ធដល់សេចក្តីអន្តរធានថៃព្រះសទ្ធម្មដែលនឹងកើតឡើងបាន ក៏ព្រោះបរិស័ទ ៤ គឺ ភិក្ខុនី ឧបាសក ឧបាសិកា មិនគោរពក្នុងព្រះសាស្តា ព្រះធម៌ព្រះសង្ឃ ក្នុងការសិក្សាសូត្ររៀន មិនមានអ្វីដទៃដែលនឹងលុបលាងឲ្យព្រះគរុធម្មរលត់សូន្យបាន ក្រៅចាកហេតុគឺសេចក្តីមិនគោរពនោះទេ ព្រោះហេតុដូច្នោះ ភិក្ខុដែលប្រាថ្នាសេចក្តីចំរើនថៃព្រះពុទ្ធសាសនា នឹង

សេចក្តីចំរើនដល់ខ្លួន គប្បីធ្វើគារវ:គោរពទាំង ៦ ប្រការនេះ ។

សារាណីយធម៌ ៦ យ៉ាង

១- មេត្តាកាយកម្ម តាំងកាយកម្មប្រកបដោយមេត្តាចំពោះភិក្ខុសាមណេរផងគ្នា ទាំងចំពោះមុខនឹងកំបាំងមុខ គឺខ្វល់ខ្វាយក្នុងកិច្ចធុរ:ផងដោយកាយ មានជួយព្យាបាលក្នុងវេលាមានអាពាធ ;

២- មេត្តាវចីកម្ម តាំងវចីកម្មប្រកបដោយមេត្តាចំពោះភិក្ខុសាមណេរផងគ្នា ទាំងចំពោះមុខនឹងកំបាំងមុខ គឺជួយខ្វល់ខ្វាយកិច្ចធុរ:ផងគ្នាដោយវាចា មានប្រដៅដាស់តឿនជាដើម ;

៣- មេត្តាមនោកម្ម តាំងមនោកម្មប្រកបដោយមេត្តាចំពោះភិក្ខុសាមណេរផងគ្នា ទាំងចំពោះមុខនឹងកំបាំងមុខ គឺគិតតែរបស់ដែលជាប្រយោជន៍ឲ្យដល់គ្នា ;

៤- លាភ: ចែកលាភដែលខ្លួនបានមកហើយដោយធម៌ឲ្យភិក្ខុសាមណេរផងគ្នា មិនហួងហែង ឬត្បិតត្បៀតលាក់លៀមទុកបរិភោគប្រើប្រាស់តែម្នាក់ឯង ;

៥- សីល: រក្សាសីលបរិសុទ្ធស្មើគ្នា នឹងភិក្ខុសាមណេរដទៃ មិនធ្វើខ្លួនឲ្យជាទីរង្កៀសព្រោះសីលរបស់ខ្លួនមិនបរិសុទ្ធ ,

៦- ទិដ្ឋិ មានសេចក្តីយល់ឃើញត្រូវគ្នា នឹងភិក្ខុ

សាមណេរដទៃ មិនវិវាទនឹងអ្នកណា ព្រោះហេតុមានសេចក្ដីយល់ឃើញរុសគ្នាឡើយ ។

អធិប្បាយថា :

ធម៌ជាទីតាំងនៃសេចក្ដីរលឹក ហៅថា សារាណីយធម៌មាន ៦ យ៉ាង ធម៌ ៦ យ៉ាងនេះរមែងធ្វើអ្នកប្រព្រឹត្តឲ្យជាទីស្រឡាញ់ជាទីគោរពរបស់អ្នកដទៃ ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នានឹងគ្នា ដើម្បីមិនវិវាទគ្នាដើម្បីព្រមព្រៀងគ្នា ។

ធម្មតាមនុស្សដែលគ្មានមិត្ត កាលបើមានកិច្ចធុរៈកើតឡើងម្ដង ៗ ត្រូវខ្វល់ខ្វាយខ្នះខ្នែងដោយកម្លាំងខ្លួនម្នាក់ឯង មិនមានមនុស្សដទៃមកជួយជាកម្លាំងផង ។ រូបកាយមានដៃជើងសម្រាប់ជួយ បើខ្វះដៃ ឬ ជើង ហើយរមែងមានសេចក្ដីលំបាក ។ ដើមឈើមានឫសនឹងមែក សម្រាប់ជួយឲ្យរស់នៅបាន បើរុក្ខាវយវៈទាំងនោះគ្មានទេ ដើមឈើនោះក៏រស់នៅមិនបាន ត្រូវខ្យល់បក់មករលំបានដោយងាយ ។ ធម្មតាមនុស្សទាំងពួង បើរួបរួមគ្នាច្រើន ក៏រមែងមានកម្លាំងច្រើន ។ អម្បោះមួយសរសៃមិនស្វិតជាប់ប៉ុន្មានទេ ទាញតែមួយប្រិបក៏ដាច់បានតែបើគេវេញចូលជាច្លុងមួយ ទើបទាញមិនដាច់ ។ ស្រមោចមួយខាំនឹងទៅជាអ្វី ? ស្រមោចច្រើនមកចោមរោមខាំនឹងទៅជាយ៉ាងណា ? មនុស្សយើងក៏ដូចគ្នាដែរ ចំពោះខ្លួនមួយតស៊ូនឹងអ្នកណាក៏មិនឈ្នះដែរធ្វើអ្វីក៏

មិនបានច្រើនដែរ , លុះតែសាមគ្គីព្រមព្រៀងជួយគ្នាទើបបានកម្លាំងច្រើននឹងធ្វើការអ្វីក៏បានសម្រេចដូចបំណង ។

ដោយហោចទៅ សូម្បីនៅក្នុងទីណាហើយក្រឡេកមើលជុំវិញមិនស្គាល់អ្នកណាម្នាក់សោះ ក៏រមែងមិនបានសុខ មិនត្រូវពោលដល់មនុស្សដែលនៅក្នុងពួកជាមួយ ហើយមិនត្រូវគ្នាឡើយ ។ ព្រោះហេតុដូច្នេះសេចក្ដីមេត្រីស្និទ្ធស្នាលគ្នាដោយល្អ ទើបជាផលដែលបុគ្គលត្រូវស្វែងរកយ៉ាងក្រៃលែង ។ ក៏សេចក្ដីមេត្រីនោះ តែងកើតដោយសារាណីយធម៌ទាំង ៦ យ៉ាងដែលសម្ដែងមកនេះ ។ ធម្មតាបុគ្គលដែលជាទីស្រឡាញ់ គោរពរាប់អានរបស់ប្រជុំជនក៏ព្រោះអាស្រ័យឧបការគុណដែលខ្លួនបានធ្វើទុកដល់គេម្យ៉ាង អាស្រ័យសេចក្ដីប្រតិបត្តិល្អប្រតិបត្តិប្រពៃដោយកាយវាចាម្យ៉ាង ។ កាលបើបុគ្គលបានធ្វើសេចក្ដីខ្វល់ខ្វាយខ្នះខ្នែងក្នុងកិច្ចធុរៈរបស់គ្នានឹងគ្នា ដោយកាយវាចាក្ដីដោយមេត្តាចិត្តគិតនឹងជួយពិត ៗ ក្ដី មិនមានបំណងផលប្រយោជន៍ ក្នុងទីចំពោះមុខយ៉ាងណា ក្នុងទីកំបាំងមុខយ៉ាងនោះដែរ ។ អ្នកដែលបានទទួលឧបការដូច្នោះក៏នឹងមានចិត្តសោមនស្ស ស្មោះសរចំពោះឧបការគុណគិតនឹងតបស្នងឧបការៈខ្លះក្នុងវេលាដែលគួរ ។ អ្នកដែលបានទទួលមេត្រីចិត្តដូច្នេះ ខាងក្រោយក៏នឹងសំដែងមេត្រីចិត្តតបវិញ ។

ម្យ៉ាងទៀត កាលបើបានទ្រព្យសម្បត្តិដោយផ្លូវដ៏ល្អហើយមិនលាក់

លៀម ទុកបរិភោគប្រើប្រាស់តែម្នាក់ឯងអាចចែករំលែកដល់បុគ្គលដែលគួរឲ្យតាមមានតាមបាន ។ អ្នកដែលទទួលសេចក្ដីសង្គ្រោះដូច្នោះក៏នឹងមានចិត្ត សោមនស្សស្រឡាញ់ បើបានទ្រព្យអ្វី ៗ ក៏នឹងរំលែកចែកមកវិញ សមដូចសុភាសិតថា បូជកោ លភតេ បូជំ " អ្នកបូជាគេរមែងបានគេបូជាវិញ វន្ទកោ បដិវន្ទនំ " អ្នកសំពះគេរមែងបានគេសំពះវិញ " ដូច្នោះ ។

ម្យ៉ាងវិញទៀតបុគ្គលដែលប្រព្រឹត្តខ្លួនឲ្យជាអ្នក មានកាយវាចារៀបរយ គឺធ្វើអ្វីក៏មិនឲ្យអ្នកដទៃបានសេចក្ដីលំបាក ដោយ ឋានៈមិនមែនហេតុ ពោលវាចាក៏ផ្អែមពិរោះគួរគាប់ចិត្តហើយមានសេចក្ដីយល់ឃើញត្រូវតាមហេតុផល បើគិតអ្វីក៏សុទ្ធជាហេតុឲ្យសម្រេចផលដ៏ល្អទាំងជាប្រយោជន៍ខ្លួននឹងប្រយោជន៍អ្នកដទៃ ។ អ្នកដែលបានប្រព្រឹត្តដូច្នេះអាស្រ័យ គុណសេចក្ដីល្អរបស់ខ្លួន រមែងជាទីសោមនស្សស្រឡាញ់គោរពរបស់ប្រជុំជន នាំឲ្យមានការសង្គ្រោះគ្នានឹងគ្នាដោយមេត្តាចិត្ត ។

ធម្មតាមនុស្សដែលនឹងវិវាទទាស់ទែងបែកខ្ញែកគ្នា ក៏ព្រោះអាស្រ័យសេចក្ដីយល់ឃើញផ្សេង ៗ គ្នា មិនមានបំណងឲ្យជាប្រយោជន៍ដល់គ្នានឹងគ្នាខ្លះ មានសេចក្ដីប្រព្រឹត្តមិនស្មោះស្មើដែលជាហេតុឲ្យរង្គៀសដល់គ្នានឹងគ្នាខ្លះ បើនាំគ្នាដឹងឧបការគុណរបស់គ្នានឹងគ្នាក្ដី នាំគ្នាប្រព្រឹត្តស្មោះស្មើរកគ្នាមិនឲ្យជាទីរង្គៀសនៃគ្នានឹងគ្នាក្ដី ក៏រមែងមិនវិវាទទាស់ទែងបែកខ្ញែកគ្នា អាចធ្វើឲ្យមានសាមគ្គីព្រមព្រៀងជាមួយគ្នា ។ កាលបើមានសេចក្ដីព្រមព្រៀងមិនទាស់ទែងបែកខ្ញែកគ្នា ហើយក៏នឹងមានសេចក្ដីចំរើនមិនសាបសូន្យឡើយ ព្រោះហេតុដូច្នោះ អ្នកដែលប្រាថ្នាសេចក្ដីសុខសេចក្ដីចំរើនដល់ពួកក្រុម ប្រាថ្នានឹងចងស្ពានមេត្រីនឹងអ្នកដទៃនិងបំណងប្រយោជន៍សុខដើម្បីខ្លួន គប្បីបំពេញរាសីធម៌ទាំង ៦ យ៉ាងនេះឲ្យបរិបូណ៌ក្នុងខ្លួនចុះ ។

អាយតនៈខាងក្នុង ៦

ចក្ខុ ភ្នែក, សោតៈ ត្រចៀក, ឃានៈ ច្រមុះ, ជីវ្ហា អណ្ដាត, កាយៈ ខ្លួនប្រាណ, មនោចិត្តហៅឥន្ទ្រីយ ៦ ក៏បាន ។

អធិប្បាយថា :

ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ដែលមានឈ្មោះហៅថា អាយតនៈនោះដោយសេចក្ដីថាជាគ្រឿងតឬជាគ្រឿងជាប់ទាក់ទងគ្នា ។ សេចក្ដីថា: ដូចជាដៃដែលនឹងធ្វើឲ្យខ្លួនប្រាណយើងអាចជាប់តនឹងវត្ថុដែលនៅក្រៅខ្លួនយើងបានគឺភ្នែកជាប់តនឹងរូប ត្រចៀកជាប់តនឹងសម្លេង, ច្រមុះជាប់តនឹងក្លិន, អណ្ដាតជាប់តនឹងរស, កាយជាប់តនឹងផោដ្ឋព្វៈ (គឺវត្ថុគ្រប់យ៉ាងដែលកាយអាចពាល់ត្រូវហើយដឹងបាន) ចិត្តជាប់តនឹងធម្មារម្មណ៍ (គឺសេចក្ដីដឹងល្អអាក្រក់ស្អប់

ស្រឡាញ់ប្រាថ្នានឿយណាយ) ។ ដែលហៅថាអាយតនៈខាងក្នុងនោះ ព្រោះជារបស់ជាប់តនឹងកាយ ។

មួយវិញទៀត ដែលមានឈ្មោះហៅថា ឥន្ទ្រិយក៏បាននោះ ព្រោះរបស់ទាំងនេះសឹងជាធំក្នុងនាទីរបស់ខ្លួន ៗ គឺភ្នែកជាធំក្នុងការឃើញរូប , ត្រចៀកជាធំក្នុងការស្តាប់សម្លេង ។ល។ ចិត្តជាធំក្នុងការដឹងធម្មារម្មណ៍ដូច្នោះ ។

អាយតនៈខាងក្រៅ ៦

រូបៈ រូប , សទ្ទៈ សម្លេង , គន្ធៈ ក្លិន , រសៈ រស , ផោដ្ឋព្វ អារម្មណ៍ដែលប៉ះពាល់ត្រូវកាយ , ធម្មារម្មណ៍ អារម្មណ៍ដែលកើតចំពោះចិត្ត ។ ហៅថាអារម្មណ៍ ៦ ក៏បាន ។

អធិប្បាយថា :

របស់ទាំងនេះមានឈ្មោះថាអាយតនៈព្រោះជាគ្រឿងជាប់តនឹងរបស់ដែលជាប់ទាក់ទងនៅនឹងកាយ គឺសម្រាប់តនឹងអាយតនៈខាងក្នុងឲ្យជាគូ ៗ ដូច្នេះ ៖

១- រូបមកជាប់តនឹងភ្នែក, ២- សម្លេងមកជាប់តនឹងត្រចៀក,
៣- ក្លិនមកជាប់តនឹងច្រមុះ , ៤- រសមកជាប់តនឹងអណ្តាត,
៥- ផោដ្ឋព្វៈមកជាប់តនឹងកាយ, ៦- ធម្មារម្មណ៍មកជាប់តនឹងចិត្ត

ព្រោះរបស់ទាំងនេះនៅក្រៅកាយទើបហៅថាអាយតនៈខាងក្រៅ ។

មួយវិញទៀត , ដែលមានឈ្មោះហៅថាអារម្មណ៍បាននោះព្រោះរបស់ទាំងនេះជាធម្មជាតិដែលជាទីទន់ទាញនៃចិត្ត គឺអាចនឹងបង្អោនចិត្តឲ្យទៅជាផ្សេង ៗ បាន ហើយរមែងជាគ្រឿងជន្លចិត្តឲ្យជាប់នៅដូចខ្សែបង្ហៀរដែលអាចញាក់សេះឲ្យទៅកាន់ទីដែលប្រាថ្នាបាន ។

វិញ្ញាណ ៦

រូបប៉ះភ្នែកកើតសេចក្តីដឹងឡើង ហៅថាចក្ខុវិញ្ញាណ , សម្លេងប៉ះត្រចៀកកើតសេចក្តីដឹងឡើង ហៅថាឃានវិញ្ញាណ , រសប៉ះអណ្តាតកើតសេចក្តីដឹងឡើង ហៅថាជិវ្ហាវិញ្ញាណ , ផោដ្ឋព្វៈប៉ះកាយកើតសេចក្តីដឹងឡើងហៅថាកាយវិញ្ញាណ និងធម៌កើតចំពោះចិត្តកើតសេចក្តីដឹងឡើង ហៅថាមនោវិញ្ញាណ ។

អធិប្បាយថា :

វិញ្ញាណ ប្រែថា ការដឹងច្បាស់ ។ ការដឹងច្បាស់នេះ កើតអំពីអាយតនៈ ខាងក្នុងនឹងខាងក្រៅប៉ះគ្នា ។ វិញ្ញាណសញ្ញាបញ្ញាមានលក្ខណៈប្រហែល ៗ គ្នា ជួនកាលអាចធ្វើសេចក្តីចូលចិត្តខុសគ្នាក៏មាននឹងអធិប្បាយឲ្យល្អមជាឧទាហរណ៍ដូចតទៅនេះ វិញ្ញាណបានដល់ការដឹងច្បាស់, សញ្ញាបានដល់ការចាំបាន , បញ្ញាបានដល់សេចក្តីដឹងជុំវិញ ឧទាហរណ៍ដូចសម្លឹងទៅឃើញកំពែង ដែលមានពណ៌សកើតសេចក្តីដឹងឡើងថាពណ៌សដូច្នេះជាលក្ខណៈរបស់វិញ្ញាណ , ដឹងតទៅទៀតថា

ពណ៌សនោះ ជាកំបោរសដែលគេលាបបូកកំពែងសេចក្ដីដឹងយ៉ាងនេះជាលក្ខណៈរបស់សញ្ញា ។ ដឹងច្បាស់តទៅទៀតថា កំបោរសនេះជារបស់ធ្វើឡើងអំពីធាតុដីម្យ៉ាង គឺគេយកថ្មមកដុតភ្លើងឆ្អិនហើយបុកវែងនឹងត្រងដល់ទីបំផុតក៏ជាកំបោរសនេះឯងជាលក្ខណៈរបស់បញ្ញា ។

សម្ផស្ស ៦

អាយតនៈខាងក្នុងមានភ្នែកជាដើម អាយតនៈខាងក្រៅមានរូបជាដើម វិញ្ញាណមានចក្ខុវិញ្ញាណជាដើម មកខ្ទប់គ្នាទាំង ៣ នេះហៅថាសម្ផស្សមានឈ្មោះហៅតាមអាយតនៈខាងក្នុង ៦ គឺ ចក្ខុសម្ផស្ស, សោតសម្ផស្ស, ឃានសម្ផស្ស, ជិវ្ហាសម្ផស្ស, កាយសម្ផស្ស, មនោសម្ផស្ស ។

អធិប្បាយថាៈ

ពាក្យថា សម្ផស្ស នេះ លោកឲ្យឈ្មោះហៅថាតាមអាការៈរបស់អាយតនៈខាងក្នុង នឹងអាយតនៈខាងក្រៅ នឹងវិញ្ញាណមកខ្ទប់គ្នា ។ សម្ផស្សនេះជារបស់សំខាន់បំផុត ជាដើមហេតុរបស់កុសលាកុសលធម៌ទាំងពួងមែនពិត ព្រោះហេតុនេះ ទើបលោកប្រដៅឲ្យសង្រួមអាយតនៈខាងក្នុង ព្រោះថាបើមកខ្ទប់នឹងអាយតនៈខាងក្រៅហើយហេតុការណ៍ផ្សេង ៗ ក៏កើតឡើង ។ កិរិយាដែលបានសង្រួមខ្លះហើយនោះជាគ្រឿងរាំងទប់ចិត្តមិនឲ្យកើតសេចក្ដីសោមនស្សទោមនស្សលោក ។

វេទនា ៦

សម្ផស្ស ជាបច្ច័យឲ្យកើតវេទនា , គឺជាសុខខ្លះ , ទុក្ខខ្លះ , មិនសុខ មិនទុក្ខខ្លះ មានឈ្មោះហៅតាមអាយតនៈខាងក្នុង ៦ គឺកើតផ្លូវភ្នែក ហៅ ចក្ខុសម្ផស្សជា វេទនា, កើតផ្លូវត្រចៀកហៅ សោតសម្ផស្សជា វេទនា កើតផ្លូវច្រមុះហៅ ឃានសម្ផស្សជា វេទនាកើតផ្លូវអណ្ដាត ហៅ ជិវ្ហាសម្ផស្សជា វេទនា , កើតផ្លូវកាយហៅ កាយសម្ផស្សជា វេទនា , កើតផ្លូវចិត្តហៅ មនោសម្ផស្សជា វេទនា ។

អធិប្បាយថាៈ

អាយតនៈខាងក្នុងនឹងអាយតនៈខាងក្រៅមកខ្ទប់គ្នាកើត វិញ្ញាណប្រជុំធម៌ ៣ ប្រការនេះកើតជាសម្ផស្ស ។ សម្ផស្សជាបច្ច័យឲ្យកើតវេទនា ជាសុខខ្លះ ទុក្ខខ្លះ មិនសុខមិនទុក្ខខ្លះ តាមអាយតនៈខាងក្រៅជាទីតាំងនៃវេទនាយ៉ាងណា រមែងបានសោយវេទនាជាយ៉ាងនោះ ។ សម្ដែងឧទាហរណ៍ ដូចត្រចៀកបានសម្លេង កើតវិញ្ញាណនឹងសម្ផស្សដោយលំដាប់គ្នា សំឡេងនោះពីរោះគេសរសើរយើងរមែងបានសោយសុខ , មិនពីរោះគេនិន្ទាយើងរមែងបានសោយទុក្ខ ។ ក្រៅអំពីនោះរមែងបានសោយឧបេក្ខា ។

ធាតុ ៦

បឋវីធាតុ ធាតុដី ១, អាបោធាតុ ធាតុទឹក ១, តេជោធាតុ ធាតុភ្លើង ១, វាយោធាតុ ធាតុខ្យល់ ១, អាកាសធាតុ ចន្លោះដែលមានក្នុងកាយ ១, វិញ្ញាណធាតុ សេចក្ដីដឹងអ្វី ៗ បាន ១ ។

អធិប្បាយថាៈ

បឋវីធាតុ មានរបស់ដែលរឹង ៗ ជាលក្ខណៈ មានកិរិយាតាំងទុកនូវធាតុទាំង ៣ ជាកិច្ច មានកិរិយាដែលរងធាតុទាំង ៣ ទុកជាផល ។

អាបោធាតុ មានកិរិយាដែលភាវជ្រួតជ្រាបជាលក្ខណៈធ្វើឲ្យសរីរៈស្រស់ថ្លារឹងប៉ឹងស្រស់បស់ជាកិច្ច ឲ្យកម្លាំងសង្គ្រោះធាតុទាំង ៣ ជាផល ។

តេជោធាតុ មានអាការៈក្ដៅជាលក្ខណៈញុំាងអាហារឲ្យរលួយល្អិតជាកិច្ច ញុំាងកាយឲ្យទ្រុឌទ្រោមទៅជាផល ។

វាយោធាតុ មានកិរិយាដែលទប់ទល់កាយឬទ្រទ្រង់កាយបានជាលក្ខណៈ ញុំាងកាយឲ្យញាប់ញ័រគ្រឡប់ប្រែប្រួលខ្លួនបាននិយាយបានជាកិច្ចនាំទៅកាន់ទិសទាំងឡាយបាន ធ្វើការងារបានដោយសមគួរដល់សេចក្ដីប្រាថ្នាជាផល ។

ធម្មជាតិ ៤ ប្រការនេះដែលបាននាមបញ្ញត្តិជាធាតុនោះ ព្រោះហេតុថាទ្រទ្រង់ទុកនូវលក្ខណៈនៃខ្លួន , គឺធាតុដី ទ្រទ្រង់នូវលក្ខណៈដ៏រឹង ។ ធាតុទឹកទ្រទ្រង់នូវលក្ខណៈដ៏ភាវជ្រួតជ្រាប ។ ធាតុភ្លើងទ្រទ្រង់នូវលក្ខណៈដ៏ក្ដៅ ។ ធាតុខ្យល់ទ្រទ្រង់នូវលក្ខណៈដ៏ញាប់ញ័រ ។ នេះឯងបានឈ្មោះថាទ្រទ្រង់នូវលក្ខណៈនៃខ្លួន ។

ន័យមួយទៀត, ប្រែថាទ្រទ្រង់នូវទុក្ខ ព្រោះហេតុជាទីតាំងនៃទុក្ខ ។ បើដី ទឹក ភ្លើង ខ្យល់ គ្មានហើយ មិនកើតជារូបកាយឡើយ សេចក្ដីទុក្ខវេទនានឹងមានមកអំពីណា ? នេះអាស្រ័យហេតុដែលមាន ដីទឹកភ្លើងខ្យល់បង្កើតឡើងជារូបកាយហើយ សេចក្ដីទុក្ខវេទនាទើបកៀគរប្រមូលបញ្ចូលជាអនន្តបរិមាណដូច្នេះ ។

ហេតុនៃធាតុ ៤ គឺ ដី ទឹក ភ្លើង ខ្យល់ នេះប្រមូលគ្នា កើតឡើងឯងដូច ទឹក ភ្លើង ខ្យល់ ៣ នេះជាហេតុឲ្យកើតដី ។ ដី ភ្លើង ខ្យល់ ៣ នេះជាហេតុឲ្យកើតទឹក ។ ដី ខ្យល់ ទឹក នេះជាហេតុឲ្យកើតភ្លើង ។ ដី ទឹក ភ្លើង ៣ នេះជាហេតុឲ្យកើតខ្យល់ ។ អាកាសធាតុនោះជាហេតុ ដែលកំណត់ដឹងបានដោយកម្រ ព្រោះជារបស់ល្អិតសុខុម មើលមិនឃើញដោយចក្ខុទេ អាចដឹងបានដោយសម្ផស្ស តែក៏គង់ដឹងបានដោយកម្រដូចគ្នា ។ គប្បីចូលចិត្តចុះថាបណ្ដាដែលជាចន្លោះ ៗ នៅក្នុងកាយនៃយើងទាំងឡាយ គឺប្រហោងត្រចៀកប្រហោងមាត់ ប្រហោងច្រមុះជាដើម ឈ្មោះថាអាកាសធាតុ ។

វិញ្ញាណធាតុនោះបានដល់ធាតុ ១៨ គឺទ្វារ ៦ មាន ចក្ខុ សោតៈ

ឃានៈ ជិវ្ហា កាយ មនោ ។ អារម្មណ៍ ៦ គឺរូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ធម្មៈ ។ វិញ្ញាណ ៦ គឺ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ ។ សេចក្តីឈ្លាសវៃក្នុងធាតុទាំងនេះ ជាបញ្ញាយ៉ាងខ្ពង់ខ្ពស់ ជាបញ្ញាដ៏សុខុមជាបញ្ញាដែលនិយមក្នុងផ្លូវព្រះពុទ្ធសាសនាយ៉ាងក្រៃលែង ។ បញ្ញាក្នុងក្រៃសិក្ខារបស់ភិក្ខុ ក៏បំណងចំពោះបញ្ញាដែលឈ្លាសវៃក្នុងរឿងធាតុទាំងនេះដែរ ។ សេចក្តីឈ្លាសវៃដឹងជុំវិញក្នុងធាតុទាំងនេះជារបស់ដែលត្រូវប្រាថ្នាទាំងផ្លូវលោកទាំងផ្លូវធម៌ ។

ភាគ ២ ចប់តែប៉ុណ្ណោះ